ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ជីវិតម្ដាយ
- សាក្សីប្រវត្តិសាស្ត្រ៖ សៀវភៅកំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៨៣ ខែកក្កដា ឆ្នាំ២០២៣

# ស្វែងរកការពិត

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨៣ ខែកក្កដា ឆ្នាំ២០២៣



ស្ត្រីរស់នៅភូមិសុភី ឃុំដូងខ្ពស់ ស្រុកបូរីជលសារ ខេត្តតាកែវ កំពុងអានសៀវភៅ សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ


- ជីវិតម្ដាយ ........................................ ១
- សាក្សីប្រវត្តិសាស្ត្រ៖ សៀវភៅកំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ .......................... ៤


### ផ្នែកឯកសារ


- គុណថុន ថាណារ៉ាក់ ៖ មន្ទីររោងពុម្ព ............. ៦


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- បណ្ណាល័យសម្ដេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បោះពុម្ពសៀវភៅ សាក្សី ..........................១០
- ក្រុមការងារគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជាពិនិត្យសុខភាពបឋមនៅភូមិក្ដុលលើ.... ១៤
- ក្រុមការងារគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះពិនិត្យសុខភាពបឋម....... ១៧
- រំភើបចិត្ត ពេលឃើញសម្ដេចម៉ែ................. ២០
- រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការ នៅក្នុងភូមិ .................. ២៣
- ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង នាំយកសៀវភៅ "សាក្សីប្រវត្តិសាស្ត្រ".......... ២៧
- អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជាភូមិបាក់នឹមចុះចែកសៀវភៅព័ត៌មាន ....................... ៣០
- ង៉ែត សំ ៖ កងចល័តនៅក្នុងរបបខ្មែរ ......... ៣២


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- វេទិកាអ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម និងដំណើរទស្សនកិច្ចសិក្សាទៅ................... ៣៤
- មជ្ឈមណ្ឌលឯកសារកោះថ្ម ត្រួតពិនិត្យ និងវាយតម្លៃការសិក្សារបស់សិស្សដែល ............. ៣៧
- សិស្សមកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន លាដលើចូលរួមវេទិកាថ្នាក់រៀនស្ដីអំពីប្រវត្តិសាស្ត្រខ្មែរ..៤០
- សាមណនិស្សិត និស្សិត និងសាស្ត្រាចារ្យនៃពុទ្ធិកសកលវិទ្យាល័យសម្ដេចអគ្គមហាសេនាបតី... ៤៤
- វេទិកាថ្នាក់រៀនចុងសប្ដាហ៍ស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅខេត្តតាកែវ................ ៤៨
- វេទិកាអប់រំសហគមន៍ស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ក្នុងស្រុកវាលវែង........... ៥១
- មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំសិក្ខាសាលាអំពីការថែរក្សាសុខភាពសម្រាប់អ្នករស់រាន ......៥៥


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- **«ទួលពិឃាដ» (ត)** ............................. ៥៩


**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, ដា៉រដ្ឋ មេត្តា, សោម ប៊ុនថន, គីម សុវណ្ណដានី, ផេង ពង្សរ៉ាស៊ី, វី ស៊ីថា, ឡុង ដានី, ដាត ចាន់សុនិតា, ផន វន្នី, ទូច វណ្ណេត, ភា រស្មី, រីម ស្រីស្រស់, កើត សុរចនា និង ឡុង វង្សសម័ទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ីភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉រដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ជីវិតម្តាយ

ឆាំង យុ



កែវ ណាន អាយុ៩៥ឆ្នាំ នៅវត្តលង្កា។
(អ៊ូច មករា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងជីវិតយើងម្នាក់ៗ តែងតែជួបប្រទះនូវហេតុការណ៍មួយចំនួន ដែលធ្វើឲ្យយើងនឹកគិតដល់គំនិតមួយ ក៏ដូចជាសំណួរមួយចំនួន ដែលហាក់បីដូចជាមានអាទិភាពខ្លាំងណាស់នៅពេញមួយជីវិតរបស់យើង។ ដូចជាហេតុការណ៍នៃការចូលមន្ទីរពេទ្យដំណាក់កាលចុងក្រោយរបស់ម្តាយខ្ញុំនាពេលថ្មីៗនេះ គឺជាកាលៈទេសៈមួយដែរ ហើយហេតុការណ៍នេះ មិនត្រឹមតែជំរុញឲ្យខ្ញុំនឹកគិតដល់ជីវិតរបស់ម្តាយខ្ញុំតែប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឲ្យខ្ញុំបាននឹកគិតទៅដល់ការលះបង់របស់គាត់ចំពោះក្រុមគ្រួសារ កូនចៅ ក៏ដូចជាការលះបង់របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់សម្រាប់ប្រជាជាតិកម្ពុជា ទាំងមូល។

ម្តាយរបស់ខ្ញុំឈ្មោះ កែវ ណាន កើតឆ្នាំ១៩២៨ ត្រូវនឹងឆ្នាំម្សាញ់ នៅភូមិខ្នែរលើ ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ដូចទៅនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដទៃទៀតដែរ គាត់មានកូនច្រើននាក់ ប៉ុន្តែមួយចំនួនបានបាត់បង់ជីវិតអស់ទៅហើយ។ នៅលើលោកនេះ ប្រហែលជាគ្មានការឈឺចាប់ណាស្មើនឹងការឈឺចាប់ដែលកូនរបស់ខ្លួនត្រូវលាចាកលោកមុនឪពុកម្តាយនោះទេ ហើយរបបខ្មែរក្រហមគឺជារបបដែលបន្សល់ទុកនូវការឈឺចាប់ដ៏យូរអង្វែងមួយ ដែលធ្វើឲ្យកូនៗ ឪពុកម្តាយ និង

គ្រួសាររបស់ពួកគាត់ជាច្រើនស្លាប់ទាំងគ្មានកំហុស។

ម្តាយរបស់ខ្ញុំបានជួបរឿងដ៏គួរឲ្យរន្ធត់ជាខ្លាំង ដោយគាត់ត្រូវប្រឈមមុខមើលកូនចំនួន៦នាក់ ក្នុងចំណោមកូន១០នាក់ ទទួលមរណភាព កូនខ្លះស្លាប់នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលសង្គ្រាម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហមដ៏ឃោរឃៅ។ ខ្ញុំគឺជាកូនពៅ ដែលជាកូនទី១០ ក្នុងគ្រួសារ ហើយម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំថា នៅពេលខ្ញុំកើតមក គាត់បានដាក់ឈ្មោះឲ្យខ្ញុំផ្សេងមួយទៀត ប៉ុន្តែដោយសារតែការភ័យខ្លាច និងជំនឿផ្សេងៗផងនោះ គាត់ក៏បានដាក់ឈ្មោះដូចសព្វថ្ងៃនេះមកឲ្យខ្ញុំ (អាយុ)។ ឈ្មោះរបស់ខ្ញុំដែលគាត់ដាក់ឲ្យនៅពេលដែលខ្ញុំកើត គឺសំដៅលើថ្ងៃដែលខ្ញុំកើត គឺថ្ងៃចន្ទ (គាត់ដាក់ឈ្មោះថា ចន្ទសុខ) ហើយគាត់ជឿថា ឈ្មោះនេះអាចជួយឲ្យខ្ញុំមានសំណាងល្អ អាចរស់រានមានជីវិតនៅក្នុងស្ថានភាពលំបាកដែលយើងរស់នៅក្នុងពេលនោះ។

កាលពីសម័យខ្មែរក្រហម ខ្ញុំនៅជាកូនក្មេងនៅឡើយ ហើយខ្ញុំមិនសូវដឹងច្រើនអំពីរបៀបរស់នៅនោះទេ។ ប៉ុន្តែខ្ញុំបានរៀនចេះអំពីរបៀបរស់បានយ៉ាងឆាប់រហ័ស ដោយសារតែខ្ញុំមិនអាចទ្រាំនឹងសេចក្តីស្រេកឃ្លានដែលទារុណកម្មមួយដ៏ធ្ងន់ធ្ងរមកលើរូបខ្ញុំ។ ប៉ុន្តែ ដូចទៅនឹងបងប្អូនបង្កើតរបស់ខ្ញុំទាំងអស់ដែរ យើងតែងតែពឹងផ្អែកលើម្តាយរបស់យើងដើម្បីធ្វើជាអ្នកណែនាំ ពុះពារ និងជាអ្នកថែទាំយើងដ៏រឹងមាំមួយ។ នៅពេលរំពឹកអំពីអតីតកាលបែបនេះ គឺធ្វើឲ្យខ្ញុំមានចិត្តមិនស្ងប់ នៅពេលនឹងគិតដល់តួនាទីម្តាយរបស់ខ្ញុំនៅក្នុងគ្រួសារ នៅក្នុងសម័យកាលដ៏លំបាកលំបិនបំផុតនោះ និងការទទួលស្គាល់តួនាទីរបស់គាត់ដែលកាន់តែតិចទៅៗនៅបណ្តាឆ្នាំក្រោយៗមកទៀតនៅក្នុងក្រុមគ្រួសារយើង។ ក្តីរន្ធត់ដ៏ខ្លាំងប្រៀបបានទៅនឹងរបបខ្មែរក្រហមដែរនោះ ខ្ញុំគិតថាស្មារតីរបស់ម្តាយខ្ញុំ និងការផ្តល់តម្លៃលើខ្លួនឯងគឺពិតជាអស្ចារ្យណាស់ក្នុងពេលនោះ ដោយសារតែយើងទាំងអស់គ្នាពឹងផ្អែកទៅលើគាត់ដើម្បីអាចរស់បាន ហើយគាត់ និងយើងទាំងអស់គ្នា ពិតជាទទួលស្គាល់ថានេះគឺជាការពិត។

មានការលើកឡើងជួយគ្នា យ៉ាងហោចណាស់ចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មួយចំនួនដែលថា ស្មារតីនៃការសម្រេចគោលបំណង និងតម្លៃគុណបំណាច់មួយចំនួនកើតឡើងដោយសារការឆ្លងកាត់សម័យខ្មែរក្រហមនោះ ហើយនៅពេលជីវិតយើងមានភាពល្អប្រសើរ សង្គមមានការវិវឌ្ឍទៅមុខ ស្មារតីនៃការសម្រេចតម្លៃគុណបំណាច់នេះ ហាក់បីដូចជាមានការធ្លាក់ថយចុះ រហូតក្លាយជាការចងចាំមួយដែលត្រូវបានគេបំភ្លេចចោលសម្រាប់សង្គមកម្ពុជា បើទោះបីជាមិនមានការបំភ្លេចចោលទាំងស្រុងយ៉ាងណាក្តី។

នៅក្រោយរបបខ្មែរក្រហម ក្រុមគ្រួសាររបស់ខ្ញុំ និងខ្ញុំនៅតែពឹងផ្អែកទៅលើជំហររឹងមាំរបស់ម្តាយយើង ប៉ុន្តែនៅពេលដែលពេលវេលាចេះតែរំកិលទៅមុខ ហើយជីវិតក៏ចាប់ផ្តើមត្រឡប់ទៅរកភាពនឹងនរ និងធម្មតាវិញម្តងបន្តិចៗ ហើយយើងក៏ចាប់ផ្តើមលែងសូវពឹងផ្អែកទៅលើម្តាយរបស់យើងតទៅទៀតដែរ។ នៅពេលដែលម្តាយរបស់យើងមានវ័យកាន់តែចាស់ទៅៗ យើងមិនបានចងចាំអំពីស្មារតី ភាពរឹងមាំ និងការដឹកនាំ ភាពនឹងនរ និងការថែទាំដូចដែលគាត់មានកាលពីនៅក្មេងទៀតឡើយ។

កូនៗរបស់អ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ជំនាន់កូនរបស់ពួកគេ និងអ្នកជំនាន់ក្រោយៗ មិនត្រូវភ្លេចទេថា ឪពុកម្តាយរបស់យើងដែលបានរស់ក្នុងរបបខ្មែរក្រហមនោះ មិនត្រឹមតែដើរតួនាទីជាឪពុកម្តាយ ជីដូនជីតា របស់អ្នកជំនាន់ក្រោយនេះនោះទេ លើសពីនេះគាត់ទាំងអស់ក៏ជាវីរជនដែលមានគុណូបការៈចំពោះប្រទេសជាតិទៀតផង។ រហូតទាល់តែដល់ថ្ងៃនេះ ដែលស្ថានភាពសុខភាពម្តាយរបស់ខ្ញុំចុះខ្សោយជាបន្តបន្ទាប់ ទើបខ្ញុំភ្ញាក់ខ្លួនថា ខ្ញុំនៅជំពាក់គុណបំណាច់គាត់ដ៏មហាធំធេង ហើយសង្គមខ្មែរនៅជំពាក់គុណូបការៈចំពោះវីរជនជំនាន់នោះយ៉ាងច្រើនលើសលុប ក្នុងការជួយ

រក្សាជីវិតគ្រួសាររបស់គាត់ទាំងអស់ឲ្យរស់រាននៅក្នុងសម័យកាលដ៏យង់ឃ្នងមួយនេះ។

ខ្ញុំសូមសម្តែងនូវការដឹងគុណជាអនេកចំពោះក្រុមវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងបុគ្គលិក ដែលបានជួយព្យាបាល និងថែទាំម្តាយរបស់ខ្ញុំ ជាពិសេស គឺលោកវេជ្ជបណ្ឌិតខ្មែរវ័យក្មេង ឆ ប៊ុនប៉ូល ឯកទេសផ្នែកថែទាំសួត និងផ្លូវដង្ហើម។ ខ្ញុំក៏សូមដឹងគុណដល់វេជ្ជបណ្ឌិត កាំង គីមសាន និង លោកប្រធានវេជ្ជបណ្ឌិត រិទ្ធ និងវេជ្ជបណ្ឌិត ភោគ សុវណ្ណ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកពីសំណាក់ប្រទេសបារាំងក្នុងប្រព័ន្ធសុខាភិបាលសាធារណៈរបស់ប្រទេសកម្ពុជា ដែលការរួមចំណែកនេះពិតជាបានផ្តល់ជាជំនួយជាច្រើនដល់ប្រជាជនកម្ពុជាដែលមានតម្រូវការផ្នែកថែទាំវេជ្ជសាស្ត្រទំនើប ព្រមទាំងវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងបុគ្គលិកវ័យក្មេងដែលបម្រើការងារនៅទីនោះ។ ការរួមចំណែកនេះបានផ្តល់ឱកាសដល់យុវជនកម្ពុជាវ័យក្មេងក្នុងការសិក្សា អនុវត្ត និងសម្រួចជំនាញ និងឯកទេសរបស់ខ្លួននៅមណ្ឌលវេជ្ជសាស្ត្រដែលមានវិជ្ជាជីវៈខ្ពស់បែបនេះ។ សរុបមក ម្តាយរបស់ខ្ញុំនឹងមិនអាចមានជីវិតរស់រានបានឡើយ ប្រសិនបើគ្មានការថែទាំពីសំណាក់វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងបុគ្គលិកទាំងនោះ។

(ពីឆ្វេងទៅស្តាំ)៖ ចៅទួត កែវ ណាន, កែវ ណាន, ឆាំង យុ កូនប្រុសពៅ កែវ ណាន ថតនៅព្រះបរមរាជវាំង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជារួម ប្រទេសកម្ពុជា នឹងមិនអាចក្លាយជាប្រទេសដ៏រឹងមាំ និងមានភាពធន់រហូតមកដល់សព្វថ្ងៃនេះបានដែរ ប្រសិនបើគ្មានភាពរឹងមាំ ការលះបង់ និងវីរភាពរបស់មនុស្សចាស់ជំនាន់មុនដែលបានឆ្លងកាត់របបខ្មែរក្រហម។ យើងពិតជាមានការដឹងគុណ សេចក្តីគោរព និងសូមផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ចំពោះគាត់គ្រប់ៗគ្នា។

នៅពេលដែលខ្ញុំសរសេរអត្ថបទនេះ ម្តាយរបស់ខ្ញុំគឺនៅមានជីវិតនៅឡើយទេ ប៉ុន្តែខ្ញុំពិតជាមិនដឹងទេថា តើគាត់អាចនឹងនៅបន្តមានជីវិតរហូតដល់ពេលដែលអត្ថបទនេះត្រូវបានចុះផ្សាយជាសាធារណៈដែរឬទេ។ ជីវិតរបស់គាត់គឺស្ថិតនៅក្នុងដៃទេវតាទៅហើយ ហើយខ្ញុំមិនមានអ្វីក្រៅពីការបួងសួងសូមឲ្យទេវតាថែរក្សាគាត់ជាប់ជានិច្ចទៅ។



# សាក្សីប្រវត្តិសាស្ត្រ៖
## សៀវភៅកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

**ឆាំង យុ**




*សៀវភៅកំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ឆ្នាំ២០២៣ គឺជាខួបអនុស្សាវរីយ៍គម្រប់ ៥០ឆ្នាំ គិតចាប់តាំងពីកាលដែលសម្ដេចព្រះវររាជមាតាជាតិខ្មែរ ព្រះអង្គបានសព្វព្រះរាជហឫទ័យរាជចំណារលើសៀវភៅកំណត់ហេតុស្ដីពីព្រះរាជដំណើរជាប្រវត្តិសាស្ត្ររបស់ព្រះអង្គ។ ឆ្លៀតក្នុងឱកាសនេះ បណ្ណាល័យសម្ដេចម៉ែ មានមហាកិត្តិយសសូមប្រកាសនូវការចេញផ្សាយការបកប្រែជាភាសាខ្មែរនៃព្រះរាជកំណត់ហេតុឆ្នាំ១៩៧៣កត់ត្រាអំពីព្រះរាជដំណើរជាប្រវត្តិសាស្ត្ររបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ។ សៀវភៅនេះមានចំណងជើងថា "សាក្សីប្រវត្តិសាស្ត្រ៖ សៀវភៅកំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ" ដែលជាឯកសារប្រវត្តិសាស្ត្រគ្មានពីរ បានបង្ហាញអំពីព្រះរាជហឫទ័យសង្កេតផ្ទាល់របស់សម្ដេចព្រះមហាក្សត្រី ក្នុងព្រះរាជបេសកកម្ម និងព្រះរាជដំណើររបស់ព្រះអង្គ យាងទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជា ស្ថិតនៅក្នុងប្រទេសកម្ពុជា។ សម្ដេចព្រះមហាក្សត្រីបានយាងអមព្រះរាជដំណើរ ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ ចាប់ផ្ដើមចេញពីការយាងព្រះរាជដំណើរតាមព្រះទីនាំងយន្តហោះចេញពីទីក្រុងប៉េកាំង ឆ្ពោះទៅកាន់ទីក្រុងហាណូយ និងបន្ទាប់មកបន្តដំណើរដោយព្រះទីនាំងរថយន្តតាមបណ្ដោយផ្លូវលំ ហូជីមិញ ឆ្ពោះទៅកាន់ខេត្តសៀមរាប/អង្គរវត្ត ដោយឆ្លងកាត់ផ្នែកខ្លះនៃផ្លូវលំ សីហនុ ក្នុងរយៈពេលប្រមាណ៣៩ថ្ងៃ។

ព្រះរាជដំណើរនេះ មានព្រះរាជគោលបំណង៖ ទីមួយ គឺដើម្បីយាងអង្កេតការណ៍លើតំបន់ព្រំដែនប៉ែកខាងកើតនៃប្រទេសកម្ពុជា ដែលតំបន់នេះត្រូវបានកាត់ផ្ដាច់មិនអាចធ្វើដំណើរទៅដល់ក្នុងរយៈកាល

ជាងបីឆ្នាំកន្លងមក ដោយសារតែសង្គ្រាមរ៉ាំរ៉ៃ, ការទម្លាក់គ្រាប់បែក និងការកាន់កាប់ៗ ទីពីរ គឺដើម្បីយាងជួបជាមួយប្រជានុរាស្ត្រកម្ពុជានៅក្នុងតំបន់នេះ ដើម្បីឈ្វេងយល់អំពីស្ថានភាព និងតម្រូវការរបស់ប្រជាជនទាំងនោះៗ ទីបី គឺដើម្បីធានាជូនប្រជានុរាស្ត្រថាព្រះអង្គទាំងទ្វេ គឺជាថ្នាក់ដឹកនាំនៃចលនាតស៊ូកម្ពុជាៗ ថ្វីត្បិតតែត្រូវប្រឈមទៅនឹងភាពលំបាកលំបិន និងហានិភ័យដ៏ប្រថុយប្រថានដូចដែលបានពិពណ៌នានៅក្នុងខ្លឹមសារនៃកំណត់ហេតុនេះស្រាប់យ៉ាងណាក្តី សម្តេចព្រះមហាក្សត្រីនៅតែមិនរួញរាក្នុងការចូលរួមនៅក្នុងព្រះរាជដំណើរនេះៗ សៀវភៅកំណត់ហេតុនេះ បានរំលេចអំពីគោលគំនិតមួយស្តីអំពីប្រវត្តិសាស្ត្រសហសម័យ ហើយអ្វីដែលសំខាន់ជាងនេះទៀតនោះគឺផ្តល់ជាមាគ៌ាមួយបង្ហាញអំពីភាពអង់អាច និងតួនាទីផ្ទាល់ព្រះកាយដ៏វិសេសវិសាលរបស់សម្តេចព្រះមហាក្សត្រីក្នុងព្រះបរមនាមជាអ្នកគ្រួសត្រាយ និងជាព្រះរាជគំរូសម្រាប់ស្ត្រីកម្ពុជាគ្រប់វ័យ ទាំងក្មេង និងចាស់ៗ

សម្តេចព្រះវររាជមាតាជាតិខ្មែរ ព្រះលិខិតផ្ទាល់ព្រះហស្តនូវបទពិសោធន៍របស់ព្រះអង្គលើចំណារដើមជាភាសាបារាំងៗ នៅក្នុងឆ្នាំ២០២១ សម្តេចព្រះវររាជមាតាជាតិខ្មែរ ព្រះអង្គបានប្រោសព្រះបរមរាជានុញ្ញាតដល់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបកប្រែជាផ្លូវការនូវសៀវភៅកំណត់ហេតុរបស់ព្រះអង្គទៅជាភាសាអង់គ្លេស ដើម្បីផ្តល់ឱកាសសិក្សាឈ្វេងយល់ដល់អ្នកអានទូទៅឲ្យបានទូលំទូលាយជាងមុនៗ មិនតែប៉ុណ្ណោះ សម្តេចព្រះវររាជមាតាជាតិខ្មែរ ព្រះអង្គក៏បានសព្វព្រះរាជហឫទ័យព្រះបរមរាជានុញ្ញាតដល់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការបកប្រែជាផ្លូវការនូវសៀវភៅកំណត់ហេតុរបស់ព្រះអង្គទៅជាភាសាខ្មែរផងដែរៗ ការបកប្រែជាភាសាខ្មែរនូវព្រះរាជកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រីបានបញ្ចប់រួចរាល់ និងបានបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជាៗ

ការបកប្រែជាភាសាខ្មែរចំពោះសៀវភៅកំណត់ហេតុនេះ គឺពិតជាមានសារសំខាន់ចំពោះប្រវត្តិវិទូ និងប្រជាជនកម្ពុជាគ្រប់រូបៗ សៀវភៅកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី គឺជាសំអាងនៃកំណត់ត្រាប្រវត្តិសាស្ត្រដ៏សំខាន់បំផុតពុំអាចកាត់ថ្លៃបាន ពិពណ៌នារយៈកាលដ៏វិសេសវិសាលមួយសម្រាប់ប្រជាជនកម្ពុជាទាំងអស់ៗ បច្ចុប្បន្នសៀវភៅកំណត់ហេតុជាភាសាខ្មែរនេះ ត្រូវបានបោះពុម្ពចំនួន ៣៥០០០ក្បាល ដែលនឹងចែកជូនដល់យុវនារីនៅទូទាំងប្រទេសកម្ពុជា ដើម្បីបណ្តុះគំនិត, លើកទឹកចិត្ត និងគាំទ្រដល់អ្នកទាំងនេះ ក្នុងការអប់រំ និងការអភិវឌ្ឍខ្លួនក្នុងនាមជាអ្នកដឹកនាំៗ អនាគតរបស់កម្ពុជា នឹងពឹងផ្អែកទៅលើភាពជាអ្នកដឹកនាំរបស់ស្ត្រីដូចទៅនឹងបុរសដែរ ហើយសៀវភៅកំណត់ហេតុនេះ ដើរតួនាទីជាឯកសារគោលសម្រាប់ភាពជាអ្នកដឹកនាំរបស់ស្ត្រី នៅក្នុងសង្គមមួយដែលប្រកបដោយសន្តិភាព និងភាពចម្រុងចម្រើនសម្រាប់មនុស្សគ្រប់គ្នាៗ





ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ និង សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ជាមួយមេដឹកនាំចិនៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គុណថុន ថាណារាក់ ៖ មន្ទីររោងពុម្ព ក-២៥

**ដារ៉ារដ្ឋ មេត្តា**



*កម្មាភិបាលខ្មែរក្រហមនៅរោងពុម្ពកំពុងបោះពុម្ពទស្សនាវដ្តីទង់បដិវត្តន៍។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ គុណថុន ថាណារាក់ ហៅ ពេញ ភេទប្រុស អាយុ២៧ឆ្នាំ នៅក្នុងឆ្នាំ១៩៧៧ ហើយខ្ញុំមិនទាន់មានគ្រួសារទេ។ ខ្ញុំមានស្រុកកំណើតនៅសង្កាត់លេខ២ ក្រុងភ្នំពេញ។ ឪពុកខ្ញុំឈ្មោះ គុណដុន ថាច មានអាយុ៥៨ឆ្នាំ នៅក្នុងឆ្នាំ១៩៧៧ និងម្តាយឈ្មោះ កុយ ណាច មានអាយុ៥២ឆ្នាំ នៅក្នុងឆ្នាំ១៩៧៧។ ឪពុកខ្ញុំគឺជាលេខាធិការនៅក្រសួងសូនិចស៊ីមភ្នំពេញ ចំណែកម្តាយខ្ញុំធ្វើការនៅសាលាក្រុងភ្នំពេញ គឺជាលេខាធិការិនី។ ក្រោយមកឪពុកម្តាយខ្ញុំបានលែងលះគ្នានៅពេលខ្ញុំមានអាយុ២ឆ្នាំ។ ឪពុកម្តាយខ្ញុំក៏មានគ្រួសារថ្មីរៀងៗខ្លួន ហើយម្តាយខ្ញុំជាមួយគ្រួសារថ្មីបានកូនស្រីម្នាក់ឈ្មោះ សរ មនិដ។ ក្រោយមកម្តាយខ្ញុំលែងលះគ្នានៅពេលដែលប្អូនស្រីខ្ញុំបានអាយុ១ឆ្នាំ។

នៅក្នុងឆ្នាំ១៩៥៦ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាម៉ាលិកា ក្រុងភ្នំពេញ។ នៅក្នុងឆ្នាំ១៩៦២ ខ្ញុំរៀននៅវិទ្យាល័យយុគន្ធរ។ នៅពេលនោះ បងលីសែបានចុះមកអប់រំខ្ញុំឲ្យចូលរៀនក្នុងក្រុម «សហសិក្សា» នៅពេលវិស្សមកាល និងអប់រំខ្ញុំឲ្យចូលរួមចលនា

ចំរើនៗ នៅក្នុងឆ្នាំ១៩៦៤ លីសែ បានអប់រំ និងវែកញែកប្រាប់ខ្ញុំថា របបសង្គមនិយមពុំមានលក្ខណៈជាតិ ហើយប្រទេសរបបសង្គមនិយមច្រើនតែក្រហាម មានតែប្រទេសសេរី ដែលច្រើនជាប្រទេសសម្បូរសប្បាយមានការហូបចុកគ្រប់គ្រាន់ៗ ក្នុងការអប់រំនោះមានសិស្សចូលរួមចំនួន៤នាក់គឺមាន ថាយ សេរី (នៅស្រុកបារាំង), ហុយ សុត (នៅស្រុកបារាំង) , ជាវ ទាម (ជម្លៀសមិនដឹងទៅទីណា) និង ឡាយ សារីលំដាប់ (ជម្លៀសមិនដឹងទៅទីណា)ៗ នៅក្នុងឆ្នាំ១៩៦៥ លីសែ បានបញ្ចូលយើងទាំង៥នាក់ក្នុងអង្គការ សេ.អ៊ី.អាៗ ទីកន្លែងចូល សេ.អ៊ី.អា នៅផ្ទះរបស់ លីសែ ផ្ទាល់ជាប់នឹងរបងវត្តតាកែវ ក្រុងភ្នំពេញ ដោយមានអ្នកទទួលស្គាល់ឈ្មោះ ហង្ស ធុនហាក់ គឺជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យវិចិត្រសិល្បៈៗ

នៅឆ្នាំ១៩៧០ ខ្ញុំប្រឡងជាប់ជាសាស្ត្រាចារ្យ ហើយចេញបង្រៀននៅវិទ្យាល័យចាក់អង្រែ ក្រុងភ្នំពេញៗ នៅខែតុលា ឆ្នាំ១៩៧០ ខ្ញុំជាប់ឆ្នោតធ្វើជាស្នងការគណនេយ្យ សមាគមមហាវិទ្យាល័យអក្សរសាស្ត្រៗ នៅខែមីនា ឆ្នាំ១៩៧២ មានចលនារបស់យុទ្ធជនចំរើនយ៉ាងគគ្រឹកគគ្រេងប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរៗ បង ម៉ៅ រុនបានណែនាំយើងឲ្យគាំទ្រចលនានោះ ដោយឃោសនាថាតើចាំបាច់ខ្មែរត្រូវការជំនួយពីសហរដ្ឋអាមេរិកទើបអាចច្បាំងតទល់ជាមួយយៀកកុង ឬវៀតណាមខាងជើងបានឬយ៉ាងណាៗ

នៅខែមីនា ឆ្នាំ១៩៧៣ ម៉ៅ រុន បានជំរុញចលនាវាយ លន់ នល់ ព្រោះអង្គការ សេ.អ៊ី.អា មើលឃើញ លន់ នល់ អស់ប្រជាប្រិយភាពក្នុងចំណោមប្រជាជនៗ យើងក៏បានរៀបចំមីទ្ទីញអូស ទាញសិស្ស និស្សិតពីគ្រប់មជ្ឈដ្ឋានៗ នៅក្នុងថ្ងៃធ្វើមីទ្ទីញនេះក្រុម លន់ នល់ ចូលមកគប់គ្រាប់បែកធ្វើឲ្យកងកម្លាំងរបស់យើងបែកខ្ញែកគ្នា ហើយ ម៉ៅ រុន, ឡុប សឿន ត្រូវអង្គការចាប់ខ្លួនៗ ពេលនោះខ្ញុំត្រូវគិញចាប់យកទៅសួរចម្លើយអស់រយៈពេលមួយសប្តាហ៍ទើបដោះលែងវិញ ចំណែកកម្លាំងដែលគេចរួចទៅលាក់ខ្លួននៅជនបទៗ

នៅដើមខែមេសា ឆ្នាំ១៩៧៥ ខ្ញុំ, អៀ ប៉ោលី, ជា ប៉ា បានប្រមូលកម្លាំង សិស្ស និស្សិត បុគ្គលិកសិក្សា មកបោះទីតាំងនៅសាកលវិទ្យាល័យភ្នំពេញ ដោយយកលេសថា មករៀបចំពិធីបុណ្យចូលឆ្នាំខ្មែរៗ យើងបានយកអាវុធចូលទីនោះ ដើម្បីត្រៀមដល់ថ្ងៃកំណត់មានការផ្ទុះបាតុកម្មហែក្បួននៅក្បែរធនាគារជាតិ ដើម្បីការពារមាសកុំឲ្យ លន់ នល់ យកទៅ និងងាយស្រួលកាន់កាប់ក្រសួងឃោសនាការ ដើម្បីប្រកាសអ្នកដឹកនាំថ្មីៗ នៅពេលហែក្បួនទៅដល់ក្រសួងឃោសនាការ យោធា (ខ្មែរក្រហម) បានចូលកាន់កាប់ទីនោះរួចជាស្រេចហើយមិនធ្វើការបរបាញ់ទាំងអស់ៗ ឈ្មោះ សុខ និង វៀង បញ្ជាឲ្យកម្លាំងទាំងអស់ដកខ្លួនថយមកបោះទីតាំងនៅសាលាសន្ធរម៉ុក ហើយចាត់តាំង មុី សំអឿន និង អៀ ប៉ោលី នាំមុខយោធាធ្វើការបោសសម្អាតឆែកឆេរកន្លែងសំខាន់ៗរបស់ក្រុម លន់ នល់ ក្នុងក្រុងភ្នំពេញ ហើយផ្តែផ្តាំឲ្យធ្វើការឲ្យបានល្អដើម្បីឲ្យយោធាខ្មែរក្រហមទុកចិត្តៗ

នៅខែឧសភា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានឈ្មោះ សុខ ចាត់តាំងឲ្យជួយមើលការខុសត្រូវកម្លាំង សិស្ស និស្សិត ដែលនៅសេសសល់ពីការធ្វើការងារនៅរោងចក្រ មន្ទីរ ក្រសួងនានា និង អប់រំកម្លាំងទាំងនោះឲ្យចេះនយោបាយបដិវត្តន៍ អាចជ្រៀតខ្លួនធ្វើការនៅកន្លែងផ្សេងៗៗ នៅខែមិថុនា ឆ្នាំ១៩៧៥ អង្គការដកខ្ញុំឲ្យមកនៅរោងពុម្ពមន្ទីរក-២៥ ដែលនៅទីនោះមានខ្សែខ្ញុំចំនួន៦នាក់ទៀត គឺ៖ ឡុប សឿន ហៅ ជាវ, អ៊ីង អ៊ិត ហៅ អ៊ិត, ពែក អន ហៅ អាំ, ឡៅ មាន ហៅ ឡោម, ប៉ែនម៉ានីល ហៅ ម៉ែន, អៀ ប៉ោលី ហៅ លីនៗ ពេលមកនៅរោងពុម្ព អង្គការឲ្យយើងដើរកត់សម្ភារតាមបណ្ណាគារ ក្នុងក្រុងភ្នំពេញៗ

នៅខែតុលា ឆ្នាំ១៩៧៥ អង្គការចាត់តាំងខ្ញុំ

និង ខ្មែរ ខ្ញុំចំនួន៦នាក់ ឲ្យនៅ ខាងផ្នែកសរសេរការសែត និងរៀបចំបណ្ណាគារ។ នៅខែធ្នូ ឆ្នាំ១៩៧៥ អង្គការបានចាត់តាំងឲ្យក្រុមការសែត មានឈ្មោះ អ៊ិន, ឡោម និងខ្ញុំទៅយកព័ត៌មាននៅខេត្តបាត់ដំបង។ ពេលទៅដល់បាត់ដំបង ខ្ញុំខិតខំស៊ើបរកខ្មែររយៈ ម៉ៅ រុន ដែរប៉ុន្តែមិនបានជួបសោះ។ នៅក្នុងខែឆ្នាំដដែល ពេលចេញទៅរៀបចំបណ្ណាគារ ខ្ញុំ, អ៊ុត និង សែ បានធ្វើឲ្យខូចម៉ាស៊ីនកាត់ក្រដាសអស់ចំនួន២គ្រឿង នៅបណ្ណាគារ ហុងយូ ស្ថិតនៅផ្លូវចន្ទរាជា។

នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ឈ្មោះ ដាវ និងខ្ញុំទាក់ទងកម្មករផ្នែកចាប់អក្សរនៅមន្ទីរក-២៥ ម្នាក់ឈ្មោះគា។ ខ្ញុំក្តាប់បានគឺគាត់ចង់នៅផ្នែកការសែត គាត់មិនចង់នៅផ្នែកចាក់ពុម្ពអក្សរនោះទេ។ យើងទាំងពីរនាក់ឃោសនាកុំឲ្យគាត់សប្បាយចិត្តនឹងអង្គការបដិវត្តន៍រហូតដល់គាត់សុខចិត្តធ្វើការនៅក្នុង សេ.អ៊ី.អា ប្រឆាំងនឹងបដិវត្តន៍។ មិត្តដាវ រាយការណ៍ប្រាប់បង វៀង អំពីការពង្រីកកម្លាំងបង្កប់នៅក្នុងក្រសួងរោងពុម្ពមន្ទីរក-២៥, ក-២៦, ក-២៧ និងរោងពុម្ពមន្ទីរក-២៨។ ពេលត្រឡប់មកវិញ ដាវ ប្រាប់យើងទាំង៦នាក់នៅផ្ទះសម្រាកមន្ទីរក-២៥ អំពីការណែនាំរបស់ វៀង បន្ថែមទៀតគឺ៖១) រិន គួរប្លង់មន្ទីររោងពុម្ពក-២៦, ផល និង លីន គួរប្លង់មន្ទីររោងពុម្ពក-២៨, ចក់ គួរប្លង់មន្ទីររោងពុម្ពក-២៧ និងខ្ញុំគួរប្លង់មន្ទីររោងពុម្ពក-២៥, មិត្តដាវ គួរប្លង់បូរីកី ឡា និងព្រាងប្លង់ប្រព័ន្ធទីតាំងសហជីពពលករ។

នៅខែមីនា ឆ្នាំ១៩៧៦ ឡុច សឿន ហៅ ដាវ បានយកប្លង់ទាំងអស់ដែលបានឲ្យគូរទៅឲ្យ វៀង នៅផ្សារតូច។ ពេល ដាវ ត្រឡប់មកវិញ ដាវ បានឲ្យយើងជួយរកខ្មែរបាត់ដំបងឈ្មោះ ម៉ៅ រុនឲ្យបានឆាប់ដើម្បីរៀបចំទាក់ទងខ្មែរ សេ.អ៊ី.អា ទៅប្រទេសថៃឈ្មោះ ស្រុប រកស៊ីធ្វើជាមេនេសាទ។ នៅខែឧសភា ឆ្នាំ១៩៧៦ អង្គការចាត់តាំងសមាជិកនៅអង្គភាព៣នាក់ រួមទាំងខ្ញុំទៅយកព័ត៌មាននៅបាត់ដំបង ភូមិភាគពាយ័ព្យ។ ពេលខ្ញុំកំពុងថតចម្ការកប្បាស នៅតំបន់៥ ខ្ញុំបានជួប ម៉ែន ភឿន គឺជាខ្មែរបាត់ដំបងរបស់ឈ្មោះ ម៉ៅ រុន។

នៅខែមករា ឆ្នាំ១៩៧៧ ក្រោយអង្គការចាត់តាំងក្រុមខ្ញុំទាំង៧នាក់ រៀបចំមន្ទីរក-៣១ រួចហើយ អង្គការក៏ចាត់វិធានការផ្លាស់ប្តូរមិត្តមួយចំនួនពីមន្ទីររោងពុម្ពដែលធ្លាប់ធ្វើការពីមុនមក។ ពែក អន ហៅ អាំ ផ្លាស់ពីរោងពុម្ព ក-២៧ មកមន្ទីរ ក-២៥ ខាងផ្នែកសរសេរការសែត, ឡុច សឿន ផ្លាស់មកពីមន្ទីររោងពុម្ពក-៣៩ ផ្នែកសរសេរសៀវភៅសិក្សា, ប៉ែន ម៉ានីល ហៅ មែន ផ្លាស់ពីមន្ទីររោងពុម្ពក-២៧ មកមន្ទីររោងពុម្ពក-២៦ ផ្នែកកែកាសែត, អ៊ុង អ៊ុត ផ្លាស់មកពីមន្ទីររោងពុម្ពក-២៥ មករោងពុម្ពមន្ទីរក-៣០ ផ្នែកវប្បធម៌, ឡៅ មាន ហៅ ឡោម ដូរពីផ្នែកម៉ាស៊ីនស្វ័យប្រវត្តិមកផ្នែកសរសេរកាសែត ប៉ុន្តែនៅក្នុងរោងពុម្ព ក-២៥ ដដែល។ នៅពេលនោះ ឡុច សឿន បានទៅកន្លែងខ្ញុំមន្ទីររោងពុម្ពក-២៥ ដោយយកលេសថាមកយកឯកសារខាងភូមិភាគបូព៌ាទៅសរសេរសៀវភៅភូមិសាស្ត្រ។ មិត្តដាវ ប្រាប់ថា ឲ្យកម្លាំងដឹកនាំផ្នែករោងពុម្ព រៀបចំគេចខ្លួនទៅប្រទេសថៃ តាមរយៈ ម៉ែន ភឿន ដែលជាខ្មែរ ខាងបាត់ដំបងធ្វើការនៅពាណិជ្ជកម្មនៅតំបន់៥។ ក្រោយមកទៀត អង្គការបានចាត់តាំងឲ្យក្រុមការសែតដែលមានខ្ញុំនៅក្នុងនោះ ទៅយកព័ត៌មាននៅតំបន់កោះកុង។ ពេលត្រឡប់ពីកោះកុងមកភ្នំពេញវិញ គណៈប្រតិភូបានឆៀងចូលកំពង់សោម ពេលនោះខ្ញុំបានស៊ើបរកឈ្មោះ សោម ក៏បានដឹងថា អង្គការចាប់។ ពេលខ្ញុំត្រឡប់មកដល់មន្ទីរក-២៥វិញ ខ្ញុំរាយការណ៍អំពីការចាប់ខ្លួននេះឲ្យឈ្មោះ ដាវ បានដឹងនៅពេលគាត់មកមន្ទីររបស់ខ្ញុំរករូបថតខាងឆ្លសាន ទៅដាក់នៅសៀវភៅភូមិសាស្ត្រ។

នៅខែមីនា ឆ្នាំ១៩៧៧ ឡុច លឿនមកកន្លែងខ្ញុំយកឯកសារខាងការសែតទៅសរសេរសៀវភៅភូមិសាស្ត្រ ហើយគាត់បានប្រាប់ខ្ញុំថាគាត់បានទៅអគ្គិសនី




ទស្សនាវដ្ដីទង់បដិវត្តន៍។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជង្រារគូបសួរ វៀង កាលណាយើងអាចគេចខ្លួនបានៗ វៀង មានគំនិតផ្ដាល់ថា នឹងរៀបចំថ្ងៃធ្វើរដ្ឋប្រហារ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ ប៉ុន្ដែពុំទាន់បានពិភាក្សាគ្នាទេ។ ខ្ញុំរង់ចាំថ្ងៃគេចខ្លួនរហូតដល់ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៧ អង្គការចាប់ខ្លួនខ្ញុំតែម្ដង។

កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ០០២៩៣។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្ដិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ គុណថុន ថាណារាក់ ហៅពេញ ពិតប្រាកដយ៉ាងណានោះទេ?

# បណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបោះពុម្ពសៀវភៅ សាក្សីប្រវត្តិសាស្ត្រ៖

## កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

*សោម ប៊ុនថន*



ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា នាំយកសៀវភៅសាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចែកជូនប្រជាជនដែលរស់នៅភូមិបាក់នឹម ឃុំច្រេស ស្រុកជុំគិរី ខេត្តកំពត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងឆ្នាំ២០២១ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ព្រះអង្គបានប្រោសព្រះបរមរាជានុញ្ញាតដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការបកប្រែជាផ្លូវការនូវសៀវភៅកំណត់ហេតុរបស់ព្រះអង្គពីភាសាបារាំងទៅជាភាសាអង់គ្លេស ដើម្បីផ្តល់ឱកាសសិក្សាឈ្វេងយល់ដល់អ្នកអានទូទៅឲ្យបានទូលំទូលាយជាងមុន។ មិនតែប៉ុណ្ណោះ សម្តេចព្រះវររាជមាតាជាតិខ្មែរ ព្រះអង្គក៏បានសព្វព្រះរាជហឫទ័យព្រះបរមរាជានុញ្ញាតដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការបកប្រែជាផ្លូវការនូវសៀវភៅកំណត់ហេតុរបស់ព្រះអង្គទៅជាភាសាខ្មែរផងដែរ។ ការបកប្រែជាភាសាខ្មែរនូវព្រះរាជកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី បានបញ្ចប់រួចរាល់ និងបានបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅឆ្នាំ២០២៣ ដែលជាខួប


សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតា
នរោត្ដម មុនិនាថ សីហនុ
នៃព្រះរាជាណាចក្រកម្ពុជា

ជូន លោក ឆាំង យុ

[illegible]

នរោត្ដម មុនិនាថ សីហនុ

ព្រះរាជលិខិតរបស់សម្ដេចព្រះមហាក្សត្រី នរោត្ដម មុនិនាថ សីហនុ ផ្ញើជូនលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អនុស្សាវរីយ៍គម្រប់៥០ឆ្នាំ គិតចាប់តាំងពីកាលដែលសម្ដេចព្រះវររាជមាតាជាតិខ្មែរ ព្រះអង្គបានសព្វព្រះរាជហឫទ័យរាជចំណាររលើសៀវភៅកំណត់ហេតុស្ដីពីព្រះរាជដំណើរជាប្រវត្តិសាស្ត្ររបស់ព្រះអង្គ។

ការបកប្រែជាភាសាខ្មែរចំពោះសៀវភៅកំណត់ហេតុនេះ គឺពិតជាមានសារសំខាន់ចំពោះប្រវត្តិវិទូ និងប្រជាជនកម្ពុជាគ្រប់រូប។ សៀវភៅកំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី គឺជាសំអាងនៃកំណត់ត្រាប្រវត្តិសាស្ត្រដ៏សំខាន់បំផុតពុំអាចកាត់ថ្លៃបាន ពិពណ៌នារយៈកាលដ៏វិសេសវិសាលមួយសម្រាប់ប្រជាជនកម្ពុជាទាំងអស់។

បច្ចុប្បន្នសៀវភៅសាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្ដម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជាភាសាខ្មែរចំនួន


ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង នាំយកសៀវភៅសាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្ដម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចែកជូនប្រជាជនដែលរស់នៅតាមសហគមន៍ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ នាំយកសៀវភៅសាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្ដម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចែកជូនប្រជាជនដែលរស់នៅតាមសហគមន៍ក្នុងខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

៤២៧៦ក្បាល ត្រូវបានបុគ្គលិកបណ្ណាល័យសម្ដេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជានាំយកទៅចែកជូនដល់សាធារណជននៅតាមបណ្ដាខេត្តចំនួន៦។

លោក ឆាំង យុ បានបញ្ជាក់ថា បណ្ណាល័យសម្ដេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជានឹងបោះពុម្ពសៀវភៅ សាក្សីប្រវត្តិសាស្ត្រ៖ កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្ដម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន១សែនក្បាល សម្រាប់ចែកជូនដល់សាធារណជនទូទៅក្នុងរយៈពេល៣ឆ្នាំខាងមុខ។

ប្រសិនបើបងប្អូនត្រូវការសៀវភៅ សាក្សីប្រវត្តិ-សាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ អាចមកយកនៅបណ្ណាល័យសម្តេចម៉ែ ភូមិគ្រឹះលេខ ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬទាក់ទងមកលោក រស់ សំពៅ លេខទូរសព្ទ ០១២ ៨៨២ ៥០៥ ឬ តាមទំព័រ ហ្វេសប៊ុក The Queen Mother Library ។



ក្រុមការងាររមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នាំយកសៀវភៅ សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចែកជូនប្រជាជនដែលរស់នៅតាមសហគមន៍ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសាររមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមការងាររមជ្ឈមណ្ឌលឯកសារកម្ពុជា នាំយកសៀវភៅ សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចែកជូនបងប្អូនជនជាតិខ្មែរ-អ៊ីស្លាម ដែលរស់នៅតាមសហគមន៍ក្នុងសង្កាត់ប្រាំផចំរេះ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ។ (បណ្ណសាររមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមការងាររមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នាំយកសៀវភៅ សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចែកជូនប្រជាជនដែលរស់នៅតាមសហគមន៍ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសាររមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងាររមជ្ឈមណ្ឌលឯកសារកោះថ្ម នាំយកសៀវភៅ សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចែកជូនប្រជាជន សិស្ស និស្សិត គ្រូបង្រៀន ដែលរស់នៅតាមសហគមន៍ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសាររមជ្ឈមណ្ឌលឯកសារកម្ពុជា)





ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា នាំយកសៀវភៅ សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចែកជូនប្រជាជនដែលរស់នៅភូមិបាក់នឹម ឃុំព្រៃស ស្រុកជុំគិរី ខេត្តកំពត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា នាំយកសៀវភៅ សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចែកជូនបងប្អូនជនជាតិខ្មែរ-អ៊ីស្លាម ដែលរស់នៅតាមសហគមន៍ក្នុងសង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នាំយកសៀវភៅ សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចែកជូនប្រជាជនដែលរស់នៅតាមសហគមន៍ក្នុងខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជាពិនិត្យសុខភាពបឋម

## ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិក្តុលលើ

*គីម សុវណ្ណដានី*



ក្រុមការងារគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ពិនិត្យសុខភាពជូនដល់អ្នកភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំចំនួន៩០នាក់ ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបានផ្តល់បទសម្ភាសន៍ដល់អ្នកស្ម័គ្រចិត្តកម្ពុជាដែលចុះសម្ភាសន៍តាំងពីឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាប់ពីថ្ងៃទី១៨, ១៩ និង២០ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាពិនិត្យសុខភាពជូនដល់អ្នកភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំចំនួន៩០នាក់ ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបានផ្តល់បទសម្ភាសន៍ដល់អ្នកស្ម័គ្រចិត្តកម្ពុជាដែលចុះសម្ភាសន៍តាំងពីឆ្នាំ២០២១។ តាមរយៈលទ្ធផលនៃការពិនិត្យសុខភាពរកឃើញជំងឺ៣ប្រភេទចម្បងគឺ៖ ១) ជំងឺលើសឈាម ៩៨ភាគរយ ២) ជំងឺក្រពះពោះវៀន ៥០ភាគរយ ៣) និងជំងឺសន្លាក់ ៤៥ ភាគរយ។ ចំពោះជំងឺទឹកនោមផ្អែមមានតែ១០ភាគរយ ប៉ុណ្ណោះ។

លោកវេជ្ជបណ្ឌិត ដោក រដ្ឋា សង្កេតឃើញថា របបអាហាររបស់អ្នកភូមិក្តុលលើ គឺចូលចិត្តហូបអាហារប្រៃ និងអាហារផ្អាប់ទុកយូរ ដូចជា ផ្អកប្រហុក ជ្រក់ ត្រីប្រឡាក់ និងសាច់ប្រឡាក់ ដែលប្រើ

ប្រាស់អំបិលច្រើន។ បន្ថែមលើនេះ ពេលបរិភោគអាហារអ្នកភូមិភាគច្រើនតែងតែមានបន្ថែមទឹកជ្រលក់ដូចជាទឹកត្រី និង ទឹកស៊ីអ៊ីវជាដើម។ លោកវេជ្ជបណ្ឌិតបានណែនាំឲ្យអ្នកជំងឺផ្លាស់ប្តូររបបអាហារ ដើម្បីជួយពន្លឿនការព្យាបាលឲ្យកាន់តែមានប្រសិទ្ធភាព ព្រោះតាមការពិនិត្យ និងប្រឹក្សាយោបល់ដល់អ្នកជំងឺឃើញថា ទោះបីជាអ្នកជំងឺផឹកថ្នាំទៀងទាត់ក៏សម្ពាធឈាម និងស្ថានភាពជំងឺពុំបានធូរស្បើយឡើយ។ ដូច្នេះហើយទើបលោកវេជ្ជបណ្ឌិតលើកឡើងថា គ្រូពេទ្យបានត្រឹមតែណែនាំ និងចេញវេជ្ជបញ្ជាជូនដល់អ្នកជំងឺ ប៉ុន្តែប្រសិនបើអ្នកជំងឺមិនតមចំណីអាហារដែលពេទ្យហាមឃាត់ ឬក៏ផ្លាស់ប្តូររបបអាហារតាមការណែនាំរបស់ពេទ្យ គឺមិនអាចព្យាបាលជាសះស្បើយទេ។ ជាពិសេស ជំងឺលើសឈាមអាចឈានដល់ការស្លាប់មួយចំហៀងខ្លួន ឬដល់កម្រិតធ្ងន់ធ្ងរ ដែលអ្នកជំងឺត្រូវសម្រាន្តនៅកន្ទេលអស់មួយជីវិត។

ភូមិក្តុលលើ មានប្រជាពលរដ្ឋប្រមាណ៩០ ភាគរយ គឺជាជនជាតិដើមភាគតិចស្ទៀង ដែលប្រកបការងារធ្វើស្រែ, ចម្ការកៅស៊ូ, ចម្ការស្វាយ, ចម្ការម្រេច, ចម្ការទុរេន, ចម្ការសាវម៉ាវ។ ដោយឡែក បន្លែដែលប្រមូលផលឆាប់រួមមាន ពោត និង សណ្តែក តាមរដូវកាល។ តាំងពីយូរលង់ណាស់មក ហើយ ពេលដែលមានជំងឺដង្កាត់ផ្សេងៗ ជនជាតិដើមភាគតិចស្ទៀង តែងតែប្រើវិធីតាមព្រហ្មញ្ញសាសនា ដូចជា សែនអ្នកតា ការបញ្ជូនអារក្ស សំពះគ្រូបាធ្យាយ និងការប្រើវិធីសាស្ត្រអុជព្យាបាលជំងឺ ដែលជនជាតិដើមភាគតិចស្ទៀងហៅថា អណ្តើកអារ៉ុស ពោះកុក។ ការព្យាបាលនេះ គឺតាមការស្មានដោយអុជឲ្យបាត់ឈឺ រួមមាន ឈឺពោះ ចុកពោះ គ្រុនក្តៅខ្លួន ព្រោះពេលដែលឈឺក្នុងពោះមានសភាពរឹងដែលអ្នកជំនាញអុជព្យាបាលហៅថា អណ្តើក។ ពេលដែលអុជរួច គឺសភាពរឹងនោះនឹងបាត់ទៅវិញព្រមគ្នានឹងរោគសញ្ញាផ្សេងៗ ដោយបន្ថែមការដាំថ្នាំស្លឹកឈើ ឬសឈើ សម្បកឈើ។ វិធីសាស្ត្រអុជព្យាបាលនេះគឺប្រើ ធូប ប៉ុយ ខ្សែ សម្បកឬសំឡឹក និងកំប្រោរ ដើម្បីអុជតាមអាការដែលកើតមាន។ ការអុជព្យាបាលជំងឺនេះ គឺអុជម្តុំពោះ និងមានខ្លះទៀតអុជដល់ទ្រូង ហើយការអុជនេះធ្វើឡើងដោយព្រឹទ្ធាចារ្យដែលមានវ័យចំណាស់ និងធ្លាប់មានបទពិសោធន៍តាំងពីដើមមក។ បន្ទាប់ពីអុជរួច គ្រូព្យាបាលជំងឺប្រើដេះ ដើម្បីលាបលើស្នាមអុជកុំឲ្យមានដំបៅ និងឲ្យឆាប់ជ្រុះ។ ចាប់តាំងពីឆ្នាំ២០០០ ជំនឿទាំងនេះ ចាប់ផ្តើមបាត់បង់បន្តិចម្តងៗ ដោយប្រជាជនចាប់ផ្តើមយល់ដឹងអំពីការព្យាបាលតាមវិទ្យាសាស្ត្រសុខាភិបាល ដែលមានប្រសិទ្ធភាពខ្ពស់ជាងការព្យាបាល ដោយប្រើថ្នាំបូរាណ។ បន្ថែមលើនេះទៀត ខាងមន្ទីរសុខាភិបាល មានពេទ្យខេត្ត ពេទ្យស្រុកបានចុះមកជួយពន្យល់ពីការដាក់ថ្នាំកម្ចាត់មូសខ្លា និងការសម្អាតអនាម័យតាមភូមិ ដែលបានជួយកាត់បន្ថយការចម្លងជំងឺគ្រុនឈាម ដោយរដូវនេះជារដូវវស្សា ដែលអាចបង្កើតនូវជម្រកមូសខ្លាបាន ប្រសិនបើមិនមានការយល់ដឹងពីវិធីសាស្ត្របង្ការ។

**ឈម ផាត** អាយុ៣៣ឆ្នាំ ភេទស្រី ត្រូវជាកូនរបស់ នាយ ឈម បានរៀបរាប់ថា ឪពុករបស់គាត់ នាយ ឈម បានទទួលមរណកាលកាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ក្នុងអាយុ៦៨ឆ្នាំ ដោយជំងឺរលាកក្រពះ រលាកសួត និងជំងឺឈាមស ស៊ីឈាមក្រហម។ ឪពុករបស់គាត់បានសម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកំពង់ចាមរយៈពេល១២ថ្ងៃ បន្ទាប់មកវិលត្រឡប់មកព្យាបាលនៅផ្ទះបន្តដោយលេបថ្នាំ។ តាមសម្តីរបស់ ផាត បានឲ្យដឹងបន្ថែមថា ឪពុករបស់គាត់មិនដែលបានពិនិត្យសុខភាពទេ។ ឪពុករបស់គាត់មិនព្រមទៅពិនិត្យសុខភាព និងទទួលការព្យាបាលនៅមន្ទីរពេទ្យទេ គឺឪពុកគាត់បានទិញថ្នាំនៅ ហ្វាម៉ាស៊ីដើម្បីព្យាបាលពេលមានជំងឺក្អកតែប៉ុណ្ណោះ។ ផាត បានបញ្ជាក់បន្ថែមថា ប្រសិនបើឪពុកព្រមទៅទទួលការព្យាបាលតាំងពីឆ្នាំមុន លោកពូនឹងអាចព្យាបាលជា ព្រោះពេទ្យដឹងរោគសញ្ញា និងឲ្យថ្នាំមកត្រូវនឹងជំងឺ។ ផាត មានអារម្មណ៍ត្រេកអរណាស់ដែលបានមកទទួលសេវាពិនិត្យសុខភាព ដោយ ឥតគិតថ្លៃជូនសឪពុក ព្រោះ ផាត មិនធ្លាប់

ដឹងថាខ្លួនមានជំងឺលើសសម្ពាធឈាមទេពីមុនមក។ លោកគ្រូពេទ្យផ្ដល់យោបល់ឲ្យ ផាត ទៅពិនិត្យអេកូបន្ថែមនៅមន្ទីរពេទ្យដើម្បីស្វែងរកពីជំងឺចុករួយជើងទាំងសងខាង។ ក្នុងនោះដែរ ផាត ចាប់អារម្មណ៍ចំពោះចំណីអាហារដែលហូបប្រចាំថ្ងៃ គឺចូលចិត្តសម្លផ្អែម និងភេសជ្ជៈប៉ូវកម្លាំង ដែលអាចមានជំងឺទឹកនោមផ្អែម និងជាកត្តាដែលធ្វើឲ្យ ផាត មានជំងឺលើសឈាម។ ជាចុងក្រោយ ផាត អរគុណដល់ក្រុមការងារ ដែលអនុញ្ញាតឲ្យទទួលសេវាពិនិត្យសុខភាពជំនួសឪពុក និងបានដឹងពីស្ថានភាពសុខភាពរបស់ខ្លួនដោយមិនអស់ថ្លៃសេវាពិនិត្យ និងធ្វើដំណើរទៅមន្ទីរពេទ្យ។

**ម៉ាត់ ភាក់** អាយុ៤១ឆ្នាំ មេភូមិក្តុលលើ មានសេចក្តីត្រេកអរក្រៃលែងដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា រួមទាំង លោកគ្រូអ្នកគ្រូពេទ្យ ដែលបានចុះមកពិនិត្យសុខភាពដល់ប្រជាពលរដ្ឋក្នុងភូមិដល់ទីកន្លែង និងជួយជាថវិកាឧបត្ថម្ភ ដើម្បីឲ្យប្រជាពលរដ្ឋអាចធ្វើដំណើរទៅពិនិត្យសុខភាពបន្ថែមនៅពេលក្រោយ ជាពិសេសប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត។ ការចុះមកពិនិត្យសុខភាពអ្នកភូមិដល់ទីតាំងនេះគឺ ទី១ ជួយដល់អ្នកភូមិបានពិនិត្យសុខភាពដើម្បីព្យាបាល និងថែទាំសុខភាពឲ្យបានល្អប្រសើរ, ទី២ ជួយសម្រួលដល់ការចំណាយថវិកាលើការពិគ្រោះ និងពិនិត្យសុខភាព ក៏ដូចជាការទិញថ្នាំព្យាបាលដល់ប្រជាពលរដ្ឋ និងទី៣ ជួយសម្រួលដល់ការធ្វើដំណើរឆ្ងាយទៅពិនិត្យសុខភាពដែលប្រជាពលរដ្ឋត្រូវចំណាយថវិកាផ្ទាល់ខ្លួន។ ម៉ាត់ ភាក់ គឺជាមេភូមិបង្ហាញការគាំទ្រ និងសំណូមពរដល់មជ្ឈមណ្ឌលឯកសារកម្ពុជាជួយសម្រួលរៀបចំកម្មវិធីពិនិត្យសុខភាពឲ្យបានញឹកញាប់ ដល់ប្រជាពលរដ្ឋដែលមានការខ្វះខាតឲ្យបានយល់ដឹងបន្ថែមពីបញ្ហាថែទាំសុខភាព។

តាមការសាកសួរមតិពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានចូលរួមទទួលសេវាពិនិត្យសុខភាពរយៈពេលពាថ្ងៃនេះ ១) ញឹក ញ៉ាល់ អាយុ ៧៩ឆ្នាំ ភេទប្រុស ២) ចប ម៉ូ អាយុ ៦២ឆ្នាំ ភេទប្រុស ៣) កន សេង អាយុ ៨២ឆ្នាំ ភេទប្រុស និង៤) ឃុល ម៉ូយ អាយុ ៦២ឆ្នាំ ភេទប្រុស គឺមានការសប្បាយចិត្ត និងអរគុណដល់ក្រុមការងារ ក៏ដូចជា លោកគ្រូពេទ្យ អ្នកគ្រូពេទ្យ ដែលបានចំណាយពេលវេលាចុះមក ពិនិត្យសុខភាពដល់ភូមិផ្ទាល់ ដែលបានជួយសម្រួលដល់ការធ្វើដំណើរឆ្ងាយ និងការព្យាបាលនៅមន្ទីរសម្រាកព្យាបាលឯកជន ក៏ដូចជាមណ្ឌលសុខភាពរដ្ឋ។ ជាពិសេស អ៊ំពូមីង ដែលកំពុងតែមានជំងឺស្រាប់បានទទួលសេវាពិនិត្យសុខភាពនៅជិតផ្ទះតែម្តង។ ការពិនិត្យសុខភាពនេះ អ៊ំពូមីង ជឿជាក់ថា នឹងអាចជួយព្យាបាលជំងឺគាត់ឲ្យបានធូរស្បើយ មានស្ថានភាពសុខភាពប្រសើរឡើងវិញ ដោយលោកគ្រូពេទ្យមានបទពិសោធន៍ច្បាស់លាស់ និងបានណែនាំគាត់ឲ្យយល់ដឹងបន្ថែមពីការវិវត្តន៍ធ្ងន់ធ្ងរនៃជំងឺប្រសិនបើមិនមានការព្យាបាលត្រឹមត្រូវ និងទាន់ពេលវេលា។





ក្រុមការងារគម្រោងសុខភាពនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ពិនិត្យសុខភាពជូនដល់អ្នកភូមិក្តុលលើ ឃុំទន្លុង ស្រុកមេមត់ ខេត្តត្បូងឃ្មុំចំនួន៩០នាក់ ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបានផ្ដល់បទសម្ភាសន៍ដល់អ្នកស្ម័គ្រចិត្តកម្ពុជាដែលចុះសម្ភាសន៍តាំងពីឆ្នាំ២០២១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះពិនិត្យសុខភាពបឋម

## ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិកូនក្រពើ

*គីម សុវណ្ណដានី*



កម្មវិធីពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅភូមិកូនក្រពើ ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ភូមិកូនក្រពើ គឺជាភូមិដាច់ស្រយាលជាងគេក្នុងចំណោមភូមិទាំង១៤ ក្នុងឃុំដាំតាម៉ៅ ដែលស្ថិតនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ ជាប់ជាមួយស្រុកស្នួល ខេត្តក្រចេះ ដែលប្រជាជននៅទីនោះប្រើប្រាស់ក្បូនជាមធ្យោបាយធ្វើដំណើរឆ្លងទៅស្រុកស្នួល។

នៅថ្ងៃទី១០ និងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងារនៃគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ចំនួន៣នាក់ មាន៖ គីម សុវណ្ណដានី, ផាត សិលា និង សុខវណ្ណៈ រួមទាំងអ្នកស្ម័គ្រចិត្តកម្ពុជាចំនួន១១នាក់ ដែលរស់នៅឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងវេជ្ជបណ្ឌិត ដោក រដ្ឋា និងគិលានុបដ្ឋាកយិកា ថន ម៉ារី បម្រើការនៅមន្ទីរពេទ្យខេរី ខេត្តត្បូងឃ្មុំ បានចុះទៅពិនិត្យសុខភាពបឋមដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣៧ នាក់ ដែលរស់នៅភូមិកូនក្រពើ ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

ក្រុមការងារបានធ្វើដំណើរពីមជ្ឈមណ្ឌលឯកសារកោះថ្ម លើផ្លូវដែលទើបតែអ៊ុតកៅស៊ូរួចឆ្ពោះទៅសាលាឃុំដាំតាម៉ៅ ក្នុងចម្ងាយប្រហែលជា១៥ គីឡូម៉ែត្រ រួចបន្តដំណើរតាមផ្លូវក្រាលគ្រួសក្រហម ដោយឆ្លងកាត់ភូមិស្រែតាពេជ្រ មុនពេលទៅដល់

ភូមិកូនក្រពើ។ នៅអមសងខាងផ្លូវមានទេសភាពចម្ការកៅស៊ូ និងផ្ទះប្រជាជនស្ថិតនៅទីប្រជុំជនក្នុងភូមិនីមួយៗ។ ប្រជាជននៅក្នុងភូមិកូនក្រពើមិនមានផ្ទះធំទេ និងស្ទើរតែពុំមានផ្ទះសង់អំពីថ្មឬស៊ីម៉ង់ត៍។ ដោយឡែក ក្មេងៗនៅក្នុងភូមិភាគច្រើនមិនបានរៀនចប់ថ្នាក់ទី១២ ហើយមានសិស្សតិចតួចប៉ុណ្ណោះដែលបានរៀនបន្តថ្នាក់អនុវិទ្យាល័យ។ សិស្សមួយចំនួនឈប់រៀនមកជួយធ្វើស្រែចម្ការឪពុកម្ដាយ ដោយសារតែជីវភាពខ្វះខាត។

នៅអំឡុងពេលពិនិត្យសុខភាព ក្រុមការងារនៃគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» រកឃើញថា អ្នកភូមិទាំងប្រុសទាំងស្រីដែលចូលរួមពិនិត្យសុខភាពមានបញ្ហាលើសឈាម៩៨ភាគរយ ដោយសារអ្នកភូមិមិនសូវបានយកចិត្តទុកដាក់លើការថែទាំសុខភាព។

វេជ្ជបណ្ឌិត ដោក រដ្ឋា គឺជាប្រធានផ្នែកវះកាត់ជំនាញវះកាត់ទូទៅបានផ្ដល់ការណែនាំដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិកូនក្រពើ ក្រោយពីការពិនិត្យសុខភាពបឋមរួចរាល់ ដោយសារចំនួនអ្នកមានជំងឺលើសឈាមមានច្រើន និងមានអ្នកជំងឺសម្ពាធឈាមឡើងខ្ពស់ក៏ច្រើន។ វេជ្ជបណ្ឌិតបានណែនាំឲ្យអ្នកជំងឺឲ្យផ្លាស់ប្ដូររបបអាហារ គឺតមហូបប្រៃ, ផ្អាកឬកាត់បន្ថយការផឹកស្រា និងជក់បារី។ បន្ថែមលើនេះទៀត អ្នកជំងឺត្រូវផឹកថ្នាំលើសសម្ពាធឈាមឲ្យបានទៀងទាត់ ថែមទាំងត្រូវទៅពិនិត្យសម្ពាធឈាមយ៉ាងហោចណាស់ឲ្យបានម្ដងក្នុងមួយខែនៅមណ្ឌលសុខភាពដែលនៅក្បែរគាត់ ដើម្បីតាមដាន និងព្យាបាលឲ្យបានត្រឹមត្រូវ។ ឧទាហរណ៍ថា ថ្ងៃនេះគាត់ត្រូវប្រើថ្នាំត្រឹមកម្រិតលេខ៥ ប៉ុន្តែសម្ពាធឈាមរបស់អ្នកជំងឺនៅតែខ្ពស់ វេជ្ជបណ្ឌិតនៅមណ្ឌលសុខភាពនឹងបន្ថែមកម្រិតថ្នាំជូនអ្នកជំងឺដើម្បីឲ្យរក្សាសម្ពាធឈាមឲ្យបានល្អ។ ផ្ទុយទៅវិញ ប្រសិនបើសម្ពាធឈាមរបស់អ្នកជំងឺបានល្អ ឬថយចុះ វេជ្ជបណ្ឌិតនឹងបន្ថយកម្រិតថ្នាំដល់អ្នកជំងឺដើម្បីរក្សាសម្ពាធឈាមឲ្យបានល្អដូចគ្នា។ ករណីជំងឺលើសឈាមដែលបានរកឃើញលើអ្នកភូមិកូនក្រពើក្រោយពីបានសួរនាំពីរបបអាហារ អ្នកជំងឺភាគច្រើនផឹកស្រា ជក់បារី និងហូបអាហារដែលមានសារជាតិប្រៃខ្លាំងដូចជា ត្រីឬ សាច់ប្រឡាក់ និងអាហារផ្អាប់ដូចជា ប្រហុក ផ្អក និងម៉ាំជាដើម។

ក្នុងកំឡុងពេល៣សប្តាហ៍កន្លងមកនេះ មានការរីករាលដាលនៃជំងឺគ្រុនឈាម ជំងឺគ្រុនពោះវៀន និងជំងឺផ្ដាសាយនៅក្នុងភូមិ ក្នុងនោះអ្នកដែលរងគ្រោះខ្លាំងគឺក្មេងៗនៅក្នុងភូមិ មានអាការក្ដៅខ្លួនខ្លាំងរហូតត្រូវបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យឯកជន



កម្មវិធីពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅភូមិកូនក្រពើ ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដែលនៅជិត និងព្យាបាលដោយការព្យួរសេរ៉ូមៗ ដោយមើលឃើញថា មានការចម្លងជំងឺគ្រុនឈាមច្រើន ហើយខែនេះគឺជារដូវវស្សាដែលមានភ្លៀងធ្លាក់ និងដក់ទឹកដែលជាជម្រកនៃមូសខ្លា វេជ្ជបណ្ឌិត ដោក រដ្ឋា បានផ្តល់ជាការណែនាំឲ្យប្រជាជនដេកនៅក្នុងមុង មិនថាមនុស្សចាស់ ឬក្មេងឡើយ ព្រោះជំងឺគ្រុនឈាមកើតលើមនុស្សគ្រប់វ័យ ទាំងអស់។

ជារួមការពិនិត្យសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលរស់នៅភូមិកូនក្រពើ ចំនួន ៣៧ នាក់ វេជ្ជបណ្ឌិត ដោក រដ្ឋា បានរកឃើញអ្នកជំងឺអស់កម្លាំង៦នាក់, វិលមុខ៦នាក់, រលាកក្រពះ១០នាក់, រលាកសន្លាក់១នាក់, លើសឈាម១៥នាក់, ក្អក១នាក់, រលាកសួត១នាក់, រលាកផ្លោកនោម១នាក់, ឈឺចង្កេះ១នាក់ និងទឹកនោមផ្អែម១នាក់។ ក្នុងចំណោមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំង ៣៧ នាក់ គឺដេកមិនសូវលក់នៅពេលយប់។

**លោក ជឹម លឹម** មានអាយុ៥១ឆ្នាំ គឺជាមេភូមិកូនក្រពើ ដែលបានសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងជួយរៀបចំកម្មវិធីដើម្បីពិនិត្យសុខភាពបឋមដល់អ្នកភូមិកូនក្រពើ មានប្រសាសន៍ថា គាត់ត្រេកអរណាស់ ព្រោះកន្លងមកក្រៅពីរដ្ឋាភិបាលពុំដែលមានអង្គការក្រៅរដ្ឋាភិបាលចុះមកអប់រំពីការថែទាំសុខភាពដល់ភូមិផ្ទាល់បែបនេះទេ។ គាត់បន្តថា ដោយសារភូមិកូនក្រពើគឺជាភូមិនៅដាច់ស្រយាល ហើយផ្លូវធ្វើដំណើរពិបាក ទើបមិនមានអ្នកចុះមកជួយអប់រំអំពីការថែទាំសុខភាពដល់អ្នកភូមិ ហើយសូម្បីតែសាលារៀនដែលមានតាំងពីទសវត្សរ៍ឆ្នាំ៩០ ក៏មិនសូវមានគ្រូបង្រៀនដែរ ដែលជាមូលហេតុធ្វើឲ្យក្មេងៗជំនាន់ក្រោយដែលរស់នៅក្នុងភូមិនេះមិនបានសិក្សារៀនសូត្របានខ្ពង់ខ្ពស់។

**លោក ឆាង តា** មានអាយុ៦០ឆ្នាំ រស់នៅភូមិកូនក្រពើ មានប្រសាសន៍ថា ភូមិកូនក្រពើចាប់ផ្តើមមានសាលារៀនតាំងពីឆ្នាំ១៩៩១ ប៉ុន្តែមិនមានគ្រូបង្រៀនទេ គឺមានតែមនុស្សចាស់នៅក្នុងភូមិដែលចេះ អក្សរជួយបង្រៀនក្មេងជំនាន់ក្រោយឲ្យត្រឹមតែចេះអានតិចតួចប៉ុណ្ណោះ។ រហូតដល់ឆ្នាំ២០១១ ទើបមានគ្រូបង្រៀន ប៉ុន្តែនៅតែខ្វះខាត និងមិនបានបង្រៀនគ្រប់គ្រាន់ទេដោយសារលោកគ្រូអ្នកគ្រូត្រូវធ្វើដំណើរពីទីរួមស្រុកមេមត់មកបង្រៀននៅភូមិដែលមានចម្ងាយប្រមាណ៣៥គីឡូម៉ែត្រ។ ចំពោះកម្មវិធីពិនិត្យសុខភាពដល់ប្រជាជនក្នុងភូមិរយៈពេល២ថ្ងៃនេះ គឺគាត់មានការត្រេកអរព្រោះមានវេជ្ជបណ្ឌិតចុះមកពិនិត្យសុខភាពជូនគាត់ផ្ទាល់។ គាត់បានពិគ្រោះ និងពិនិត្យជំងឺដោយមានការធ្វើរោគវិនិច្ឆ័យត្រឹមត្រូវដោយវេជ្ជបណ្ឌិតជំនាញច្បាស់លាស់ និងទទួលបានវេជ្ជបញ្ជាដើម្បីទិញថ្នាំដឹកព្យាបាលជំងឺបានត្រឹមត្រូវ។ គាត់បានស្នើឲ្យមានការចុះមកពន្យល់ពីការថែទាំសុខភាពដល់អ្នកភូមិដើម្បីឲ្យអ្នកភូមិមានសុខភាពល្អប្រសើរជាងមុន។

**យាយ ព្រុំ ទូច** អាយុ៧៨ឆ្នាំ មានអាការញ័រខ្លួនវិលមុខ យូឆ្នាំមកហើយ ប៉ុន្តែដោយសារ គាត់មានជីវភាពក្រក្រី គាត់មិនបានទៅពេទ្យដើម្បីពិនិត្យសុខភាពឡើយ ប៉ុន្តែក្រោយពីបានទទួលការពិនិត្យសុខភាពដោយវេជ្ជបណ្ឌិតដែលមានជំនាញច្បាស់លាស់ បានធ្វើរោគវិនិច្ឆ័យជូនគាត់ និងបានចេញវេជ្ជបញ្ជាឲ្យគាត់ទិញថ្នាំ គាត់នឹងធ្វើតាមការណែនាំរបស់គ្រូពេទ្យដើម្បីគាត់មានអាយុវែង និងមានសុខភាពល្អឡើងវិញ។ គាត់បន្ថែមទៀតថា បន្ទាប់ពីបានជួបពិគ្រោះ និងពិនិត្យសុខភាពថ្ងៃនេះរួច គាត់ជឿជាក់ថាគាត់នឹងដេកលក់ស្រួល។ គាត់សូមជូនពរដល់ក្រុមការងារឲ្យបានជោគជ័យគ្រប់ភារកិច្ច និងមានសុខភាពល្អ។



កម្មវិធីពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅភូមិកូនក្រពើ ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រំភើបចិត្ត ពេលឃើញសម្តេចម៉ែ

## ផេង ពងរ៉ាស៊ី



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥នាក់ក្នុងចំណោម៧នាក់ ដែលកំពុងស្នាក់នៅក្នុង «មជ្ឈមណ្ឌលថែទាំមនុស្សចាស់ជរាគ្មានទីពឹង» នៅក្នុងបរិវេណវត្តសីម្ពលីព្រឹក្សារការជួរ ស្ថិតនៅក្នុងភូមិរការជួរ ទី១ ឃុំបន្ទាយចក្រី ស្រុកព្រះស្ដេច ខេត្តព្រៃវែង ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់ព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ពីក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ចំនួន៥ក្បាល ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៥នាក់ក្នុងចំណោម៧នាក់ ដែលកំពុងស្នាក់នៅក្នុង «មជ្ឈមណ្ឌលថែទាំមនុស្សចាស់ជរាគ្មានទីពឹង» នៅក្នុងបរិវេណវត្តសីម្ពលីព្រឹក្សារការជួរ ស្ថិតនៅក្នុងភូមិរការជួរ ទី១ ឃុំបន្ទាយចក្រី ស្រុកព្រះស្តេច ខេត្តព្រៃវែង។ អ្នកទាំង៥នាក់មានឈ្មោះ៖

១) អ៊ុក អេង ភេទស្រី អាយុ៨៩ឆ្នាំ គឺជាស្ត្រីមេម៉ាយ គ្មានកូនចិញ្ចឹម។

២) នូ ថន ភេទស្រី អាយុ៥៥ឆ្នាំ គ្មានប្តី សាច់ញាតិ និងបងប្អូនចិញ្ចឹម។

៣) ពុធ ធារី ភេទស្រី អាយុ៦៨ឆ្នាំ គ្មានប្តី សាច់ញាតិ និងបងប្អូនចិញ្ចឹម។

៤) ញ៉ាញ់ យោ ភេទស្រី អាយុ៦៣ឆ្នាំ គ្មានប្តី សាច់ញាតិ និងបងប្អូនចិញ្ចឹម។

៥) សុខ ទូច ភេទស្រី អាយុ៥៤ឆ្នាំ គឺជាស្ត្រីមេម៉ាយ និងមានកូនតូចពិការសតិបញ្ញា។

អ្នកទាំង៥នាក់ បានសម្តែងអារម្មណ៍រំភើបរីករាយ និងបានបើកសៀវភៅនេះអាន ព្រមទាំងពិនិត្យមើលរូបថតដែលពួកគាត់ពុំធ្លាប់បានឃើញពីមុនមក។

ក្នុងចំណោមអ្នកទាំង៥នាក់មានតែពុធ ធាវី និង សុខ ទូច ប៉ុណ្ណោះដែលចេះអានអក្សរ។

**អ៊ុក រអេង** បានប្រាប់ថា គាត់បានឃើញសម្តេចម៉ែម្តងទៀតហើយ តាមរយៈរូបថតព្រះអង្គនៅក្នុងសៀវភៅនេះ។ អេងរំភើបចិត្តណាស់ព្រោះគាត់គោរព និងស្រឡាញ់សម្តេចម៉ែ តាំងពីគាត់មានអាយុ១៧ឆ្នាំមកម្ល៉េះ។ អេង និយាយដូច្នេះថា «ខ្ញុំធ្លាប់ឃើញ និងបានសំពះសម្តេចម៉ែបានពីរដង គឺក្នុងពេលដែលខ្ញុំទៅចូលរួមមើលពិធីអុំទូកសំពះព្រះខែ កាលពីខ្ញុំមានអាយុ១៧ឆ្នាំ។ សម្តេចម៉ែស្អាតណាស់ ហើយទន់ភ្លន់ គួរឲ្យគោរពស្រឡាញ់ណាស់។ ខ្ញុំស្រឡាញ់សម្តេចម៉ែណាស់។ ខ្ញុំមិនដែលបានជួប និងឃើញសម្តេចម៉ែទៀតទេ រហូតមកដល់ពេលនេះ។ ឥឡូវ ខ្ញុំបានព្រះអង្គគង់នៅជាមួយហើយ ព្រោះខ្ញុំមានសៀវភៅនេះ! ព្រោះនៅក្នុងសៀវភៅនេះមានរូបសម្តេចម៉ែដែលខ្ញុំស្រឡាញ់»។ តាំងពីក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ មក អេង លែងបានដឹងពីដំណឹងសម្តេចម៉ែទៀតហើយ ព្រោះគាត់ត្រូវរស់នៅក្នុងតំបន់រំដោះខ្មែរក្រហម។ ក្នុងរបបខ្មែរក្រហម អេង គឺជាអ្នកចែកបាយនៅក្នុងរោងបាយ។ ក្រោយឆ្នាំ១៩៧៧ អេង ត្រូវបានជម្លៀសទៅកាន់ភូមិតាម៉ៅ ក្នុងស្រុកពាមជរ គឺជាកន្លែងដែលគាត់បានដឹងពីការសម្លាប់មនុស្សយ៉ាងច្រើននៅទីនោះ។ ក្រោយឆ្នាំ១៩៧៩ អេង បានមករស់នៅក្នុងស្រុកកំណើតវិញ គឺភូមិរកាជួរ ឃុំបន្ទាយចក្រី ស្រុកព្រះស្តេច ខេត្តព្រៃវែង។ នៅខែកក្កដា ឆ្នាំ២០២៣នេះ អេង ត្រូវបានជ្រើសរើសឲ្យមកស្នាក់នៅក្នុង «មជ្ឈមណ្ឌលថែទាំមនុស្សចាស់ជរាគ្មានទីពឹង» ស្ថិតនៅក្នុងបរិវេណវត្តសីម្ពលីព្រឹក្សា។

**នួ ថន** បានបង្ហាញពីអារម្មណ៍រីករាយពេលដែលគាត់ទទួលបានសៀវភៅនេះ។ ថន មិនដែលបានជួបសម្តេចម៉ែពីមុនមកទេ ប៉ុន្តែគាត់មានបំណងប្រាថ្នាជាយូរមកហើយថា ចង់ជួបសម្តេចម៉ែដោយផ្ទាល់ខ្លាំងណាស់។ ឥឡូវនេះ គាត់ទទួលបានសៀវភៅដែលជាស្នាព្រះហស្តដោយផ្ទាល់របស់សម្តេចម៉ែ ពីកំណត់ហេតុរបស់ព្រះអង្គ ក្នុងដំណើរយាងមកកាន់ប្រទេសកម្ពុជា ឆ្លងកាត់ផ្លូវដ៏គ្រោះថ្នាក់គឺផ្លូវលំហូជីមិញ។ ថន តែងតែញញឹមពេលដែលគាត់បើកសន្លឹកសៀវភៅនេះឃើញរូបថតស-ខ្មៅដែលមានព្រះភក្ត្រ និងព្រះរាជសកម្មភាពរបស់សម្តេចម៉ែ។ ថន និយាយដូច្នេះថា «ខ្ញុំមិនចេះអានអក្សរទេ។ ខ្ញុំធំដឹងក្តីឡើងក្នុងរបបខ្មែរក្រហម ដូច្នេះខ្ញុំមិនបានរៀនសូត្រទេ។ ខ្ញុំស្រឡាញ់សៀវភៅនេះណាស់ ទោះបីជាខ្ញុំមិនចេះអានអក្សរក៏ដោយ ព្រោះថាខ្ញុំអាចមើលឃើញរូបថតសម្តេចម៉ែរាល់ពេលដែលខ្ញុំចង់ឃើញព្រះអង្គ។ ពេលទំនេរពីការងារ ខ្ញុំនឹងស្នើសុំឲ្យបង (ធាវី) អានឲ្យខ្ញុំស្តាប់ម្តងមួយសន្លឹកៗ។ ខ្ញុំនឹងថែរក្សាសៀវភៅនេះឲ្យល្អ។ ពេលយប់ឡើង ខ្ញុំនឹងបើកវា ដើម្បីមើលរូបថតសម្តេចម៉ែ»។

**ពុធ ធាវី** អង្គុយនៅក្បាលគុហើយអានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដោយមិនខ្វល់ពីអ្នកឯទៀតឡើយ។ គាត់អានឮៗ ហើយអ្នកឯទៀតស្តាប់ផងមើលសៀវភៅដែលជាកម្មសិទ្ធិរបស់ខ្លួនផង។ ធាវីបានប្រាប់ថា គាត់ធ្លាប់តែមើលឃើញសម្តេចម៉ែតាមទូរទស្សន៍។ គាត់មិនដែលបានជួបសម្តេចម៉ែពីមុនមកទេ។ ធាវី



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥នាក់ក្នុងចំណោម៧នាក់ ដែលកំពុងស្នាក់នៅក្នុង «មជ្ឈមណ្ឌលថែទាំមនុស្សចាស់ជរាគ្មានទីពឹង» នៅក្នុងបរិវេណវត្តសីម្ពលីព្រឹក្សារកាជួរ ស្ថិតនៅក្នុងភូមិរកាជួរ ទី១ ឃុំបន្ទាយចក្រី ស្រុកព្រះស្តេច ខេត្តព្រៃវែង ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់ព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ពីក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

និយាយថា សៀវភៅនេះស្រួលអាន និងងាយស្រួលយល់ណាស់ ជាពិសេសកំណត់ហេតុប្រចាំថ្ងៃនីមួយៗរបស់សម្តេចម៉ែ។ ក្នុងពេលជួបជាមួយក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជារយៈពេលជាង់មួយម៉ោង ធារី អានសៀវភៅនេះរហូត។ គាត់បានចាប់ផ្តើមអានពីសន្លឹកទំព័រទី១៧ អានបណ្តើរ មើលរូបថតបណ្តើររហូតដល់ចប់ផ្នែកទី១នៃសៀវភៅនេះ។ យើងមិនបាននៅស្តាប់ ធារី អានតទៅទៀតទេ ព្រោះដល់វេលាល្ងាចណាស់ទៅហើយ ហើយម្យ៉ាងទៀត ពួកគាត់ទាំង៥នាក់ ក៏ដល់ពេលពិសាអាហារពេលល្ងាចដែរ។ ពេលជូនដំណើរយើងមកវិញ ធារី បានប្រាប់ថា «ខ្ញុំនឹងអានសៀវភៅនេះឲ្យចប់»។

**ញ៉ាញ់ យោ** និង សុខ ទូច មិនមាត់កអ្វីទាំងអស់ក្រៅពីអានសៀវភៅ និងមើលរូបថតក្នុងសៀវភៅ។ យោ មិនចេះអានអក្សរដូច ថន និងអេង ដែរ។ ទូច បាននិយាយថា គាត់នឹងអានសៀវភៅនេះនៅពេលយប់ ពេលដែលកូនតូចពិការរបស់គាត់ដេកលក់។ អ្នកទាំងពីរ ថ្វីត្បិតតែមិនចេញស្តីអ្វីច្រើនក៏ពិតមែន ប៉ុន្តែគាត់បានបង្ហាញពីអារម្មណ៍សប្បាយរីករាយនៅពេលដែលគាត់បានឃើញរូបថតជាច្រើនសន្លឹក ជាពិសេសរូបថតសម្តេចម៉ែ នៅក្នុងសៀវភៅនេះ។ ទូច បានប្រាប់យើងពេលជូនដំណើរយើងត្រឡប់មកវិញថា គាត់នឹងកាន់សៀវភៅនេះទៅឲ្យកូននេន (ព្រះសង្ឃ) អានឲ្យស្តាប់។

សូមបញ្ជាក់ថា ការធ្វើដំណើរទៅកាន់ «មជ្ឈ-មណ្ឌលថែទាំចាស់ជរាគ្មានទីពឹង» គឺដើម្បីសួរសុខទុក្ខ ជូនដំណឹងពីកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹងការថែទាំសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសម្រួលដល់ការសហការការងាររវាងមជ្ឈមណ្ឌលឯកសារកម្ពុជា សាខាខេត្តព្រៃវែង និងមជ្ឈមណ្ឌលថែទាំមនុស្សចាស់ជរាគ្មានទីពឹង ទាក់ទងនឹងការចែករំលែកបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម និងការអប់រំដល់ក្មេងៗជំនាន់ក្រោយពីប្រវត្តិសាស្ត្រខ្មែរក្រហម។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៥នាក់ក្នុងចំណោម៧នាក់ ដែលកំពុងស្នាក់នៅក្នុង «មជ្ឈមណ្ឌលថែទាំមនុស្សចាស់ជរាគ្មានទីពឹង» នៅក្នុងបរិវេណវត្តសីម្ពលីព្រឹក្សារការជួរ ស្ថិតនៅក្នុងភូមិរការជួរទី១ ឃុំបន្ទាយចក្រី ស្រុកព្រះស្តេច ខេត្តព្រៃវែង ទទួលសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់ព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» ពីក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការ នៅក្នុងភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ

ទី ស៊ីថា

## កិ ផាន់



ខ្ញុំឈ្មោះ កិ ផាន់ ភេទប្រុស អាយុ៨៥ឆ្នាំ។ ខ្ញុំមានទីកន្លែងកំណើតនៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុកឈ្មោះ កិ គាត់បានស្លាប់ និងម្តាយ ឈ្មោះ សាន់ ក៏ស្លាប់ដែរ។ ខ្ញុំមានបងប្អូនចំនួន៤នាក់។ ប្រពន្ធខ្ញុំមុនឈ្មោះ ខ្សូយ ស្លាប់ដោយសារគេបាញ់។ នៅថ្ងៃនោះខ្ញុំមិនស្រួលខ្លួន មេឃងងឹតរកភ្លៀង ខ្ញុំបានឲ្យប្រពន្ធកោសខ្យល់ឲ្យខ្ញុំ ស្រាប់តែមិនដឹងមានជនខិលខូចមកពីណាលួចបាញ់ចំប្រពន្ធខ្ញុំស្លាប់ភ្លាមៗ។ ក្រោយមកខ្ញុំមានប្រពន្ធម្នាក់ទៀត ឈ្មោះ ផាត់ វេ មានអាយុ ៦៩ឆ្នាំ គឺជាអ្នកស្រុកកៀនស្វាយ ខេត្តកណ្តាល។ ប្រពន្ធទី២ខ្ញុំមានកូនប្រុសម្នាក់។

កាលពីកុមារខ្ញុំធ្លាប់បានសិក្សារៀនសូត្រ ត្រឹមថ្នាក់ទី២នៅ សាលាក្តុល។ ខ្ញុំអាចសរសេរ និង អានបានពេលចូលដល់សម័យខ្មែរក្រហមក្មេងៗ ត្រូវខ្មែរក្រហម ហាមមិនឲ្យរៀន ហើយវត្តអារាមត្រូវ បិទ និងផ្សឹកលោកសង្ឃ។ ខ្មែរក្រហមជម្លៀសខ្ញុំដំបូងទៅស្នួលហើយធ្វើការទាំងយប់ថ្ងៃគ្មានពេលសម្រាក។ ខ្ញុំត្រូវងើបទៅធ្វើការតាំងពីម៉ោង៦:០០ព្រឹកដល់ ១២:០០ថ្ងៃត្រង់បានឈប់សម្រាកហូបបបរ។ ពេលដែលហូបហើយចុះទៅធ្វើការវិញទាល់តែម៉ោង៥បានឡើង រួចម៉ោង៨:០០-៩:០០យប់ទើបបានហូបបបរ។

ខ្ញុំធ្លាប់ឃើញខ្មែរក្រហមយកមនុស្សទៅវាយទម្លាក់ទឹកអណ្តូងដោយសារតែច្រៀងចម្រៀងមិនមែនបទបដិវត្តន៍។ ពេលយប់តែងមានកងឈ្លបមកលួចស្តាប់ពីក្រោមផ្ទះ ដើម្បីលួចមើលខ្លាចមានប្រជាជនណាលួចដាំបាយបុ និយាយអ៊ីពីអង្គការ ឈ្លបនោះរាយការណ៍ទៅថ្នាក់លើ រួចចាប់យកទៅវាយចោលតែម្តង។ ខ្មែរក្រហមបានជម្លៀសខ្ញុំទៅម្ចិចមាន់ហើរ ឲ្យធ្វើស្រែចម្ការបានពីរទៅបីថ្ងៃ បន្ទាប់មកខ្មែរក្រហមឲ្យដើរទៅមុខទៀតរហូតទៅដល់ស្ពឹងត្រង់។ នៅទីនោះបានប្រហែលរយៈពេល១ខែ ខ្ញុំឮដំណឹងថាប្រជាជននៅស្រុកណាសូមធ្វើដំណើរត្រឡប់ទៅស្រុកនោះវិញ។ យើងក៏ធ្វើដំណើរត្រឡប់មកវិញ ពេលធ្វើដំណើរមកដល់ក្តុលក៏ឈប់សម្រាករយៈពេលប្រាំយប់សិន ដើម្បីឲ្យក្រុមដោះមីនស្វែងរកគ្រាប់មីននៅក្នុងភូមិក្តុលលើរួចបានចូលមករស់នៅ ហើយបានធ្វើស្រែចម្ការចិញ្ចឹមជីវិតរហូតមកដល់សព្វថ្ងៃ។

## ផាត់ វេ



ខ្ញុំឈ្មោះ ផាត់ វេ ភេទស្រី អាយុ៦៩ឆ្នាំ។ ខ្ញុំមានទីកន្លែងកំណើតនៅក្នុងភូមិចន្លក់ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។ បច្ចុប្បន្នខ្ញុំរស់នៅក្នុងភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុកឈ្មោះ មាន់ ផាត់ និងម្ដាយ ឈ្មោះ ស៊ិក សុខ។ ខ្ញុំមានបងប្អូនចំនួន៦នាក់ប៉ុន្តែសព្វថ្ងៃនៅរស់តែ២នាក់។

កាលពីកុមារខ្ញុំចូលរៀននៅសម័យសម្ដេចឪ រៀនត្រឹមថ្នាក់ទី១២។ រៀនតែ ក ខ ពេញមួយឆ្នាំ គ្រូបង្រៀនឈ្មោះ សុខុម និង ស៊ីស្វា។ ខ្ញុំឈប់រៀនដោយសារតែជីវភាពខ្វះខាត ឪពុកខ្ញុំស៊ីឈ្នួលបោសសម្អាតនៅមន្ទីរពេទ្យ ដើម្បីដោះដូរយកអង្ករចិញ្ចឹមកូនៗ។ ពេលខ្ញុំមានអាយុ១៦ទៅ១៧ឆ្នាំ មានរដ្ឋប្រហារ លន់ នល់ ហើយមិនបានធ្វើនៅក្នុងភូមិទេគឺទៅធ្វើនៅព្រែកឯង។ បងប្រុសខ្ញុំទី១ឈ្មោះ ផាត់ សែម ឬ សែប ញិល ធ្វើជាទាហានជំនាន់សម្ដេចឪ បានទៅចូលរួមធ្វើបាតុកម្មជាមួយគេដែរ តែមិនបានត្រឡប់មកផ្ទះវិញទេ។ បងថ្លៃខ្ញុំនៅខេត្តស្វាយរៀងបានទៅនៅក្នុងបន្ទាយតួកី បានបបួលប្ដីរបស់ខ្ញុំទៅធ្វើជាទាហាននៅទីនោះ។ ពេលនោះខ្ញុំឃើញបងថ្លៃកាន់កាំភ្លើង M105 និង M115។ បន្ទាប់មកប្ដីខ្ញុំក៏បានទៅដែរ ប៉ុន្តែប្ដូរទៅជាបងថ្លៃខ្ញុំជាអ្នកបើកឡាន ហើយប្ដីនិងប្អូនរបស់ខ្ញុំជាអ្នកលើកដីដាក់ឡាន។ យប់មួយមកដល់អ្នកក្នុងភូមិនាំគ្នារត់ចេញពីផ្ទះទៅនៅក្នុងព្រៃអស់ នៅផ្ទះខ្ញុំដេកមិនដឹងខ្លួនទាល់តែប្អូនជីដូនមួយរបស់ខ្ញុំមកទាត់ទ្វារផ្ទះឲ្យក្រោក ហើយនិយាយថា ឆាប់រត់ចេញពីភូមិ។ ក្រុមគ្រួសារខ្ញុំបានជិះទូកកាត់យប់ទៅដល់ភូមិកោះចាស់ដែលនៅជុំវិញសុទ្ធតែទឹកទន្លេ។ នៅទីនោះមានចំនួន៣គ្រួសារគឺ គ្រួសារបងស្រី បងបន្ទាប់ និងគ្រួសារខ្ញុំមានឪពុកម្ដាយ។ មុខរបរពេលរស់នៅកោះចាស់ស្ថិតក្នុងឃុំដីឥដ្ឋ ដាំបន្លែរកត្រី ធ្វើចំការ ដាំត្រសក់ សណ្ដែកគួរ។ វៀតកុងឬវៀតណាមខាងជើង ចូលមកវាយជាមួយទាហានលន់ នល់ ពេលនោះខ្ញុំនៅចូលរួមពិធីមង្គលការចៅ។ ពួកវៀតកុងបានចូលបន្លំខ្លួននៅក្នុងពិធីមង្គលការនោះនៅកោះស្លាកែតស្ថិតក្នុងភូមិចម្ងក់។ កម្មវិធីការចប់សព្វគ្រប់ ហើយគ្រួសារខ្ញុំបានទៅនៅបន្ទាយទាហានតួគី ប្រជាជននៅទីនោះភាគច្រើនមានពាក្យស្លោកមួយហើយម្ដាយក៏និយាយប្រាប់កូនចៅដែរថា «កោះស្លាកែតបាំងដៃមើល» ដោយសារតែកោះនេះតាំងពីសម័យមុនៗមិនដែលមានសង្គ្រាមទេ គឺជៀសវាងរហូត។ ចាស់ក្នុងភូមិច្រើននិយាយថា« ព្រេងនគរធំរលំ ភ្នំពេញរលាយ បាត់ដំបងខ្ចាត់ខ្ចាយ សប្បាយអង្គរវត្ត ដើមរការរលំស្រីដណ្ដើមប្រុស» ។ នៅក្នុងភូមិមានកម្លាំង៣កម្រិតគឺ កម្លាំងស្រួចមាន ស្ត្រីមេម៉ាយឬកម្លាំងនារី, កម្លាំងកណ្ដាល និងកម្លាំងមនុស្សចាស់។ ពេលធ្វើការខ្មែរក្រហមហាមមិនឲ្យច្រៀង បទលោកកីទេ ច្រៀងបានតែចម្រៀងបដិវត្តន៍ប៉ុណ្ណោះ។

នៅស្រែអំបិល ប្រជាជនស្លាប់ច្រើនដោយសារតែអត់បាយ។ ប្រជាជននៅព្រែកឯង និងក្បាលកោះ ខ្មែរក្រហមបានប្រើឲ្យជីករណ្ដៅខ្លួនឯង ហើយនាំគ្នាទៅប្រជុំនៅក្នុងរណ្ដៅនោះសំណាងដែលប្រធានកងមិនបានឡើងមកលើវិញ កុំអីត្រូវបានស្លាប់ នៅក្នុងរណ្ដៅទាំងអស់គ្នា។ នៅបឹងគ្រុំ ក្មួយប្រុសខ្ញុំម្នាក់ស្លាប់ដោយសារកើតកញ្ជ្រិល។ រួចពីនោះទៅនៅព្រែកប្រា ស្រាប់តែផ្ទុះសង្គ្រាម ប្ដីខ្ញុំទៅវាយនៅសមរភូមិហើយគាត់ដេញឲ្យខ្ញុំនាំកូនត្រឡប់មកផ្ទះមុនចាំគាត់ត្រឡប់មកតាមក្រោយ។ ខ្ញុំបាននាំកូនមកនៅស្រុកកំណើតប៉ុន្តែមិនឃើញប្ដីខ្ញុំត្រឡប់មកទេ។ រហូតមកដល់សព្វថ្ងៃខ្ញុំបានមកនៅក្តុលលើ តាមស្វាមីថ្មី ហើយប្រកបមុខរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។

## ជិន គឿន



ជិន គឿន ភេទប្រុស អាយុ៥៧ឆ្នាំ មានទីកន្លែងកំណើតនៅភូមិក្ដុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នរស់នៅក្នុងភូមិក្ដុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ហើយខ្ញុំធ្វើជាប្រធានប្រជាការពារឃុំទន្លូង។ ខ្ញុំមានឪពុកឈ្មោះ ជិន និងម្ដាយឈ្មោះ កិ ស្នាន់។ ខ្ញុំមានបងប្អូនចំនួន៨នាក់ ប៉ុន្តែស្លាប់អស់៣នាក់។ ខ្ញុំគឺជាកូនទី៣នៅក្នុងគ្រួសារ។ ខ្ញុំមានប្រពន្ធឈ្មោះ ប៉ោង ហ៊ាង មានអាយុ៥៥ឆ្នាំ។

នៅមុនសម័យខ្មែរក្រហម ខ្ញុំរៀនបានថ្នាក់ទី២ នៅសាលាក្ដុលលើ ដែលមានលោកគ្រូឈ្មោះតា ហិ និងគ្រូ សុវណ្ណ នៅចង្កំក្រោមបង្រៀន។ ពេលខ្ញុំអាយុ១១ឆ្នាំ ឪពុក និងម្ដាយខ្ញុំធ្វើជាកងចល័តត្រូវដើបទៅធ្វើការតាំងពីព្រឹករហូតដល់ព្រលប់ទើបត្រឡប់មកផ្ទះវិញ។ ខ្មែរក្រហមជម្លៀសអ្នកភូមិក្ដុលលើ ទៅស្រែតាពេជ្រ នៅបានរយៈពេល១០ថ្ងៃជម្លៀសទៅ ម្ចិចមាន់ហើរ បន្តទៀត។ នៅម្ចិចមាន់ហើរ មានអ្នកភូមិស្លាប់ច្រើនដោយសារអត់បាយ។ ខ្មែរក្រហម ជម្លៀសខ្ញុំទៅភូមិភាគកណ្ដាល នៅទីនោះខ្មែរក្រហមមិនបានប្រើឲ្យធ្វើការទេ ហើយបានបាយហូបគ្រប់គ្រាន់។

នៅឆ្នាំ១៩៧៩ ពេលត្រឡប់មកភូមិក្ដុលលើវិញ ខ្ញុំធ្វើជាឈ្លបឃុំទន្លូងមានតួនាទីមើលសណ្ដាប់ធ្នាប់ និងសុវត្ថិភាពប្រជាជនក្នុងឃុំ ប្រសិនបើទាហានស្នើរឈ្លបឃុំឲ្យទៅធ្វើសង្គ្រាមគឺទៅជាមួយ ទាហាន។ ឆ្នាំ១៩៨២ ខ្ញុំចូលធ្វើទាហាននៅ«គ១» ឃុំទន្លូង ហើយបានចុះទៅសមរភូមិចំនួន៣លើក។ ទៅវាយនៅភូមិម្កោរ បន្ទាប់មកភូមិពងទឹក ចុងក្រោយ ភូមិហុចម្ពរ។ ចុះទៅសមរភូមិ៣ដងវាយឈ្នះរហូត។ ឆ្នាំ១៩៨៨ ពេលត្រៀមការពារខ្មាំងសត្រូវ មិត្តធ្វើជាទាហានដូចគ្នាបានបាញ់កាំភ្លើងលេង។ ខ្ញុំប្រាប់ថាប្រយ័ត្នបាញ់ត្រូវខ្ញុំតែមិត្តទាហាន និយាយថាមិនអីទេ។ បន្ទាប់មកស្រាប់តែកាំភ្លើងរៀលមកត្រូវភ្លៅខ្ញុំធ្វើឲ្យបាក់ឆ្អឹងភ្លៅ រួចទៅសម្រាកព្យាបាលនៅពេទ្យកំពង់ចាម។ ពេលនោះខ្ញុំត្រូវគូដណ្ដឹងផ្ដាច់ពាក្យដោយសារតែខ្ញុំពិការ។ បន្ទាប់ពីជាស្រួលបួលចូលធ្វើទាហានបន្តទៀត ថ្នាក់លើបានបញ្ជូនខ្ញុំទៅប៉ៃលិន តែខ្ញុំសុំច្បាប់មកស្រុកវិញ។ ឆ្នាំ១៩៨៩ ខ្ញុំបានសែនជាមួយប្រពន្ធឈ្មោះ ប៉ោង អៀង ហើយរស់នៅជាមួយគ្នារហូតមកដល់សព្វថ្ងៃ។

## កិ យ៉ាន់



ខ្ញុំឈ្មោះ កិ យ៉ាន់ ភេទស្រី អាយុ៩៣ឆ្នាំ។ ខ្ញុំមានទីកន្លែងកំណើតនៅក្នុងភូមិក្ដុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្នរស់នៅក្នុងភូមិក្ដុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ កឺ បានស្លាប់ និងម្ដាយឈ្មោះ សាន់ ធ្លាក់ពីលើគ្រែនិយាយមិនចេញ ហើយក៏ស្លាប់តែម្ដង។ ខ្ញុំមានបងប្អូនចំនួន៤នាក់។ កាលពីក្មេងរៀនសូត្របានត្រឹមថ្នាក់ទី១ ហើយរៀននៅតាមផ្ទះ។ ជីវភាពគ្រួសារពិបាកពេកខ្ញុំឈប់រៀន ហើយទៅធ្វើស្រែចម្ការជាមួយឪពុកម្ដាយ។ កាលនោះមានការទម្លាក់គ្រាប់បែកនៅជាយៗភូមិ ប៉ុន្តែមិនមានអ្នកភូមិណាត្រូវរបួសទេ។ បន្ទាប់មកធ្វើស្រែរួមគ្នាបានផលចែកគ្នា

ហើយ ហូបបាយតាមផ្ទះរៀងខ្លួនៗ តមកទៀតចាប់ផ្តើមដាក់របស់របររួម ហូបបាយរួម ជម្រុកស្រូវតែមួយដោយបង្កើតជាសហករណ៍។ កូនប្រុសខ្ញុំទៅរកសត្វឈ្លូសក្នុងព្រៃត្រូវខ្មែរក្រហមបាញ់ស្លាប់។

## ម៉ៅ ជិន



ខ្ញុំឈ្មោះ ម៉ៅ ជិន ភេទប្រុស អាយុ៨៨ឆ្នាំ មានទីកន្លែងកំណើតនៅភូមិយក្រឹម ឃុំយក្រឹម ស្រុកស្នួល ខេត្តក្រចេះ។ ឪពុកឈ្មោះ ជិន និង ម្តាយឈ្មោះ ដាន់ ស្លាប់ដោយសារជំងឺ។ ខ្ញុំមានបងប្អូនចំនួន២នាក់ ប៉ុន្តែប្អូនខ្ញុំស្លាប់តាំងពីឆ្នាំ១៩៩៤។ កាលពីក្មេងខ្ញុំចូលរៀននៅសាលា ក្នុងឃុំយក្រឹម។ លោកគ្រូបង្រៀនឈ្មោះ អេង ហើយមួយថ្នាក់មានសិស្សចំនួន៣០នាក់។ រៀនបានត្រឹមថ្នាក់ទី៤ ខ្ញុំឈប់រៀនដោយសារតែគ្រួសារខ្វះខាត។ រួចមករស់នៅជាមួយឪពុក មិនបានជួយធ្វើស្រែចម្ការទេ។ ខ្ញុំរៀបការឆ្នាំ១៩៦៧ រួចមករស់នៅភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ចូលដល់សម័យ លន់ នល់ ទៅរៀនបើកឡានបានពីរឆ្នាំបានលុយក៏ទៅប្រឡងយកពាក់មី។ ខ្ញុំបើកឡានដឹកឈើម៉ុខ២៧០ ម៉ុខ២៨០ ឈើធំៗទៅទម្លាក់នៅថ្មគ្រែ ហើយបើមានអ្នកដំណើរខ្ញុំដឹកពីភ្នំពេញទៅក្រចេះ និង ពីក្រចេះមកភ្នំពេញ។ ពេលធ្វើរដ្ឋប្រហារ នៅក្នុងភូមិមានអ្នកទៅចូលរួមដែរ តែទៅដោយស្ម័គ្រចិត្ត និង មានឡានគេមកដឹកយកទៅធ្វើបាតុកម្មនៅជីពោទ៌។ ប្រជាជនដែលទៅធ្វើបាតុកម្មភាគច្រើនមិនឃើញមានយកអ្វីទៅទេ ហើយទៅមួយថ្ងៃពីរថ្ងៃត្រឡប់មកវិញធ្វើស្រែចម្ការ។ ទាហានអាមេរិកចូលមកក្នុងភូមិ ប៉ុន្តែមិនធ្វើបាបប្រជាជនទេ ហើយ ទាហានអាមេរិកមានបន្ទាយនៅកោះថ្មនិង ភូមិពងទឹក។ ពួកវៀតកុងឬវៀតណាមខាងជើងនៅតាមព្រៃនៅជិតប្រភពទឹក ហើយចូលមកក្នុងភូមិរហូត។ ទាហានអាមេរិកតាំងនិង ពួកវៀតកុងធ្លាប់វាយគ្នាពីរទៅបីដងនៅជិតភូមិក្តុលលើ ប៉ុន្តែខ្ញុំមិនបានឃើញដោយផ្ទាល់ទេឮតែសំឡេងកាំភ្លើងៗ។ បន្ទាប់មកមានការរៀបចំធ្វើស្រែចម្ការរួមគ្នា បានផលចែកគ្នា។ ហូបបាយតាមផ្ទះបានរយៈពេល១ឆ្នាំ ខ្មែរក្រហមប្រមូលទ្រព្យសម្បត្តិ មាសប្រាក់ ដីធ្លី គោក្របី ដាក់ចូលជាសម្បត្តិរួម។ ប្រជាជននៅក្នុងភូមិត្រូវគោរពតាមច្បាប់វិន័យរបស់អង្គការ បើហ៊ានធ្វើខុសខ្មែរក្រហមនឹងចាប់យកទៅកសាង។ ក្រុមគ្រួសារខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅភូមិស្រែតាពេជ្រ នៅធ្វើស្រែបាន៩ទៅ១០ថ្ងៃ ខ្មែរក្រហមជម្លៀសទៅភូមិស្អាត ខាងស្រុកស្នួល។ នៅភូមិស្អាតធ្វើការជាមួយប្រជាជននៅទីនោះបានរយៈពេល៣ខែ ខ្មែរក្រហមជម្លៀសទៅស្វាយជ្រះ។ នៅស្វាយជ្រះធ្វើការទាំងយប់ថ្ងៃ ពិបាកហូបចុកណាស់ យាយតាចាស់ៗស្លាប់ច្រើន។ បន្ទាប់មកខ្មែរក្រហមជម្លៀសទៅម៉ិច នៅធ្វើការលើកទំនប់ ភ្លឺស្រែ កាប់គាស់រានព្រៃ មើលក្របី ភ្ជួរស្រែ ធ្វើស្រែគ្មានពេលសម្រាក។ បបរាវគ្មានគ្រាប់អង្ករ ហូបមួយថ្ងៃ២ដង នៅតែគ្មានកម្លាំងធ្វើការ។ មនុស្សចាស់ ក្មេង ឈឺ ស្លាប់។ ខ្ញុំបន្តទៅថ្មគ្រែទៅដល់មានកាណូតមកយកទៅក្រូចឆ្មារ ហើយជិះឡានទៅភូមិជយោ នៅបាន២ទៅ៣ខែបានហូបបាយឆ្អែត។ បន្ទាប់មកឮចាស់ៗក្នុងភូមិថាអ្នកនៅស្រុកណាទៅនៅស្រុកនោះវិញ។ ខ្ញុំធ្វើដំណើរតាមភូមិបុស្សខ្នុរ ឈប់សម្រាកមួយយប់។ បន្ទាប់មកដើរថ្មើរជើងរហូតមកដល់មេមត់ ដេកមួយយប់ ហើយពេលមកដល់ក្តុលសម្រាក៤ទៅ៥ថ្ងៃទៀត ទាល់តែដោះមីនរួចទើបហ៊ានចូលរស់នៅ។ ចូលមកនៅដំបូងមានតែ៣ទៅ១០គ្រួសារទេ បន្ទាប់មកប្រជាជនចេះតែចូលមកនៅតាមគ្នារហូតមកដល់សព្វថ្ងៃ។

# ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង នាំយកសៀវភៅ "សាក្សីប្រវត្តិសាស្ត្រ"

## កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន២០០ក្បាល ចែកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងមូលដ្ឋាន

ឡុង ដានី



នៅចន្លោះថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រគេន និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន២០០ក្បាល ដល់ព្រះសង្ឃ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និង អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចន្លោះថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រគេន និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន២០០ក្បាល ដល់ព្រះសង្ឃលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និង អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។

ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានប្រគេន និងចែកសៀវភៅ "សាក្សីប្រវត្តិសាស្ត្រ" នៅតាមភូមិ ឃុំ សាលារៀន និងវត្តអារាម ដែលក្រុមការងារធ្លាប់បានធ្វើការងារជាមួយពីមុនមកចំនួន ១៨កន្លែងនៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។

សាក្សីប្រវត្តិសាស្ត្រ៖ សៀវភៅកំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ» គឺជាឯកសារប្រវត្តិសាស្ត្រ ដែលបានបង្ហាញអំពីព្រះរាជហឫទ័យសង្កេតផ្ទាល់របស់សម្តេចព្រះមហាក្សត្រី ក្នុងព្រះរាជបេសកកម្ម និងព្រះរាជដំណើររបស់ព្រះអង្គ

យាងទៅកាន់តំបន់រំដោះរណសិរ្សរួបរួមជាតិកម្ពុជាក្នុងឆ្នាំ១៩៧៣។ សម្តេចព្រះមហាក្សត្រីបានយាងអមព្រះរាជដំណើរ ព្រះករុណាព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ ដោយចាប់ផ្តើមចេញព្រះរាជដំណើរតាមព្រះទីនាំងយន្តហោះពីទីក្រុងប៉េកាំង ឆ្ពោះទៅកាន់ទីក្រុងហាណូយប្រទេសវៀតណាម និងបន្ទាប់មកបន្តដំណើរតាមព្រះទីនាំងរថយន្តតាមបណ្តោយផ្លូវលំហូជីមិញ ឆ្ពោះទៅកាន់ប្រទេសកម្ពុជាដោយឆ្លងកាត់ផ្នែកខ្លះនៃផ្លូវលំសីហនុក្នុងខេត្តស្ទឹងត្រែង ឆ្លងទន្លេមេគង្គបន្តទៅខេត្តព្រះវិហារ ដើម្បីបំពេញព្រះរាជបេសកកម្ម និងទស្សនកិច្ចនៅភ្នំគូលែន និងសៀមរាប (អង្គរវត្ត) ក្នុងដំណើរបំពេញព្រះរាជបេសកកម្មរយៈពេលប្រមាណ៣៩ថ្ងៃ។ «ហ្វូងម៉ែ» ទ្រង់បានសព្វព្រះរាជហឫទ័យប្រគល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជាបោះពុម្ពសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ជាលើកទីមួយសម្រាប់ប្រគេន និងចែកជូនព្រះសង្ឃ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សា និងប្រជាជនខ្មែរបានអាននូវកំណត់ហេតុរបស់ហ្វូងម៉ែ ដែលជាផ្នែកសំខាន់មួយនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជាកាលពីជាង៥០ឆ្នាំមុន។

ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានប្រគេន និងចែកជូនគ្រប់ចំនួន១៥ សាលារៀន ស្ថាប័ន និងទីកន្លែងដូចខាងក្រោម ៖

១) សាលាវត្តប្រម៉ោយ ចំនួន១៥ក្បាល
២) វិទ្យាល័យ ក្រពើពីរ ចំនួន១៨ក្បាល
៣) វិទ្យាល័យ ហ៊ុនសែនប្រម៉ោយ ចំនួន៤០ក្បាល
៤) អនុវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ថ្មដារ ចំនួន២០ក្បាល
៥) អនុវិទ្យាល័យអន្លង់រាប ចំនួន១៥ក្បាល
៦) អនុវិទ្យាល័យអូរសោម ចំនួន១៥
៧) សាលាឃុំអូរសោមចំនួន៥ក្បាល
៨) សហគមន៍តំបន់ការពារធម្មជាតិភូមិទំព័រ ចំនួន៨ក្បាល
៩) សាលាឃុំប្រម៉ោយ ចំនួន៥ក្បាល
១០) សាលាបឋមសិក្សាដូនទាគ ចំនួន៧ក្បាល
១១) អនុវិទ្យាល័យ តាំងយ៉ ចំនួន២៥ក្បាល
១២) សាលាបឋមសិក្សា តាំងយ៉ ចំនួន៧ក្បាល
១៣) ភូមិទួលកកោះ ចំនួន១០ក្បាល
១៤) ភូមិស្ទឹងថ្មី ចំនួន១០ក្បាល



នៅចន្លោះថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រគេន និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុព្រះវររាជមាតាជាតិខ្មែរ ចំនួន២០០ក្បាល ដល់ព្រះសង្ឃ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និង អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

«ព្រះសង្ឃ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាជនខ្មែរស្ទើរតែគ្រប់គ្នាពេលដែលទទួលបានសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ មានចិត្តសប្បាយរីករាយ ទឹកមុនញញឹមញញែម ត្រេកអរចំពោះសៀវភៅដែលក្រុមការងារបាន ប្រគេននិងចែកជូន។ ប្រជាជនបានមកចាំទទួលសៀវភៅរបស់ «ហ្លួងម៉ែ» ឬ សៀវភៅសាក្សីប្រវត្តិសាស្ត្រ ហើយបានបង្ហាញពីភាពកក់ក្ដៅ និងទទួលស្វាគមន៍បានយ៉ាងល្អ។ នៅតាមសាលារៀន ស្ថាប័ន និងទីកន្លែងដែលក្រុមការងារត្រូវចុះទៅចែកសៀវភៅ មានការរៀបចំបានល្អ មានទាំងទេសភាពអមសងខាងផ្លូវ រុក្ខជាតិពណ៌បៃតងស្រស់។ ប្រជាជនរស់នៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ភាគច្រើន គឺជាកសិករប្រកបរបរកសិកម្ម ដូចជា ដាំដំឡូងមី ស្វាយចន្ទី កៅស៊ូ ចិញ្ចឹមសត្វ និងលក់ដូរនៅតាមទីផ្សារ ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។








នៅចន្លោះថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រគេន និងចែកសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» កំណត់ ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សហនុ ព្រះវររាជមាតាជាតិខ្មែរ ចំនួន២០០ក្បាល ដល់ព្រះសង្ឃ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និង អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា ភូមិបាក់នឹមចុះចែកសៀវភៅព័ត៌មាន

## អំពីការថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

ផាត ចាន់សុនិតា





អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបាក់នឹម កំពុងអានសៀវភៅអប់រំអំពីសុខភាព។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងារស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជានៅភូមិបាក់នឹមរួមមាន ណូន នៃឡែន, ខេង ពិសី, អៀង សុជា និង ជន វន្នី បានចុះចែកសៀវភៅ ព័ត៌មានអំពីការថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០០ក្បាល ដល់ប្រជាជននៅភូមិបាក់នឹម ដែលបានផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហមដល់អ្នកស្ម័គ្រចិត្តកម្ពុជា។ ភូមិបាក់នឹម គឺជាតំបន់ដាច់ស្រយាលស្ថិតនៅតាមបណ្តោយជើងភ្នំដំរីរមៀល ជាប់ព្រំប្រទល់ខេត្តតាកែវកំពត មានចម្ងាយឆ្ងាយពីទីប្រជុំជន សាលារៀន និង មន្ទីរពេទ្យប្រមាណជាង២០គីឡូម៉ែត្រ។ ប្រជាជនរស់នៅតំបន់នេះ មានជីវភាពខ្វះខាតមិនមានលទ្ធភាពទៅពិនិត្យ ព្យាបាលជំងឺនៅមន្ទីរពេទ្យនោះទេ។ ក្នុងរយៈពេល៤ខែកន្លងមកនេះ ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធិ និង ការធ្វើឲ្យប្រសើរឡើងវិញនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅ

ជួបសួរសុខទុក្ខ និងពិនិត្យសុខភាពជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបាក់នឹមចំនួន ១៨៩ នាក់ ដែលមានអាយុចាប់ពី៥០ឆ្នាំឡើង។ គោលបំណងនៃការចុះសួរសុខទុក្ខ និង ពិនិត្យជំងឺជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមតាមរយៈការសិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់គាត់ ផ្តោតលើការអប់រំ និង ពិគ្រោះយោបល់អំពីបញ្ហាសុខភាព មានគោលដៅពន្យារអាយុជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីឲ្យគាត់មានឱកាសបន្តចែករំលែកបទពិសោធន៍ជីវិតរបស់ខ្លួនទៅកាន់មនុស្សជំនាន់ក្រោយក្នុងការទប់ស្កាត់អំពើឧក្រិដ្ឋកម្មមិនឲ្យកើតមានសាជាថ្មីម្តងទៀត។

យោងតាមលទ្ធផលនៃការស្ទាបស្ទង់មតិរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ៣២០០០នាក់ នៅទូទាំងប្រទេសកម្ពុជាបានរកឃើញជំងឺ១០ប្រភេទ ដែលតែងកើតមានចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានដូចជា៖ ជំងឺលើសឈាម, ជំងឺក្រពះពោះវៀន, ជំងឺគ្រុនចាញ់, ជំងឺផ្លូវចិត្ត, ជំងឺបេះដូង, ជំងឺរលាកសន្លាក់, ជំងឺទឹកនោមផ្អែម, ជំងឺហឺតរ៉ាំរ៉ៃ, ជំងឺរបេង និង ជំងឺឆ្កួតជ្រូក។ ការចែកជូនកូនសៀវភៅព័ត៌មានអំពីការថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ក្នុងគោលបំណងឲ្យប្រជាជនយល់ដឹងអំពីរបៀបរស់នៅឲ្យមានសុខភាពល្អ និងយល់ដឹងពីមូលហេតុដែលបង្កឲ្យមានជំងឺ និងវិធីសាស្ត្រក្នុងការបង្ការទប់ស្កាត់កុំឲ្យកើតមានជំងឺទាំង១០ប្រភេទខាងលើ។







អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបាក់នឹម កំពុងអានសៀវភៅអប់រំអំពីសុខភាព។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ង៉ែត សំ ៖ កងចល័តនៅក្នុងរបបខ្មែរក្រហម

**ផន វន្នី**



ង៉ែត សំ អាយុ៦២ឆ្នាំ រស់នៅភូមិបាក់នឹម ឃុំព្រែស ស្រុកជុំគិរី ខេត្តកំពត។ (ផន វន្នី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ង៉ែត សំ ភេទប្រុស កើតថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៦១។ មកដល់សព្វថ្ងៃ ខ្ញុំមានអាយុ៦២ឆ្នាំ ហើយ និងរស់នៅភូមិបាក់នឹម ឃុំព្រែស ស្រុកជុំគិរី ខេត្តកំពត។ ខ្ញុំមានស្រុកកំណើតនៅភូមិកសិករ ឃុំស្រឡាញ់ ស្រុកអង្គរជ័យ ខេត្តកំពត។ ខ្ញុំចូលរៀននៅសាលាវត្តអង្គស្តុកក្នុងឆ្នាំ១៩៦៨។ រហូតដល់ថ្ងៃរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីព្រះប្រមុខរដ្ឋដោយសេនាប្រមុខ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំមិនសូវបានរៀនជាប់ដូចពីមុនទេ ព្រោះមានសង្គ្រាម ហើយខ្ញុំរត់គេចគ្រាប់ផ្លោង និងយន្តហោះទម្លាក់គ្រាប់បែក។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារខ្ញុំទៅកាន់ភូមិ៤ ឃុំព្រៃយុទ្ធកា ស្រុកកោះអណ្តែត ខេត្តតាកែវ ជាប់ព្រំដែនវៀតណាម។ ពេលនោះខ្មែរក្រហមចាត់ឲ្យខ្ញុំឲ្យឃ្វាលគោជាមួយកងមនុស្សចាស់ រហូតដល់ឆ្នាំ១៩៧៦ ទើបអង្គការផ្លាស់ខ្ញុំមកនៅកងកុមារក្លាហានវិញ។ ខ្ញុំត្រូវធ្វើការងារនៅតាមកងចល័តនៅភូមិបន្ទាយភ្លាយ ឃុំព្រៃបាយ ស្រុកកោះអណ្តែត ខេត្តតាកែវ។ ទីកន្លែងដែលខ្ញុំរស់នៅមានចម្ងាយប្រហែលជាង២០ គីឡូម៉ែត្រ ពីកន្លែងឪពុកម្តាយខ្ញុំរស់នៅ។ ការងាររបស់ខ្ញុំគឺជីកប្រឡាយ លើកទំនប់ ធ្វើស្រែបីដងក្នុងមួយឆ្នាំ។

នៅចុងឆ្នាំ១៩៧៧ កងទ័ពវៀតណាមវាយចូលកាន់កាប់ស្រុកកោះអណ្តែតទាំងស្រុង ហើយមិនយូរប៉ុន្មានកងទ័ពខ្មែរក្រហមក៏វាយដណ្តើមយកមកវិញ។ ពេលនោះ ខ្ញុំត្រូវបានខ្មែរក្រហមយកទៅផ្ញើនៅតាមកងចល័តនៅភូមិពោន ឃុំអង្គុញ ស្រុកទ្រាំង ខេត្តតាកែវ។

អំឡុងពេលនោះ ខ្ញុំត្រូវប្រធានកងចល័តយល់ច្រឡំថា ខ្ញុំគឺជាមនុស្សដែលខ្មែរក្រហមបញ្ជូនពីព្រំដែនវៀតណាមមក ហេតុនេះហើយទើបប្រធានកងចល័តចោទខ្ញុំថា គឺជាខ្មែរកម្ពុជាក្រោមដោយធ្វើការលត់ដំឲ្យខ្ញុំធ្វើការងាររែកដី ជីកប្រឡាយជាទម្ងន់។ ពេលព្រឹក ខ្ញុំរែកដីចំនួន២ម៉ែត្រគុបកន្លះ និងពេលរសៀលចំនួន២ម៉ែត្រគុបកន្លះទៀត។ ប្រសិនបើខ្ញុំធ្វើការមិនរួចតាមផែនការកំណត់ទេ ត្រូវធ្វើការងារពេលយប់បន្ថែម និងមិនទទួលបានរបបអាហារទេ។ ដោយសារតែខ្ញុំធ្វើការងារលើសកម្លាំង និងខ្វះខាតអាហារ ខ្ញុំក៏

ធ្លាក់ខ្លួនឈឺ។ ខ្មែរក្រហមចោទខ្ញុំថា ធ្វើពុតជាឈឺ គេចវេះពីការងារ ហើយវាយដំខ្ញុំដើម្បីកុំឲ្យអ្នកផ្សេងទៀតយកគំរូតាមខ្ញុំ។ ខ្មែរក្រហមបែងចែកកម្លាំងធ្វើការងារក្នុងមួយពួកមាន៦នាក់ មួយក្រុមមាន១២នាក់ និងមួយកងមានមនុស្សចំនួន៣០នាក់, ៥០នាក់ និងរហូតទៅដល់១០០នាក់។ កងកម្លាំងពួកប្រជុំគិតទៀនចំនួន៣ថ្ងៃម្តង។ ចំណែកកងកម្លាំងក្រុមប្រជុំគិតទៀននិងបូកសរុបការងាររយៈពេល៦ថ្ងៃម្តង។ ការប្រជុំរួមគ្នាក្នុងមួយខែបីដង ដោយប្រជុំនៅរៀងរាល់ថ្ងៃទី១០ ទី២០ និងទី៣០។ មុនពេលកិច្ចប្រជុំចាប់ផ្តើមមានការស្រែកជ័យឃោសបីដង និងប្តេជ្ញាបីដង រួចទើបធ្វើដំណើរជាជួរទៅកាន់ទីកន្លែងប្រជុំបដិវត្តន៍។

នៅក្នុងស្រុករបស់ខ្ញុំនៅក្នុងរបបខ្មែរក្រហមមានមន្ទីរសន្តិសុខដូចជា មន្ទីរតាម៉ឺន ស្ថិតនៅក្នុងភូមិអង្គក្រូវ ឃុំអង្គរជ័យ ស្រុកអង្គរជ័យ ខេត្តកំពត ដែលបានសម្លាប់ប្រជាជនចំនួនប្រហែលជាងបីម៉ឺននាក់ និងទីតាំងសម្លាប់មនុស្សមួយកន្លែងទៀតស្ថិតនៅភូមិក្របៀត ក្នុងតំបន់ភ្នំក្រិល ឃុំសំឡាញ់ ស្រុកអង្គរជ័យ ខេត្តកំពត។ នៅពេលខ្ញុំនឹកឃើញដល់របបខ្មែរក្រហម ខ្ញុំមានការឈឺចាប់ខ្លោចផ្សារមិនអាចបំភ្លេចបានឡើយ ខ្ញុំមានអារម្មណ៍ហាក់ដូចជារឿងទាំងអស់នោះទើបនឹងកើតឡើងថ្មីៗពីម្សិលមិញ។ ខ្ញុំបាត់បង់ពូម្នាក់នៅក្នុងរបបខ្មែរក្រហមដោយសារគាត់គឺជាអតីតទាហានលន់ នល់។



ង៉ែត សំ អាយុ៦២ឆ្នាំ រស់នៅភូមិបាក់នឹម ឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត។ (ផន វិទ្នី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍

ទូច វណ្ណេត





នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៣ មជ្ឈ-មណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់ចេតិយរំឭក សម្រាប់សហគមន៍ ដោយមានការចូលរួមពីអ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម ចំនួន១០០នាក់ មកពីស្រុកកំពង់សៀម និងស្រុកកោះសូទិន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់ចេតិយរំឭក សម្រាប់សហគមន៍ ដោយមានការចូលរួមពីអ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម ចំនួន១០០នាក់ មកពីស្រុកកំពង់សៀម និងស្រុកកោះសូទិន។ វេទិកាអ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាមនេះរៀបចំឡើងក្នុងគោលបំណងផ្ដល់ចំណេះដឹង ដល់អ្នកស្ម័គ្រចិត្តដែលជាក្មេងជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បុគ្គលការខ្មែរក្រហម និងការសរបុះជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ជាកិច្ចចាប់ផ្ដើមនៃវេទិកានេះ ទូច វណ្ណេត គឺជាបុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានដឹកនាំអ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តកំពង់ចាម ទៅទស្សនាពិព័រណ៍អចិន្ត្រៃយ៍ដែលបង្ហាញអំពីប្រវត្តិ

មេដឹកនាំខ្មែរក្រហម, ការជម្លៀសប្រជាជន, ការធ្វើការងារនៅការដ្ឋានទំនប់ និងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពង់ចាម។ បន្ទាប់មកអ្នកស្ម័គ្រចិត្តទាំងអស់បានបន្តទៅទស្សនាពិព័រណ៌ព្រះឆាយាល័ក្ខណ៍ចំនួន១៨ផ្ទាំង ដែលជាផ្នែកមួយនៃពិព័រណ៌ «ក្តីសុបិនកម្ពុជា» រៀបចំដោយ «បណ្ណាល័យសម្តេចម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ណាល័យខ្មែរក្រហមដែលមានតម្កល់សៀវភៅទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហមជាច្រើន។

កម្មវិធីបន្ទាប់គឺបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយលោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ លោក ស៊ាង ចិន្តា ចាប់ផ្តើមធ្វើបទបង្ហាញរបស់ខ្លួនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលបានផ្តោតទៅលើការកំណត់ក្រុមប្រជាជនក្នុងរបបខ្មែរក្រហម, ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីប្រជុំជន, ការបង្ខំប្រជាជនឲ្យធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់ និងការសម្លាប់រង្គាលទៅលើប្រជាជន។ បន្ទាប់មកលោក ស៊ាង ចិន្តា បន្តដឹកនាំការពិភាក្សាដោយផ្តោតសំខាន់ទៅលើការបង្ខំប្រជាជនឲ្យធ្វើការហួសកម្លាំងក្នុងរបបខ្មែរក្រហម និងសារសំខាន់នៃការដឹងអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ឆ្លៀតក្នុងឱកាសនេះដែរ លោក សាំង ចាន់ធូ បុគ្គលិកទទួលបន្ទុកអ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម បាននិយាយចែករំលែកដល់អ្នកស្ម័គ្រចិត្តចូលរួមទាំងអស់អំពី សារសំខាន់នៃការចុះជួប និងសួរសុខទុក្ខអ៊ំប្រុសអ៊ំស្រី លោកតា លោកយាយ ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម។ បន្ថែមលើនេះទៀត អ្នកស្ម័គ្រចិត្តអាចមានឱកាសស្តាប់បទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានរបស់ខ្លួន រួមទាំងអ្វីដែលគាត់ចាំមិនភ្លេច និងអ្វីដែលគាត់ចង់ឲ្យក្មេងជំនាន់ក្រោយចងចាំអំពីរបបខ្មែរក្រហម។ ជាកិច្ចបញ្ចប់ អ្នកស្ម័គ្រចិត្តទស្សនាវីដេអូខ្លីអំពីអ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម ជំនាន់ទី១ និងជំនាន់ទី៦ ដែលបាននិយាយចែករំលែកបទពិសោធន៍របស់ខ្លួន។

ជាកិច្ចបន្ត លោក ព្រាំ ដល្លា បុគ្គលិកសម្របសម្រួលគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចូលរួមផ្តល់បទបង្ហាញរបស់ខ្លួនទៅកាន់អ្នកស្ម័គ្រចិត្តអំពីដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការខ្មែរក្រហម ដែលបានកាត់ទោសទៅលើមេដឹកនាំខ្មែរក្រហម ឬអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងរបបខ្មែរក្រហម។ លោក ព្រាំ ដល្លា បានលើកឡើងអំពីការចាប់ផ្តើម និងដំណើរការតុលាការខ្មែរក្រហមក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតពីរបបខ្មែរក្រហម និងសំណងសមូហភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

កម្មវិធីពេលរសៀលនៃវេទិកានេះ គឺការចុះផ្ទាល់ទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ និងជួបផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ នៅពេលទៅដល់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍ លោក គុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទទួលស្វាគមន៍អ្នកស្ម័គ្រចិត្តទាំងអស់ និងនិយាយចែករំលែកអំពីបទពិសោធន៍ជីវិតរបស់ខ្លួន និងការបាត់បង់ជីវិតឪពុករបស់ខ្លួនដែលកងឈ្លបខ្មែរក្រហមបានចាប់យកទៅសម្លាប់ចោល។ ខណៈពេលកំពុងនិយាយអំពីបទពិសោធន៍របស់ខ្លួន លោក គុង សុភា បាននាំអ្នកស្ម័គ្រចិត្តទាំងអស់ទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ស្ថិតនៅកណ្តាលវាលស្រែ។ លោក គុង សុភា បានបញ្ជាក់ថា ចេតិយរំឭកនេះគឺសម្រាប់សហគមន៍គគរ ដែលប្រជាជនអាចធ្វើការរំឭកដល់ជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម និងផ្តល់ជាទីតាំងសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអាចនិយាយចែករំលែកបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហមទៅកាន់ក្មេងៗជំនាន់ក្រោយ។

សុទី អាស៊ីរ៉ស់ អ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម មកពីស្រុកកោះសូទិន បង្ហាញទស្សន

យល់ឃើញថា ខ្ញុំយល់ថា ការចូលរួមការងារស្ម័គ្រចិត្ត គឺពិតជាមានសារសំខាន់សម្រាប់រូបខ្ញុំ និងយុវជនផ្សេងទៀត ពីព្រោះការងារស្ម័គ្រចិត្តនឹងផ្តល់ទាំងបទពិសោធន៍ ក្នុងការប្រាស្រ័យទាក់ទងក្នុងសហគមន៍ និងចំណេះដឹងប្រវត្តិសាស្ត្រចេញពីការស្តាប់បទពិសោធន៍ជីវិតរបស់អ៊ំៗ លោកតាលោកយាយដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម»។

សៀង អ៊ី អ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម មកពីស្រុកកំពង់សៀម និយាយថា «វេទិកាអ្នកស្ម័គ្រចិត្តកម្ពុជានេះបានផ្តល់ការយល់ដឹងបន្ថែមអំពីប្រវត្តិសាស្ត្រ ការកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងតុលាការខ្មែរក្រហម ដែលខ្ញុំមិនបានដឹងពីមុនមក និងការស្តាប់អំពីរឿងរ៉ាវរបស់អ៊ំប្រុស សុភា ដែលបានរួចផុតពីសេចក្តីស្លាប់ ប៉ុន្តែគាត់បានបាត់បង់ឪពុក។ អ្វីដែលខ្ញុំទទួលបានថ្ងៃនេះ គឺបានធ្វើឲ្យខ្ញុំមានទំនុកចិត្តជាងមុនក្នុងការចុះជួបជាមួយអ៊ំៗយាយតាក្នុងសហគមន៍របស់ខ្ញុំដើម្បីសួរសុខទុក្ខ និងសួរនាំអ្វីដែលគាត់ចាំមិនភ្លេច និងបទពិសោធន៍ក្នុងរបបខ្មែរក្រហម»។







អ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តកំពង់ចាមចំនួន១០០នាក់ ទស្សនកិច្ចសិក្សាមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងសហគមន៍នៅស្រុកកំពង់សៀម។
( លី ដេវីត / មជ្ឈមណ្ឌលឯកសារកម្ពុជា )



# មជ្ឈមណ្ឌលឯកសារកោះថ្ម ត្រួតពិនិត្យ និង វាយតម្លៃការសិក្សារបស់សិស្សដែលធ្លាប់បាន

## ចូលរួមវេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និង វិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍»

ធ្យូង ជានី



ការត្រួតពិនិត្យ និង វាយតម្លៃការសិក្សារបស់សិស្សដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន "ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍" នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំធ្វើការត្រួតពិនិត្យ និងវាយតម្លៃការសិក្សារបស់សិស្សដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន«ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍»។ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានជ្រើសរើសយកវិទ្យាល័យចំនួនបីដែលក្នុងមួយវិទ្យាល័យជ្រើសយកសិស្សចំនួន៥នាក់ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃការសិក្សា។ សកម្មភាពដែលក្រុមការងារបានជួបសិស្សានុសិស្សដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃការសិក្សានៅតាមវិទ្យាល័យនីមួយៗមានដូចខាងក្រោម ៖

### ១) វិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន លាជលើ ៖

នៅវេលាម៉ោង០៨:០០ព្រឹក ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មបានធ្វើដំណើរទៅដល់វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនលាជលើ និងបានជួបនាយកសាលា ស៊ុំ គុងហេង ដើម្បីស្នើសុំជួបសិស្ស



ការត្រួតពិនិត្យ និង វាយតម្លៃការសិក្សារបស់សិស្សដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន "ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍" នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ (ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចំនួន៥នាក់ដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន «ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍» នៅមជ្ឈមណ្ឌលឯកសារកោះថ្មកន្លងមក។

លោក ស៊ុំ តុងហេង បានអនុញ្ញាតឲ្យសិស្សចំនួន៥នាក់ស្រី២នាក់ និងប្រុស៣នាក់ដើម្បីជួបជាមួយក្រុមការងារ។ ជាកិច្ចបន្ទាប់លោក ឡុង ដានី បានណែនាំ និងពន្យល់នូវសំណួរក្នុងតារាងស្ទាបស្ទង់មតិទៅកាន់សិស្សានុសិស្សទាំង៥នាក់។ នៅវេលាម៉ោង០៨:២០នាទីព្រឹក សិស្សចាប់ផ្តើមបំពេញកម្រងសំណួរដោយយកចិត្តទុកដាក់។ សិស្សទាំង៥នាក់បានសរសេរចម្លើយ ទាំងអស់យ៉ាងឆាប់រហ័ស។ សិស្សបាននិយាយថាក្រោយពេលចូលរួមវេទិកាថ្នាក់រៀនកន្លងមក គាត់បានចែករំលែករឿងរ៉ាវដែលធ្លាប់បានសិក្សារៀនសូត្រទៅដល់ គ្រួសារ មិត្តភក្តិ និងអ្នកភូមិដែលខ្លួនកំពុងរស់នៅ។ ជាចុងក្រោយ សិស្សសំណូមពរឲ្យមានការរៀនលម្អិតអំពីប្រវត្តិ-សាស្ត្រខ្មែរក្រហមឲ្យបានកាន់តែច្រើនបន្ថែមទៀត។

## ២) វិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន ស្រែតានងកើត៖

នៅម៉ោង០៩:១៥នាទីព្រឹក ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បានធ្វើដំណើរចេញពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែនលាជលើ ឆ្ពោះទៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ស្រែតានងកើត។ លោកគ្រូអ្នកគ្រូបានចេញមកទទួលស្វាគមន៍ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មយ៉ាងកក់ក្តៅ។ នៅវេលាម៉ោង១០:០០នាទីព្រឹក លោក ឡុង ដានី បានជួប និង ពន្យល់សំណួរក្នុងតារាងស្ទាបស្ទង់មតិទៅកាន់សិស្សានុសិស្សចំនួន៥នាក់ គឺស្រី៣នាក់ និងប្រុស២នាក់ ដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន «ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍» កាលពីខែមីនា ឆ្នាំ២០២៣ កន្លងមក។ បន្ទាប់មកបានបំពេញកម្រងសំណួរដោយយកចិត្តទុកដាក់។ សិស្សសរសេរចម្លើយទៅតាមការយល់ដឹងរបស់ខ្លួន។ សិស្សនៅវិទ្យាល័យស្រែតានងកើត ពិតជាទទួលបានការបណ្តុះបណ្តាលពីគ្រូ អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងបានចែករំលែកចំណេះដឹងរបស់



ការត្រួតពិនិត្យ និង វាយតម្លៃការសិក្សារបស់សិស្សដែលធ្លាប់បានចូលរួមវេទិកាថ្នាក់រៀន " ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍" នៅមជ្ឈមណ្ឌលឯកសារកោះថ្មៗ ( ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

ខ្លួនដែលបានរៀនសូត្រទៅដល់ក្រុមគ្រួសារ មិត្តភក្តិ នៅក្នុងសាលារៀន និងតំបន់មូលដ្ឋានដែលគាត់រស់នៅថែមទៀតៗ

## ៣) វិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន មេមត់ ៖

នៅពេលរសៀលម៉ោង២ថ្ងៃដដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្មបានធ្វើដំណើរទៅដល់វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ៗ ពេលនៅដល់លោកគ្រូ អ្នកគ្រូ និងសិស្ស ចំនួន៥នាក់ ស្រី៣នាក់និងប្រុស២នាក់ គឺកំពុងរង់ចាំទទួលក្រុមការងារជាស្រេចៗ លោក ឡុង ដានី បានណែនាំខ្លួន និងឈ្មោះក្រុមការងាររបស់មជ្ឈមណ្ឌលឯកកោះថ្មដល់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស និងនិយាយសំណេះសំណាលជាមួយលោកគ្រូអ្នកគ្រូ ប្រមាណ១៥នាទីៗ បន្ទាប់មក លោក ឡុង ដានី បានធ្វើការពន្យល់សិស្សានុសិស្សអំពីកម្រងសំណួរដើម្បីឲ្យសិស្សានុសិស្សងាយស្រួលយល់ៗ នៅពេលគាត់កំពុងពន្យល់ គាត់យល់ឃើញថាសិស្សានុសិស្ស





មានចំណេះដឹងច្រើននិងយល់អំពីសំណួរៗ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកកម្រងសំណួរឲ្យសិស្សានុសិស្សបំពេញៗ សិស្សានុសិស្សចាប់ផ្តើមបំពេញកម្រងសំណួរយ៉ាងរហ័ស និងបានចប់សព្វគ្រប់នូវសំណួរទាំង៧ នៅវេលាម៉ោង០៣:០០នាទីរសៀលៗ សិស្សបានបំពេញកម្រងសំណួរប្រកបដោយភាពក្លាហាន និងជឿជាក់ដោយប្រើរយៈពេល ខ្លីៗ ដូចនេះសិស្សានុសិស្សនៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន មេមត់ ពិតជាទទួលបានចំណេះដឹងច្រើន «ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍» ៗ



វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនលាជលើៗ ( ឈុំ វ៉ា/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# សិស្សមកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន លាជលើ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦

ឡុង ដានី






សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន លាជលើ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និង ទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៧:៣០នាទីព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ សិស្សានុសិស្សមកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន លាជលើ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ចំនួន៥០នាក់ ក្នុងនោះស្រី២៩នាក់ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ វេទិកាថ្នាក់រៀននេះផ្តោតសំខាន់លើប្រវត្តិសាស្ត្រ និងទំនាក់ទំនងការបរទេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)។

ជាកិច្ចចាប់ផ្តើមលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម បានដឹកនាំសិស្សានុសិស្សដើរទស្សនាពិព័រណ៍រូបថតដែលបានដាក់បង្ហាញនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម។ លោក ឡុង ដានីបានចាប់ផ្តើមបង្ហាញពីបណ្តុំរូបថតសង្គ្រាមនៅចន្លោះឆ្នាំ១៩៧០ និង១៩៧៥, បណ្តុំរូបថតអំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩), បណ្តុំរូបថតអំពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩។ បណ្តុំរូបថតអំពីភស្តុតាងឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបគំនូរ និងផែនទីបង្ហាញផ្លូវនៃដំណើររបស់សមមិត្ត ហ៊ុន

សែន និងយុទ្ធមិត្ត៤រូប ចេញទៅប្រទេសវៀតណាម កាលថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីសុំការអន្តរាគមន៍កសាងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឲ្យរួចផុតពីសេចក្តីស្លាប់។ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ត្រូវបានបង្កើតឡើងដោយមានសមមិត្ត ហ៊ុន សែន គឺជាស្ថាបនិក។ ចាប់ពីខែឧសភា ដល់ចុងខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា បានរីកធំធាត់ និងកើនចំនួនរហូតដល់២៣ កងវរសេនាតូច និងប្រមាណជាង១០០ ក្រុមប្រតិបត្តិការប្រដាប់អាវុធ ដែលមានកងកម្លាំងសរុបប្រមាណជាង១ម៉ឺននាក់។ បន្ទាប់មក កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានសហការ ជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩។ នៅក្នុងនោះដែរ លោក ឡុង ដានី ក៏បានចាក់បញ្ចាំងខ្សែភាពឯកសារដំណើរឆ្ពោះទៅផ្តួលរំលំរបប ប៉ុល ពត ដល់សិស្សានុសិស្សបានទស្សនា។

បន្ទាប់មក លោក ឡុង ដានី បានធ្វើបទបង្ហាញប្រវត្តិសាស្ត្រ និង ទំនាក់ទំនងការបរទេសនៃរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដោយចាប់ផ្តើមពីពាក្យថា ខ្មែរក្រហម និងការអនុវត្តគោលនយោបាយ ៨ចំណុច របស់ខ្មែរក្រហមបន្ទាប់ពីខ្លួនទទួលជ័យជម្នះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ កម្ពុជាប្រជាធិបតេយ្យបានធ្វើទំនាក់ទំនងការទូតជាមួយប្រទេសចិន កូរ៉េខាងជើង វៀតណាម ឡាវ រូម៉ានី យូហ្គោស្លាវី គុយបា អាល់បានី និង អេហ្ស៊ីប ដោយប្រទេសទាំងនោះមានស្ថានទូតប្រចាំនៅទីក្រុងភ្នំពេញ។ ចំណែក កម្ពុជាប្រជាធិបតេយ្យបានបើកស្ថានទូតរបស់ខ្លួននៅប្រទេសចិន កូរ៉េខាងជើង វៀតណាម និង ឡាវ។ ទំនាក់ទំនងជាមួយចិន និងកូរ៉េខាងជើងមានលក្ខណល្អប្រសើរ ហើយទំនាក់ទំនងជាមួយ ឡាវមានលក្ខណល្អបង្គួរ។ ចំណែក ទំនាក់ទំនងជាមួយវៀតណាមកាន់តែអាក្រក់ទៅៗ ព្រោះមានការប៉ះទង្គិចគ្នានៅតាមបណ្តោយព្រំដែន និងការខ្វែងគំនិតគ្នាលើមនោគមវិជ្ជា។ ដោយសារទំនាក់ទំនងការទូតរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសចិនមានលក្ខណល្អប្រសើរនោះ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិន គឺជាប្រធានក្រុមនៃអ្នកការទូតប្រចាំនៅប្រទេសកម្ពុជា និងមានសិទ្ធិធ្វើដំណើរទៅកាន់ទីកន្លែងនានាក្នុងប្រទេសកម្ពុជា។ ប្រទេសចិនបានបញ្ជូនក្រុមជំនាញការមកជួយកម្ពុជាប្រជាធិប-តេយ្យរាប់ពាន់នាក់ដូចជាអ្នកបច្ចេកទេស និងជាទីប្រឹក្សាស្ទើរគ្រប់ផ្នែក។ ប្រទេសចិន គឺជាប្រទេសដែលបាននាំចូលស្រូវ វត្ថុធាតុដើមកសិកម្ម និងឧស្សាហកម្មពីកម្ពុជាធំបំផុត និងជាប្រទេសដែលផ្តល់គ្រឿងសព្វាវុធ និងគ្រឿងយន្តកសិកម្មមកកម្ពុជាច្រើនបំផុតដែរ។ កម្ពុជាបានបញ្ជូនយុវជនទៅរៀនសូត្រផ្នែកកងទ័ព និងកម្មករជំនាញនៅប្រទេសចិនរាប់ពាន់នាក់។ ពេលរបបកម្ពុជាប្រជាធិបតេយ្យមានជម្លោះជាមួយវៀតណាមឆ្នាំ១៩៧៨ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានស្នើឲ្យចិនបញ្ជូនទ័ពមកជួយច្បាំងជាមួយវៀតណាម។ ប៉ុន្តែចិនបានពន្យារពេល ហើយបានស្នើឲ្យមានបទឈប់បាញ់ និងធ្វើការចរចាគ្នា។ កម្ពុជាប្រជាធិបតេយ្យបានច្រានចោលសំណើរនេះ។ នៅឆ្នាំ១៩៧៨ កម្ពុជាប្រជាធិបតេយ្យ បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីពង្រីកទំនាក់ទំនងការទូត និងវិស័យពាណិជ្ជកម្មក្រៅប្រទេសរបស់ខ្លួន។ កម្ពុជាប្រជាធិបតេយ្យមានទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសចិន កូរ៉េខាងជើង ថៃ ជប៉ុន ហុងកុង ម៉ាដាហ្គាស្កា បង់ក្លាដែស និងសិង្ហបុរី។ កម្ពុជាប្រជា-ធិបតេយ្យបាននាំចេញទំនិញសំខាន់រួមមាន៖ ស្រូវ ជ័រកៅស៊ូ ឈើ និងសរីរាង្គសត្វកម្ររួមមាន ស្បែក ភ្លុក និងស្នែក។ ចំណែកទំនិញនាំចូល រួមមាន៖ គ្រឿងសព្វាវុធ រថក្រោះ កាំភ្លើងធំ គ្រឿងយន្តសម្រាប់ធ្វើកសិកម្ម ផលិតផលគីមី និងក្រណាត់ជាដើម។

លោក ឡុង ដានី ក៏បានធ្វើបទបង្ហាញអំពីដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហមក្នុងសំណុំរឿង ០០១ និង០០២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ

កម្ពុជា។ នៅក្នុងសំណុំរឿង០០១ ពាក់ព័ន្ធនឹងការជំនុំជម្រះក្តី កាំងហ្កេកអ៊ាវ ហៅ ឌុចៗ ឌុច គឺជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ ដែលប្រជាជនកម្ពុជាស្គាល់ជា ទូទៅ ថាគុកទួលស្លែង ស្ថិតនៅ ទីក្រុងភ្នំពេញ។ នៅឆ្នាំ២០១២ ឌុច ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ សំណុំរឿង០០២ នៅឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួន៤រូប រួមមាន៖ អៀង សារី នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ដោយសារភាពស្មុគស្មាញនៃរឿងក្តី និងអាយុរបស់ជនជាប់ចោទ ទើបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រេចបំបែកសំណុំរឿង០០២ជាពីរគឺ សំណុំរឿង០០២ វគ្គ១ និងសំណុំរឿង០០២ វគ្គ២ សម្រាប់ការជំនុំជម្រះពីរផ្សេងគ្នា។

សំណុំរឿង០០២វគ្គ១ ដោយសារ អៀងសារី និង អៀង ធីរិទ្ធ មានជំងឺ និងទទួលមរណភាពនៅឆ្នាំ២០១៣ និង ២០១៥។ ដូច្នេះ នៅឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តន្ទាទោស នួនជា និង ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាក់ទងនឹងការសម្លាប់ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងដំណាក់កាល ទីពីរនៃការផ្លាស់ប្តូរទីលំនៅប្រជាជន។ សំណុំរឿង០០២ វគ្គ២ គឺជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និង អំពើប្រល័យពូជសាសន៍ ដែលបានប្រព្រឹត្តឡើងនៅតាមសហករណ៍ ការដ្ឋានការងារ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សមួយចំនួនដែលជាប់ពាក់ព័ន្ធទៅនឹងក្រុមមនុស្សដែលជាក្រុមគោលដៅជាក់លាក់ ដូចជាជនជាតិចាម ជនជាតិវៀតណាម អ្នកកាន់សាសនាព្រះពុទ្ធ និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថាប្រព្រឹត្តបទឧក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ



សិស្សានុសិស្សមកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែន លាដលើ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ុច-១៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និង អំពើប្រល័យពូជសាសន៍ ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មព្រហ្មទណ្ឌរួមជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត។

នៅឆ្នាំ២០១៩ នួន ជា បានស្លាប់ដោយសារជរាភាព។ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចផ្តន្ទាទោស ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិតបន្ថែមទៀតចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មខាងលើ និងបានបិទបញ្ចប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែម្តង។ នៅវេលាម៉ោង១១ព្រឹកថ្ងៃដដែល សិស្សានុសិស្សបានបន្តដំណើរទៅទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦ បន្តទៀត។







សិស្សានុសិស្សមកពីវិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន លាដលើ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និង ទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# សាមណនិស្សិត និស្សិត និងសាស្ត្រាចារ្យ នៃពុទ្ធិកសកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## ទស្សនកិច្ចសិក្សាមជ្ឈមណ្ឌលឯកសារកោះថ្ម និងតំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦

**ឡុង ដានី**





សាមណនិស្សិតចំនួន២អង្គ ព្រមទាំងនិស្សិត និងសាស្ត្រាចារ្យចំនួន៤០នាក់ មកពីពុទ្ធិកសកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ខេត្តកំពង់ចាម បានមកទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៨:៣០នាទីព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៣ សាមណនិស្សិតចំនួន២អង្គ ព្រមទាំងនិស្សិត និងសាស្ត្រាចារ្យចំនួន៤០នាក់ មកពីពុទ្ធិកសកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ខេត្តកំពង់ចាម បានមកទស្សនកិច្ចសិក្សា និងចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារកោះថ្ម។

ជាកិច្ចចាប់ផ្តើមលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានណែនាំខ្លួន ក្រុមការងារ និងមជ្ឈមណ្ឌលឯកសារកោះថ្មដែលមានទីតាំងស្ថិតនៅក្នុងសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម។ បន្ទាប់មក លោក ឡុង ដានី បានដឹកនាំសាមណនិស្សិត និស្សិត និងសាស្ត្រាចារ្យទាំងអស់

ដើរទស្សនាពិព័រណ៍រូបថតដែលបានដាក់តាំងបង្ហាញនៅក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម និងរៀបរាប់អំពីបណ្តុំរូបថតអំពីសង្គ្រាមចាប់ពីចុងទសវត្សរ៍ឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៧៥, បណ្តុំរូបថតអំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩), បណ្តុំរូបថតអំពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩, បណ្តុំរូបថតអំពីភស្តុតាងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩), រូបគំនូរ និងផែនទីបង្ហាញផ្លូវនៃដំណើររបស់សមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៤រូបចេញទៅប្រទេសវៀតណាមកាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីសុំការអន្តរាគមន៍កសាងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា វាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឲ្យរួចផុតពីសេចក្តីស្លាប់។

នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ត្រូវបានបង្កើតឡើងដោយមានសមមិត្ត ហ៊ុន សែន ជាស្ថាបនិក។ ចាប់ពីខែឧសភា ដល់ចុងខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានរីកធំធាត់ និងកើនចំនួនរហូតដល់២៣កងវរសេនាតូច និងប្រមាណជាង១០០ក្រុមប្រតិបត្តិការប្រដាប់អាវុធ ដែលមានកងកម្លាំងសរុបប្រមាណជាងមួយម៉ឺននាក់។ បន្ទាប់មក កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានសហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ នៅក្នុងឱកាសនោះ លោក ឡុង ដានី ក៏បានចាក់បញ្ចាំងខ្សែភាពឯកសារដំណើរឆ្ពោះទៅផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ដល់និស្សិត និងសាស្ត្រាចារ្យបានទស្សនា។

តមកលោក ឡុង ដានី បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ លោក ឡុង ដានីបានរៀបរាប់ថា បន្ទាប់ពីទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានអនុវត្តគោលនយោបាយ៨ចំណុចរបស់ខ្លួនមានដូចជា៖ ១) ជម្លៀសប្រជាជនដោយបង្ខំ ២) បំបាត់ផ្សារ និងរូបិយប័ណ្ណ ៣) ផ្សឹកព្រះសង្ឃ និងកម្ទេចវត្តអារាម ៤) បិទសាលារៀន ៥) បង្កើតសហករណ៍ ៦) បំបែកក្រុមគ្រួសារមិនឲ្យជួបជុំគ្នា ៧) សម្លាប់បញ្ញវន្ត មន្ត្រីរដ្ឋការ និងប្រជាជនស្លូតត្រង់ ៨) បណ្តេញជនជាតិវៀតណាម និងធ្វើសង្គ្រាមតាមព្រំដែនជាមួយវៀតណាម។ ដោយសារខ្មែរក្រហមការអនុវត្តគោលនយោបាយខាងលើបានបណ្តាលឲ្យប្រជាជនកម្ពុជាប្រមាណ២លាននាក់បានស្លាប់ ដោយសារការសម្លាប់ អត់អាហារ ធ្វើការងារហួសកម្លាំង និងឈឺគ្មានការព្យាបាលត្រឹមត្រូវ។ របបកម្ពុជាប្រជាធិបតេយ្យមានរយៈពេលត្រឹមតែ៣ឆ្នាំ ៨ខែ ២០ថ្ងៃប៉ុណ្ណោះ ប៉ុន្តែបណ្តាលឲ្យប្រទេសកម្ពុជាប្រឈមនឹងបញ្ហាដូចតទៅគឺ៖ ទី១) សុខភាពប្រជាជនទ្រុឌទ្រោម ដោយសារខ្មែរក្រហមបង្ខំប្រជាជនឲ្យធ្វើការងារពលកម្មហួសកម្លាំង ហូបចុកមិនគ្រប់គ្រាន់ និងពេលមានជំងឺគ្មានគ្រូពេទ្យ និងថ្នាំព្យាបាលត្រឹមត្រូវ ទី២) ខ្មែរក្រហមបានធ្វើបន្សុទ្ធកម្មកម្មាភិបាល យុទ្ធជនយុទ្ធនារី កងទ័ព និងប្រជាជនខ្លួនឯងជាទ្រង់ទ្រាយធំ ជាពិសេសនៅភូមិភាគបូព៌ា ចាប់ពីឆ្នាំ១៩៧៧ ដែលជាមូលហេតុធ្វើឲ្យកម្មាភិបាល យុទ្ធជន និងប្រជាជនមួយចំនួនធំបានរត់ភៀសខ្លួនទៅប្រទេសជិតខាង និងងើបឡើងបះបោរប្រឆាំងនឹងរបបខ្មែរក្រហមវិញ ទី៣) ការប៉ះទង្គិចជាមួយប្រទេសវៀតណាម គឺជាមូលហេតុធំបំផុតមួយដែលបណ្តាលឲ្យរបបខ្មែរក្រហមដួលរលំលឿន គឺនៅខែធ្នូឆ្នាំ១៩៧៧ របបខ្មែរក្រហមបានប្រកាសផ្តាច់ទំនាក់ទំនងការទូតទាំងស្រុងជាមួយវៀតណាម ហើយប្រទេសទាំងពីរបានប្រយុទ្ធគ្នាស្ទើរពេញមួយរយៈកាលនៃឆ្នាំ១៩៧៨ ជាពិសេសនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានសហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយចូលប្រទេសកម្ពុជាជាទ្រង់ទ្រាយធំ និងបានចូលកាន់កាប់ទីក្រុងភ្នំពេញទាំងស្រុងនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។



សាមណនិស្សិតចំនួន២អង្គ ព្រមទាំងនិស្សិត និងសាស្ត្រាចារ្យចំនួន ៤០នាក់ មកពីពុទ្ធិកសកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និង ទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ សង្គមកម្ពុជាទាំងមូលបានទទួលផលប៉ះពាល់ដូចខាងក្រោម៖

១) បន្សល់ទុកស្ត្រីមេម៉ាយ និងក្មេងកំព្រារាប់ពាន់នាក់នៅក្នុងសង្គមកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហម
២) ប្រជាជនកម្ពុជាភាគច្រើនមានជំងឺបាក់ស្បាត និងមានប្រជាជនកម្ពុជាមួយចំនួនបានសម្រេចចិត្តធ្វើចំណាកស្រុក និងជាជនភៀសខ្លួន
៣) បានបន្សល់ទុកគ្រាប់មីនរាប់លានគ្រាប់
៤) អ្នករស់រានមានជីវិតភាគច្រើនមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ
៥) សេដ្ឋកិច្ចប្រទេសកម្ពុជាបានធ្លាក់ដល់កម្រិតសូន្យ
៦) ពុំមានអ្នកចេះដឹងច្រើន សម្រាប់ជួយអភិវឌ្ឍន៍ប្រទេស

នៅចុងបញ្ចប់នៃវេទិកាថ្នាក់រៀន លោក ឡុង ដានី បានធ្វើបទបង្ហាញអំពីដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហមក្នុងសំណុំរឿង០០១ និង០០២នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅក្នុងសំណុំរឿង០០១ ពាក់ព័ន្ធនឹងការជំនុំជម្រះក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុចៗ ឌុច គឺជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ (ដែលប្រជាជនកម្ពុជាទូទៅបានស្គាល់ថា ជាគុកទួលស្លែងស្ថិតនៅ ទីក្រុងភ្នំពេញ)។ នៅឆ្នាំ២០១២ ឌុច ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តន្ទាទោស សឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩។

សំណុំរឿង០០២ នៅឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួន៤រូប រួមមាន៖ អៀង សារី នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ដោយសារភាពស្មុគស្មាញនៃរឿងក្តី និងអាយុរបស់ជនជាប់ចោទ ទើបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រេចបំបែក

សំណុំរឿង០០២ ជាពីរគឺ សំណុំរឿង០០២ វគ្គ១ និងសំណុំរឿង០០២ វគ្គ២ សម្រាប់ការជំនុំជម្រះពីរផ្សេងគ្នា។ សំណុំរឿង០០២វគ្គ១ ដោយសារ អៀង សារី និង អៀង ធិរិទ្ធ មានជំងឺ និងទទួលមរណភាពនៅឆ្នាំ២០១៣ និង២០១៥។ ដូច្នេះ នៅឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្តន្ទាទោស នួន ជា និង ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងការសម្លាប់ ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងដំណាក់កាលទីពីរនៃការផ្លាស់ប្តូរទីលំនៅប្រជាជន។

សំណុំរឿង០០២ វគ្គ២ គឺជាប់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងនៅតាមសហករណ៍ ការដ្ឋានការងារ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សមួយចំនួនដែលជាប់ពាក់ព័ន្ធទៅនឹងក្រុមមនុស្សដែលជាក្រុមគោលដៅជាក់លាក់ ដូចជាជនជាតិចាម ជនជាតិវៀតណាម អ្នកកាន់សាសនាព្រះពុទ្ធ និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថាបានប្រព្រឹត្តបទឧក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និង អំពើប្រល័យពូជសាសន៍ ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មព្រហ្មទណ្ឌរួមជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត។ នៅឆ្នាំ២០១៩ នួន ជា បានស្លាប់ដោយសារជរាភាព។ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចផ្តន្ទាទោស ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិតបន្ថែមទៀត ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មខាងលើ និងបានបិទបញ្ចប់ការជំនុំជម្រះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែម្តង។

នៅវេលាម៉ោង១១៖៣០នាទីព្រឹកថ្ងៃដដែល សាមណនិស្សិត និស្សិត និងសាស្ត្រាចារ្យនៃពុទ្ធិកសកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ខេត្តកំពង់ចាម បានបន្តដំណើរទៅទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦ មុននឹងបញ្ចប់កម្មវិធី។





សាមណនិស្សិតចំនួន២អង្គ ព្រមទាំងនិស្សិត និងសាស្ត្រាចារ្យចំនួន ៤០នាក់ មកពីពុទ្ធិកសកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩) នៅខេត្តតាកែវ

*រីម ស្រីស្រស់*







សិស្សានុសិស្សមកពីវិទ្យាល័យ ជា ស៊ីម តាកែវ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៨ និងថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍សម្រាប់សិស្សានុសិស្សមកពីវិទ្យាល័យជាស៊ីមតាកែវចំនួន៥៥នាក់ ក្នុងនោះស្រី៣៦នាក់ ក្រោមការដឹកនាំពីគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាចំនួន២នាក់ ដើម្បីផ្តល់ការយល់ដឹងបន្ថែមពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់១៩៧៩) និងវិធីទប់ស្កាត់ដើម្បីកុំឲ្យរបបកម្ពុជាប្រជាធិបតេយ្យនេះកើតឡើងម្តងទៀតៗ ប្រធានបទដែលត្រូវលើកយកមកបង្ហាញនៅ

ក្នុងវេទិកានេះ គឺ«ទំនាក់ទំនងការបរទេសកម្ពុជាប្រជាធិបតេយ្យ និងចំណងមិត្តភាពជាមួយប្រទេសចិន»។

ជាដំបូង លោកគ្រូខ ឡែស ផេង ពង្សរ៉ាស៊ី បានណែនាំប្រាប់ដល់ក្រុមយុវជនទាំងអស់អំពីផ្ទាំងពិព័រណ៌រូបថតចំនួន៨ផ្ទាំង ដែលបានដាក់តាំងនៅក្នុងបរិវេណមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ ផ្ទាំងរូបថតទាំងនោះបានបង្ហាញអំពី ៖ ១) សំណង់ផ្ទះដែលត្រូវបានទុកចោលកាលពីក្នុង និងក្រោយរបបខ្មែរក្រហម ព្រមទាំងទិដ្ឋភាពផ្ទះក្នុងទីក្រុងភ្នំពេញដែលគ្មានមនុស្សរស់នៅ ២) ការបំផ្លិចបំផ្លាញរបស់ខ្មែរក្រហមទៅលើហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសដូចជាការបំផ្លាញស្ពានជ្រោយចង្វារ ៣) ទិដ្ឋភាពនៃការចូលមកដល់ទីក្រុងភ្នំពេញរបស់កងកម្លាំងខ្មែរក្រហម និងការអបអរសាទររបស់ប្រជាជនកម្ពុជាចំពោះវត្តមាននៃកម្លាំងទាំងនោះ ៤) ទិដ្ឋភាពនៃការវិលត្រឡប់របស់ប្រជាជនកម្ពុជាដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្រោយខែមករា ឆ្នាំ១៩៧៩ ៥) រូបថតជាច្រើនសន្លឹកដែលបង្ហាញពីមេដឹកនាំកំពូលៗរបស់ខ្មែរក្រហម និងបក្ខពួក។

បន្ទាប់មក សិស្សានុសិស្សទាំងអស់ត្រូវបានណែនាំអំពីផ្ទាំងរូបថតមួយចំនួននៅខាងក្នុងការិយាល័យ និងបានបង្ហាញពីកេសសម្រាប់ដាក់គ្រាប់ដែលបន្សល់ពីសម័យសង្គ្រាមកាលពីឆ្នាំ១៩៧២ ក្នុងទឹកដីស្រុកបុរីជលសារ ខេត្តតាកែវ។ មុននឹងចាប់វេទិកាថ្នាក់រៀនសិស្សានុសិស្សទាំងអស់តម្រូវឲ្យបំពេញកម្រងសំណួរវាស់ស្ទង់ចំណេះដឹងស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងទំនាក់ទំនងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ។ តមកទៀតគ្រូខ ឡែស ក៏បានណែនាំខ្លួន, ទីតាំងការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ និងបង្ហាញអំពីវត្ថុបំណងនៃវេទិកាថ្នាក់រៀនសម្រាប់ថ្ងៃនេះគឺ ៖ ទី១) ឈ្វេងយល់បន្ថែមពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យផ្តោតលើទំនាក់ទំនងការបរទេសរបស់ខ្លួនជាមួយនឹងបណ្តាប្រទេសមួយចំនួន និងវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍ ទី២) ប្រើប្រាស់ចំណេះដឹងដែលទទួលបានពីវេទិកាថ្ងៃនេះ សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ខ្លួនទាក់ទងនឹងការចងចាំ និងការទប់ស្កាត់អំពើហិង្សា ទី៣) លើកស្ទួយគំនិត និងផ្លាស់ប្តូរការគិតពីការចង់ប្រើប្រាស់អំពើហិង្សា ទៅជាការពន្ធត់អំពើហិង្សា ដើម្បីស្ថេរភាពសង្គម និងអភិវឌ្ឍន៍ប្រទេសដោយគ្មានអំពើហិង្សា។

ជាកិច្ចចាប់ផ្តើមការបង្រៀន លោកគ្រូខ ឡែស បានបំផុសសិស្សានុសិស្សឲ្យនិយាយពីអ្វីដែលខ្លួនបានដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម និងទំនាក់ទំនងការបរទេសរបស់ខ្មែរក្រហម។ ការបំផុសនេះ គឺដើម្បីទាញចំណាប់អារម្មណ៍សិស្សឲ្យផ្តោតលើមេរៀនក្នុងថ្ងៃនេះអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងទំនាក់ទំនងការបរទេស។ បន្ទាប់មក គ្រូខ ឡែស បានផ្តល់ឱកាសដល់សិស្សានុសិស្សទាំងអស់លើកឡើងពីអ្វីដែលខ្លួនចង់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម និងទំនាក់ទំនងការបរទេសរបស់ខ្មែរក្រហម។ ចំណុចនេះ គឺដើម្បីអនុញ្ញាតឲ្យសិស្សានុសិស្សលើកឡើងពីចម្ងល់ផ្សេងៗ របស់ខ្លួនទាក់ទងនឹងប្រធានបទ។ សិស្សានុសិស្សក៏លើកជាសំណួរទៅកាន់គ្រូខ ឡែស។ បន្ទាប់ពីសិស្សសួរចប់ លោកគ្រូខ ឡែស ក៏បានឆ្លើយតបទៅកាន់សិស្សានុសិស្ស ដោយយោងទៅតាមសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ, សៀវភៅសត្រូវបងប្អូនឯង និងការចាក់បញ្ចាំងខ្សែភាពយន្តឯកសារស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យសិស្សទស្សនា។ វេទិកាថ្នាក់រៀននេះបញ្ចប់នៅម៉ោង១២ថ្ងៃត្រង់។

នៅពេលរសៀល ក្រុមយុវសិស្សទាំងអស់បានបន្តធ្វើទស្សនកិច្ចសិក្សាទៅកាន់ ៖ ១) ទីតាំងទួលធាតុ គឺជាទីកន្លែងដែលសិស្សានុសិស្សបានរៀនសូត្របន្ថែមពីសំណង់រួមដែលអ្នករស់រានមានជីវិតសមនឹងទទួលបាន ក្រោយពីតុលាការកាត់ទោសខ្មែរក្រហមបញ្ចប់ទៅ។ លោកគ្រូខ ឡែស បានពន្យល់ដល់សិស្សានុសិស្សអំពីមូលហេតុដែលនាំឲ្យមានការសាងសង់សំណង់ចេតិយ និងផ្ទាំងពាក្យស្លោកនៃការចងចាំ នៅលើទីទួលធាតុនោះ ២) មន្ទីរ

សន្តិសុខស្រុក១០៥ បុមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលជាទីតាំងសម្លាប់មនុស្ស ឃុំឃាំងមនុស្ស និងធ្វើទារុណកម្មមនុស្សយ៉ាងឃោរឃៅ។ នៅទីនោះ សិស្សានុសិស្សបានឈ្វេងយល់បន្ថែមពីភ័ស្តុតាងជាក់ស្តែងមួយចំនួនដូចជា ស្លាកស្នាមរណ្តៅសាកសព និងមន្ទីរបូជនីយដ្ឋានធ្វើអំពីថ្មមួយនៅចំកណ្តាលទីតាំងក្រាំងតាចាន់ដែលមានតម្កល់ឆ្អឹងលលាដ៍ក្បាល និងឆ្អឹងស្នូងដៃជើងរបស់សាកសព។ ខាងក្រោមនេះគឺជាចំណាប់អារម្មណ៍របស់សិស្សានុសិស្សបន្ទាប់ពីបញ្ចប់វេទិកាថ្នាក់រៀន៖

នាងខ្ញុំឈ្មោះ នាក់ គីមលីនថាណា អាយុ១៧ឆ្នាំ គឺជាសិស្សនៃវិទ្យាល័យជាស៊ីមតាកែវ។ ខ្ញុំទទួលបានចំណេះដឹងអំពីទំនាក់ទំនងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានទំនាក់ទំនងល្អជាមួយប្រទេសចិន ហើយប្រទេសឡាវមានទំនាក់ទំនងល្អបន្តួរ។ ចំណែកឯប្រទេសវៀតណាមវិញគឺមានជម្លោះជាមួយខ្មែរក្រហម។ ខ្ញុំយល់ថាប្រទេសកម្ពុជាមានទំនាក់ទំនងល្អជាមួយប្រទេសចិនអាចជួយអភិវឌ្ឍន៍ប្រទេសជាតិរបស់យើង។ ខ្ញុំគិតថាការបង្កើតវេទិកាថ្នាក់រៀននេះឡើង គឺមានសារសំខាន់យ៉ាងខ្លាំង ព្រោះខ្ញុំដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួន ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិនាពេលខាងមុខ។

នាងខ្ញុំឈ្មោះ ខឹម ច័ន្ទសកដា អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យជាស៊ីមតាកែវ។ ខ្ញុំដឹងថា របបកម្ពុជាប្រជាធិបតេយ្យមានទំនាក់ទំនងល្អជាមួយប្រទេសចិន។ ពេលនោះចិនបានជួយដល់កម្ពុជាប្រជាធិបតេយ្យ ដូចជា គ្រឿងសព្វាវុធដើម្បីធ្វើសង្គ្រាម។ ខ្ញុំយល់ថា របបកម្ពុជាប្រជាធិបតេយ្យគឺជារបបដែលឃោរឃៅ បង្ខិតបង្ខំឲ្យប្រជាជនធ្វើការងារហួសកម្លាំង ឲ្យហូបចុកមិនបានគ្រប់គ្រាន់ បំបែកបំបាក់សមាជិកគ្រួសារ មិនមានថ្នាំគ្រប់គ្រាន់សម្រាប់ព្យាបាលជំងឺ។ ក្រោយពីខ្ញុំបានចូលរួមវេទិកាថ្នាក់រៀនរយៈពេលមួយព្រឹកនេះ ខ្ញុំទទួលបាននូវចំណេះដឹងថ្មីច្រើនជាងមុន។







សិស្សានុសិស្សមកពីវិទ្យាល័យ ជាស៊ីម តាកែវ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) នៅមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥ -១៩៧៩)

## នៅសហគមន៍ជនជាតិដើមភាគតិចព័រ ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់

ឡុង ដានី



នៅព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាអប់រំសហគមន៍ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ -១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចព័រ ក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចព័រ និងកូនចៅជំនាន់ក្រោយចូលរួមចំនួន៤១នាក់ ក្នុងចំណោមនោះមានស្រី២៨នាក់ មកចូលរួម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាអប់រំសហគមន៍ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ -១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចព័រ ក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចព័រ និងកូនចៅជំនាន់ក្រោយចំនួន៤១នាក់ ក្នុងចំណោមនោះមានស្រី២៨នាក់ មកចូលរួម។

ចាប់ផ្តើមកម្មវិធី លោក ខៀវ ហ៊ុម អាយុ៦៧ឆ្នាំ អនុភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់មានប្រសាសន៍ថា ភូមិស្ទឹងថ្មី ឬចំណុចទួលកកោះ នេះប្រជាជនភាគច្រើនគឺជាជនជាតិដើមភាគតិចព័រ ដែលមានស្រុកកំណើតនៅភូមិទួលគ្រួស ឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវ៉ាញ ខេត្ត



នៅព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាអប់រំសហគមន៍ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចព័រ ក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចព័រ និងកូនចៅជំនាន់ក្រោយចូលរួមចំនួន៤១នាក់ ក្នុងចំណោមនោះមានស្រី២៨នាក់ មកចូលរួម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពោធិ៍សាត់ (បច្ចុប្បន្នចំណុចទួលគ្រួស និងទួលកកោះ ស្ថិតក្នុងភូមិស្ទឹងថ្មីឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់)។ នៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ (១៩៧៥-១៩៧៩) ជនជាតិដើមភាគតិចព័រនៅភូមិទួលគ្រួសត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅក្នុងឃុំព្រែក និងឃុំលាច ស្រុកភ្នំក្រវាញ តំបន់២ ភូមិភាគពាយ័ព្យ។

បន្ទាប់ពីខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ភូមិទួលគ្រួសបានធ្លាក់ក្នុងតំបន់សង្គ្រាមរវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាមសហការជាមួយកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានប្រយុទ្ធគ្នានៅតាមបណ្តោយផ្លូវជាតិលេខ៥៦ រួមទាំងចំណុចភូមិទួលគ្រោះ។

នៅអំឡុងឆ្នាំ២០០០ ទើបជនជាតិដើមភាគតិចព័រចំនួន១៥៧គ្រួសារបានផ្លាស់មករស់នៅក្នុងភូមិស្ទឹងថ្មី ចំណុចទួលកកោះវិញ។ ប៉ុន្តែក្រោយមកមានប្រជាជនដែលជាជនជាតិដើមភាគតិចព័រមួយចំនួនបានវិលត្រឡប់ទៅរស់នៅឃុំព្រែក និងឃុំលាច នៃស្រុកភ្នំក្រវាញវិញ ដោយសារប្រឈមនឹងការលំបាកផ្នែកជីវភាព។ សព្វថ្ងៃនេះ មានប្រជាជនដែលជាជនជាតិដើមភាគតិចព័រសរុបចំនួន២៧២នាក់ (ក្នុងនោះមានស្រីចំនួន១៣៦នាក់) ស្មើនឹង៦៤គ្រួសារប៉ុណ្ណោះកំពុងរស់នៅក្នុងភូមិស្ទឹងថ្មីចំណុចទួលកកោះនេះ។

បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានជម្រាបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សានុសិស្សដែលបានចូលរួមក្នុងវេទិកាសហគមន៍ថា មជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានបើកដំណើរការជាសាធារណនៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ កន្លងទៅ ដោយមានគោលបំណងដូចខាងក្រោម៖

១) ធ្វើការស្រាវជ្រាវ និងចងក្រងប្រវត្តិសាស្ត្រសង្គ្រាមនៅប្រទេសកម្ពុជាចាប់ផ្តើមនៅក្នុង



ទសវត្សរ៍ឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៩០។

២) ពង្រឹងការកសាងសន្តិភាព និងការការពារជម្លោះតាមរយៈកម្មវិធីអប់រំដែលនឹងផ្តល់ឱកាសសម្រាប់យុវជននៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលបានចូលរួមរៀនសូត្រ។

៣) លើកទឹកចិត្តឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចែករំលែកពីបទពិសោធន៍របស់គាត់ក្នុងរបបខ្មែរក្រហមដល់យុវជនជំនាន់ក្រោយ។

៤) ប្រមូលរឿងរ៉ាវ និងបទពិសោធន៍ពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទីតាំងឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។

នៅក្នុងឱកាសនោះ លោក ឡុង ដានី ក៏បានធ្វើបទបង្ហាញជាសង្ខេបអំពីរបបខ្មែរក្រហមដូចជា៖ ១) ការឡើងកាន់អំណាចរបស់ខ្មែរក្រហមនៅថ្ងៃទី១៧ មេសា ១៩៧៥ ២) ការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន ៣) ការបំផ្លាញផ្សារ និងរូបិយវត្ថុ ៤) ការផ្សឹកព្រះសង្ឃ និងកម្ទេចវត្តអារាម ៥) ការបិទសាលារៀន ៦) ការបង្កើតសហករណ៍ ៧) ការបំបែកក្រុមគ្រួសារ និងការផ្តាច់ទំនាក់ទំនងក្នុងគ្រួសារ ៨) ការសម្លាប់បញ្ញវន្ត មន្ត្រីរដ្ឋការ និងប្រជាជនស្លូតត្រង់ ព្រមទាំងផលប៉ះពាល់មកលើប្រជាជននិងសង្គមកម្ពុជា បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។



នៅព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាអប់រំសហគមន៍ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចព័រ ក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចព័រ និងកូនចៅជំនាន់ក្រោយចូលរួមចំនួន៤១នាក់ ក្នុងចំណោមនោះមានស្រី២៨នាក់ មកចូលរួម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)







*នៅព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានរៀបចំវេទិកាអប់រំសហគមន៍ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចព័រ ក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចព័រ និងកូនចៅជំនាន់ក្រោយចូលរួមចំនួន៤១នាក់ក្នុងចំណោមនោះមានស្រី២៨នាក់ មកចូលរួម។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

បន្ទាប់ពីការធ្វើបទបង្ហាញ លោក ឡុង ដានី ក៏បានការបែងចែកអ្នកចូលរួមក្នុងវេទិកាអប់រំសហគមន៍ជា៥ក្រុម ដោយក្នុងក្រុមនីមួយៗមានសមាសភាពទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងយុវជនជំនាន់ក្រោយ ដើម្បីសន្ទនាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ជាពិសេសគឺរឿងរ៉ាវអ្នករស់រានមានជីវិតនៅក្នុងរបបខ្មែរក្រហមម្នាក់ៗ។

## ចំណាប់អារម្មណ៍អ្នកចូលរួម

យាន ឡឿន អាយុ៧៨ឆ្នាំ គឺជាជនជាតិដើមភាគតិចព័រ កើតនៅភូមិទួលគ្រួស ឃុំស្រែតាំងយ៉ ស្រុកភ្នំក្រវ៉ាញ ខេត្តពោធិ៍សាត់ សព្វថ្ងៃរស់នៅភូមិស្ទឹងថ្មីឃុំប្រម៉ោយ ស្រុកវាលវែងខេត្តពោធិ៍សាត់បានរៀបរាប់ថា ខ្ញុំពិតជាសប្បាយរីករាយណាស់ដែលបានមកជួបជុំជាមួយបងប្អូនដែលនៅរស់រានមានជីវិតក្រោយពីរបបខ្មែរក្រហម ជាពិសេសបងប្អូនជាជនជាតិដើមភាគតិចព័រនៅចំណុចភូមិស្ទឹងថ្មី ឬទួលកកោះនេះ។ ខ្ញុំសប្បាយចិត្តនៅពេលដែលខ្ញុំនិយាយរឿងរ៉ាវជីវិតលំបាកវេទនាក្នុងរបប៣ឆ្នាំ ៨ខែ២០ថ្ងៃ ប្រាប់បងប្អូន និងចៅៗដែលកំពុងសិក្សារៀនសូត្រ។ នៅសម័យនោះខ្ញុំមិនមានបាយហូបគ្រប់គ្រាន់ទេ និងត្រូវបង្ខំឲ្យធ្វើការងារច្រើនម៉ោង។ ខ្ញុំរស់នៅទាំងលំបាកវេទនា។ ជាចុងក្រោយខ្ញុំចង់ឲ្យក្មេងជំនាន់ក្រោយខិតខំសិក្សារៀនសូត្រទប់ស្កាត់កុំឲ្យរបបនេះវិលត្រឡប់មកម្តងទៀត។

ង៉ែន ង៉ាវ៉ា រៀនថ្នាក់ទី៩ក នៅអនុវិទ្យាល័យតាំងយ៉ ស្ថិតនៅក្នុងភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ បានលើកឡើងថា ខ្ញុំសប្បាយរីករាយខ្លាំងណាស់ពេលដែលបានចូលរួមវេទិកាសហគមន៍ និងបានស្តាប់ការចែករំលែករឿងរ៉ាវពិតរបស់តាយាយដែលបានឆ្លងកាត់របបខ្មែរក្រហម។ ខ្ញុំធ្លាប់តែរៀនប្រវត្តិសាស្ត្រខ្មែរក្រហមតាមសៀវភៅ និងលោកគ្រូអ្នកគ្រូបង្រៀននៅសាលា។ នៅពេលនេះខ្ញុំបានជួបតាយាយផ្ទាល់ ទើបខ្ញុំដឹងកាន់តែច្បាស់ថាគាត់រស់នៅលំបាកវេទនាខ្លាំងណាស់នៅក្នុងរបបខ្មែរក្រហម។ ខ្មែរក្រហមមិនឲ្យប្រជាជនហូបអាហារបានគ្រប់គ្រាន់ និងវាយដំដូចសត្វធាតុ។ ខ្ញុំមិនចង់ឲ្យរបបនេះត្រឡប់មកវិញទៀតទេ។

# មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំសិក្ខាសាលាអំពីការថែរក្សាសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាមួយនិស្សិតពេទ្យកម្ពុជា

*ភើត សុរចនា*



ក្រុមនិស្សិតពេទ្យចូលរួមសិក្ខាសាលាអំពីការថែទាំសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំសិក្ខាអំពីការថែរក្សាសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាមួយនិស្សិតពេទ្យកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា ដែលមានអ្នកចូលរួមសរុប ៤០ នាក់ ក្នុងចំណោមនោះមានស្រី១៩ នាក់។

នៅក្នុងសិក្ខាសាលាមានកម្មវិធីដូចខាងក្រោម៖

១) ការស្វាគមន៍ដល់អ្នកចូលរួម និងការបង្ហាញអំពីគម្រោង ព្រមទាំងគោលបំណងក្នុងសិក្ខាសាលា ដោយអ្នកស្រី សូ ហ្វារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា។

២) លោក គ្រីស្តូហ្វ័រ ឌៀរីង (Christopher Dearing) គឺជាទីប្រឹក្សា និងជំនាញការតាមដាននិងវាយតម្លៃ បានលើកឡើងអំពីបញ្ហាផ្លូវចិត្ត និងការផ្លាស់ប្តូរឥរិយាបទរស់នៅរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យមានសុខភាពល្អ។ នៅក្នុងឱកាសនោះក៏មានសំណួរចម្លើយពីអ្នកចូលរួមមួយចំនួនដែរ៖

សួង រក្សា គឺជានិស្សិតពេទ្យ ផ្នែកឡាបូ នៅសាកលវិទ្យាល័យចេនឡា បានសួរថា តើធ្វើយ៉ាងដូច



ម៉េចទើបអាចផ្លាស់ប្តូរឥរិយាបទសុខភាពរបស់ប្រជាជននៅក្នុងសហគមន៍បាន?

សារព័ត៌មានខ្មែរថែម បានសួរថា នៅពេលសម្ភាសន៍រឿងរ៉ាវជីវិតជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម តើធ្វើយ៉ាងដូចម៉េចដើម្បីកុំឲ្យមានការប៉ះទង្គិចផ្លូវចិត្ត?

៣) លោក វេជ្ជបណ្ឌិត ដេមី រ៉េយស៍ បានលើកឡើងពីភាពជាអ្នកដឹកនាំរបស់វេជ្ជបណ្ឌិត និងអ្នកថែទាំអ្នកជំងឺ។ បន្ទាប់មកក៏មានសំណួរពីអ្នកចូលរួមដូចខាងក្រោម ៖

អ្នកស្រី Allen Rose Cherbito បានសួរថា តើដោះស្រាយយ៉ាងដូចម៉េចពេលវេជ្ជបណ្ឌិតធ្វើលក្ខណៈវិនិច្ឆ័យខុស ឬព្យាបាលខុស?

យ៉ុន សុបញ្ញា បានសួរថា តើវេជ្ជបណ្ឌិតត្រូវតែដឹង ឬចេះគ្រប់រឿងទេ? បើមិនចេះអាចនិយាយថាមិនចេះបានឬទេ?

៤) ការណែនាំខ្លួនពីអ្នកចូលរួម និងចំណាប់អារម្មណ៍ក្នុងសិក្ខាសាលា

សារី អាមីរ៉ា គឺជានិស្សិតវេជ្ជសាស្ត្រ នៅសាកលវិទ្យាល័យន័រតុន បានលើកឡើងថា ខ្ញុំបានចាប់អារម្មណ៍នូវការបង្ហាញរបស់លោក វេជ្ជបណ្ឌិត ដេមី រ៉េយស៍ អំពីភាពជាអ្នកដឹកនាំ។




វេជ្ជបណ្ឌិត ដេមី រ៉េយ៍ ធ្វើបទបង្ហាញ។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឈុន វិច្ឆិរ៉ា គឺជានិស្សិតវេជ្ជសាស្ត្រ នៅសាកលវិទ្យាល័យន័រតុន បានលើកឡើងថា ខ្ញុំបានចាប់អារម្មណ៍នូវការបង្ហាញរបស់លោក Christopher Dearing អំពីសុខភាព និងការផ្លាស់ប្តូរឥរិយាបទ។

៥) ការចែករំលែកបទពិសោធន៍ជាមួយ កើត សុរចនា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជានៅខេត្តស្វាយរៀង។ កើត សុរចនា បានលើកឡើងពីបទពិសោធន៍ការងាររៀនសូត្រ និងការទទួលបានអាហារូបករណ៍ពីមជ្ឈ-

មណ្ឌលឯកសារកម្ពុជា និងការជួយដល់សហគមន៍។

បន្ទាប់មកអ្នកចូលរួមបានសួរអំពីពេលវេលាក្នុងការងារស្ម័គ្រចិត្តពេញម៉ោង ឬក្រៅម៉ោង និងពេលវេលក្នុងការចុះធ្វើការងារស្ម័គ្រចិត្តនៅតាមសហគមន៍។

ឆេង ជួន មកពីសាកលវិទ្យាល័យពុទ្ធិសាស្ត្រ បានសួរអំពីការងារស្ម័គ្រចិត្តអ្វីដែលអាចជួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបាន? តើសៀវភៅព័ត៌មានអំពីការថែទាំសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅមានការកែតម្រូវបន្ថែមទេ។

យ៉ុន សុបញ្ញា គឺជានិស្សិតឆ្នាំទី៦ មកពីសាកលវិទ្យាល័យពុទ្ធិសាស្ត្រ បានលើកពីចំណុចខ្វះខាតក្នុងសៀវភៅ។

ហៀត ដូ៉ារីយះ ប្រសិនបើមិនមែនជានិស្សិតពេទ្យតើអាចចូលរួមកម្មវិធីសុខភាពសហគមន៍បានឬទេ?

នៅក្នុងឱកាសនោះ អ្នកស្រី គីម សុវណ្ណដានី និងអ្នកស្រី សូ ហ្វារីណា ក៏បានឆ្លើយតបអំពីការងារដែលនិស្សិតពេទ្យចាប់អារម្មណ៍ចង់ចូលរួមជួយក្នុងសហគមន៍ ដែលជាចំណុចមួយល្អក្នុងការរួមចំណែកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ តមកលោក ព្រំ ផល្លា បានបូកសរុបលទ្ធផលសិក្ខាសាលាព្រមទាំងអរគុណអ្នកចូលរួមទាំងអស់ និងថតរូបទុកជាអនុស្សាវរីយ៍មុននឹងបញ្ចប់កម្មវិធីសិក្ខាសាលានៅថ្ងៃនេះ។

ក្រុមនិស្សិតពេទ្យចូលរួមសិក្ខាសាលាអំពីការថែទាំសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)























# បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បុសាលាក្តីខ្មែរក្រហម។

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺជាកន្លែងប្រមូលផ្តុំ និងតម្កល់ឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅបណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយ គឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបី គឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួន គឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈបណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។



## បណ្ណាល័យកងពលតូចថ្មើរជើងលេខ ៨១

***បណ្ណាល័យប្រវត្តិសាស្ត្រយោធា ស្ថិតនៅក្នុងកងពលតូចថ្មើរជើងលេខ ៨១ ក្នុងស្រុកអន្លង់វែង ខេត្តបន្ទាយមានជ័យ។***

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានទីតាំងនៅភូមិអូរចិញ្ចៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពី ថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង២៖០០ដល់ម៉ោង៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទង បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង តាមរយៈ ទូរសព្ទលេខ៖ ០១២ ៥៧០ ៨៦៥ ឬ អ៊ីម៉ែល ៖ truthlysokkheang@dccam.org

សូមអរគុណ!











## «ទួលពិឃាដ» (ត)

# ១៣. ឆាកជីវិតក្រោយព្យុះសង្គ្រាមជិតផុតទៅ (ត)

### ចំនួនបួនឆាកជីវិតក្មេងកំព្រា

*រដើកភ្លើងកូនខ្ចី, ចន្ទុះដើរឈើទាល*

មកដល់ផ្ទះ ខ្ញុំសង្កេតឃើញយាយសម្រាន្តមើលសៀវភៅធម៌ ឯប្អូនវ៉ា កំពុងរោចរដើកភ្លើងនៅក្រោមគ្រែ ដែលបងស្រីកំពុងតែឆ្អើរ ព្រោះបងកូនខ្ចីទើបឆ្លងទន្លេបានពីរបីថ្ងៃ។

គាត់ងាកមកសួរខ្ញុំទាំងក្បាលរុំក្រមាសំឡេងខ្សាវៗ ដែលមានទឹកមុខស្លេកស្លាំង និងបន្តប់ទៅដោយក្តីអាណិតប្អូនជាពន់ពេក ហើយពោលថា ប្អូនចាំក្របីថ្ងៃនេះយូរម្ល៉េះ។ ខ្ញុំខំធ្មើទឹកមុខធម្មតារួចបើកក្រមាមើលមុខក្មួយដែលគាត់ដាក់ទន្ទឹមនឹងគាត់។ ខ្ញុំខំញញឹមដាក់ក្មួយបន្តប់នូវអារម្មណ៍ខ្សឹកខ្សួលនឹករលឹក ហើយតបទៅបងស្រីថា មិនដឹងយ៉ាងម៉េចថ្ងៃនេះក្របីក្រចេញពីព្រៃខុសធម្មតា។ គាត់បន្តទៀតថា "នោះបាយគ្របនៅក្បែរបង្ក្រានផ្ទោះជាមួយជ្រក់ល្ហុង និងកូនត្រីផ្អក់ប្រឡាក់ដែលប្អូនចាប់ពីវាលថ្ងៃមុន"។ ខ្ញុំតបថា "បាទបង"។

ខ្ញុំយកបាយមួយដុំដាក់ចូលមាត់ទំពាមួយៗ សម្លឹងមើលសកម្មភាពគ្រួសារអភ័ព្វមួយនេះ ឃើញអស់ហើយ។ យាយអង្គុយមើលរដើកភ្លើងក្រោមគ្រែដែលបងកំពុងឆ្អើរ និងមើលសៀវភៅធម៌ៗ ប្អូនវ៉ា កៀរអាចម៍ចន្ទុះដើម្បីបំភ្លឺក្នុងផ្ទះ។ ឃើញបងស្រីសម្រាន្តយកដៃគងថ្ងាសក្បាលរុំដោយក្រមា ដេកជិតក្មួយវីណៃលកូនដំបូង ដូចជាគិតរឿងវែងឆ្ងាយក្នុងឆាកជីវិតគ្រួសារបងប្អូនកំព្រាបីនាក់។

បងប្រុសគាត់មិនសូវបាននៅផ្ទះទេ ដោយរវល់ដើរទិញស្រូវអង្ករយកទៅដោះដូរដើម្បីបានប្រាក់នៅឯស្រុកលើ។

ខ្ញុំមិនអាចទប់ទឹកភ្នែកបានទេ ស្រវាំងនេត្រា មើលអ្វីពុំយល់។ វាចាទឹកភ្នែកចាប់ផ្តើមស្រក់លើរនាបឫស្សី។ ខ្ញុំបែរទៅរកជញ្ជាំងកុំឲ្យឃើញទិដ្ឋភាពកម្សត់អភ័ព្វបែបហ្នឹង ដើម្បីរំងាប់អារម្មណ៍ ប៉ុន្តែបងស្រី យាយ និងប្អូនវ៉ា សម្លឹងមើលមកខ្ញុំ។



ទិដ្ឋភាព៖ ខ្ញុំហូបបាយនៅក្នុងផ្ទះ សម្លឹងមើលបងស្រីកំពុងអាំងភ្លើងជាមួយក្មួយណៃល និងយាយកំពុងមើលសៀវភៅធម៌ជាមួយប្អូនវ៉ា។
(ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំខំទំពាបាយមួយៗគ្មានរសជាតិ។

ខ្ញុំយល់ពីអារម្មណ៍អ្នកទាំងអស់គ្នា ហើយថាគ្រួសារយើងពិតជាលំបាក និងសោកសៅណាស់។ ខ្ញុំខំឈរពត់ខ្លួនងើយក្បាលឡើងលើទប់ភ្នែកទឹកសម្បោរធ្វើធម្មតា ហើយលូនចូលទៅដេកលើកន្ទេលស្លឹកត្នោតនៅមាត់ទ្វារ បងស្រីនៅតែតាមងាកមើលរូបខ្ញុំ។

ចន្ទុះចាប់ផ្ដើមរលត់បន្តិចម្ដងៗ ក្នុងផ្ទះក៏ចាប់ផ្ដើមងងឹតដែរ ឃើញតែរងើកភ្លើងនៅក្រោមក្រែដែលបងផ្អើរ។ ខ្ញុំដេកមិនលក់រសាប់រសល់នឹករឿងពីល្ងាចគួរឲ្យស្ញើប។

នឹកគិតដល់បារមីម្ចាស់ទឹកម្ចាស់ដី និងព្រលឹងឪពុកម្ដាយពិតជាស័ក្តិសិទ្ធិជួយថែរក្សានិងបង្ហាញផ្លូវខ្ញុំឲ្យបានសុខសប្បាយជាប្រផ្នូលមួយ ដូចជាសត្វពស់ធ្លាក់ពីលើដើមជ្រៃក្នុងដំបូក។ មានសំឡេងស្រែកហៅពិតប្រាកដថា ឲ្យខ្ញុំរង់ចាំក្របីនឹងចេញពីព្រៃ។ មកដល់ត្រពាំងស្វាំង ក្របីទុចមិនទៅមុខ តែពេលខ្ញុំដោះត្រដោកចេញទើបវាបកក្បាលទៅរកត្រពាំងភ្លុកវិញ។ ពិតជាមានផ្លូវងងឹតណាមួយមករារាំងក្របីមិនឲ្យទៅមុខ ហើយឲ្យដោះត្រដោកចេញ បើមិនដូច្នោះទេ ប្រហែលជាពួកកងចក្រឮសូរត្រដោក ពិតជាតាមរកសំឡេងត្រដោក ហើយតើវាសនាខ្ញុំទៅជាយ៉ាងណា?។

ទោះជាស្រុកយើងបានរំដោះចេញពីក្រញាំដៃប្រឡាក់ឈាមខោអាវខ្មៅពិតមែន តែស្រុកយើងមិនទាន់មានសន្តិភាពពេញលេញទេ ពេលយប់យើងឮតែគ្រាប់កាំភ្លើងបាញ់គ្នារវាងកងទ័ពនៃចលនាតស៊ូផ្សេងៗ។

តំណក់ភ្លៀងរលឹមលើដំបូលផ្ទះឮសូរស្រិបៗ ស្រក់មិនដាច់សោះ និងសំឡេងកូនក្អាត់ហ៊ីងយំលាន់រំពងដូចជាតន្ត្រីប្រគំបំពេអារម្មណ៍ធ្វើឲ្យលន្លង់លន្លោចនៃបទភ្លេងទំនួញឆាកជីវិតក្មេងកំព្រាឲ្យរិតតែក្ដុកក្ដួលឱរា។ ក្នុងដួងចិត្តរហែកបែកធ្លាយប្រៀបបាននឹងស្ពាយសម្ពាយទុក្ខកង្វល់ ដែលបានផ្ដល់ឲ្យគ្រួសារពិការផ្លូវចិត្តមួយនេះ។

នឹកមកដល់ត្រឹមនេះ ទឹកភ្នែកខ្ញុំនៅតែហូរមិនដាច់ ក្នុងឆាកជីវិតភ្លើងកម្មឆាបឆួល។ ខ្ញុំនៅតែគិត នៅតែស្រមៃដេកមិនលក់សោះ ប្រែខ្លួនចុះប្រែឡើង តែអំណាចនៃការភ័យខ្លាចនិងនឿយហត់អស់កម្លាំងផង ខ្ញុំក៏លង់លក់ក្នុងស្បៃរាត្រីដែលពោរពេញទៅដោយការឈឺចាប់ខ្លោចផ្សា ក្នុងដំណេកដែលកំពុងស្រេកឃ្លាននឹងសុបិនអាក្រក់ក្រោមដំបូលផ្ទះធ្លុះធ្លាយជាភ្លើងផ្សែងកម្មដែលនៅសេសសល់មិនទាន់រលត់ផុតនៅឡើយ។

ក្នុងដំណេកគ្រាំទឹកភ្នែក នៅក្នុងចិត្តនៅតែគិតនិងនឹករឭកឪពុកម្ដាយបងប្អូនភ្លោះយ៉ាងខ្លាំង ទោះជាគាត់បាត់បង់ជីវិតដោយកណ្ដាប់ដៃឃាតករឈាមជាតិឯងយ៉ាងសាហាវព្រៃផ្សៃយ៉ាងណាក៏ដោយ តែព្រលឹងរបស់គាត់នៅតែតាមថែរក្សាកូនៗឲ្យចៀសផុតពីគ្រោះកាចចង្រៃទាំងឡាយ។

# ត្រីអន្ទង់ដើមពោធិ៍ត្រពាំងភ្លុក

យប់មួយនាខែកក្ដិក ខ្ញុំបានទៅដឹកអន្ទង់ឲ្យត្រីលោតនៅដើមពោធិ៍ត្រពាំងភ្លុកខាងលិចទួលស្វាំង។ យប់កណ្ដាលអធ្រាត្រតាមពន្លឺខែរនោចមើលឃើញព្រាលៗ ស្រមោលកងចលនាតស៊ូមួយក្រុមមានគ្នាប្រមាណពី៣០-៤០នាក់ ដើរតាមភ្លឺទំនប់ប្រដាប់ដោយកាំភ្លើងគ្រប់ដៃ ស្ពាយចានឆ្នាំង អង្ករប្រកចូលក្រណាត់រាងដូចខ្នើយឱប។

ខ្ញុំឈរលើភ្លឺស្រែម្ខាងដែលមានដើមស្រូវទុំមិនទាន់ច្រូតលិចក្បាល។ មិនយូរប៉ុន្មានឮសំឡេងដើរជិតទៅៗ រំពេចនោះដែរខ្ញុំឃើញអ្នកដើរខាងមុខកាន់កាំភ្លើងអាកានិងបេសែសិបជាលក្ខណៈត្រៀមប្រយុទ្ធ ពេលមកជិតដល់ខ្ញុំឃើញច្បាស់ជាកងទ័ពវៀតណាម។

ក្នុងចិត្តខ្ញុំរំភើបត្រេកអរថានឹងរត់ចេញទៅទទួលស្វាគមន៍ពួកគេ។ ពេលនោះខ្ញុំរត់ទៅពីរនាក់អាវ៉ាតបាន

ប៉ុន្មានដំហាន ដូចជាមានអ្វីមកពញ្ញាក់ចិត្តខ្ញុំឲ្យក្រាបនៅលើភ្លឺស្រែ។ ភ្លាមនោះខ្ញុំបានទាញដៃអាវ៉ាតឲ្យក្រាបជាមួយ ហើយសំងំលួចមើលពួកគេធ្វើដំណើរបន្ត។ កន្ទុយនៃក្បួនរបស់ពួកគេមានគ្នាបីបួននាក់ដូចជាចាំការពារផ្នែកខាងក្រោយ។ រហូតពួកគេដើរផុតអស់។

បន្ទាប់មកខ្ញុំនឹកក្នុងចិត្តថា ប្រសិនបើខ្ញុំរត់ទៅជួបពួកគេប្រាកដជាមានគ្រោះថ្នាក់មិនខានដោយពួកគេអាចភាន់ច្រឡំថា ខ្ញុំជាកងចលនាតស៊ូផ្សេងៗដែលប្រឆាំងជាមួយពួកគេ ព្រោះសម័យនោះមានការបាញ់គ្នាជាហូរហែរវាងចលនាតស៊ូផ្សេងៗជាមួយកងទ័ពវៀតណាម។

នេះជាសំណាងជីវិតខ្ញុំដែរ ដែលមានអ្វីទាញកន្ត្រាក់ចិត្តខ្ញុំឲ្យក្រាបលើភ្លឺស្រែបាំងនឹងដើមស្រូវដែលពួកគេមិនអាចមើលឃើញ។ ដូច្នេះខ្ញុំសូមលើកដៃអរគុណដល់ព្រលឹងឪពុកម្តាយ និងវត្ថុសក្តិសិទ្ធិនៅទីនោះដែលបានជួយថែរក្សាខ្ញុំ។



រូបភាពឆ្នាំ២០២០៖ ដើមពោធិ៍ត្រពាំងភ្នកដាំឡើងវិញ។ (ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**ឡុង វង្សសមិទ្ធ**

**(តទៅលេខក្រោយ)**



រូបភាពឆ្នាំ២០២០៖ ត្រពាំងភ្នក។ (ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖

ព្រះឆាយាលក្ខណ៍របស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ
ថតដោយសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ នៅក្នុងឆ្នាំ១៩៧៣។

ព្រះឆាយាលក្ខណ៍នេះត្រូវបានស្កេនចេញពីសៀវភៅមួយក្បាលមានចំណងជើងថា «សម្តេចនរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជាក្នុងតំបន់រំដោះ»។ សៀវភៅនេះត្រូវបានបោះពុម្ពដោយ កងកម្លាំងប្រដាប់អាវុធរំដោះជាតិប្រជាជនខ្មែរ។

សៀវភៅនេះត្រូវបានបរិច្ចាកដោយអ្នកស្រី Crossette និងចុះនៅក្នុងបញ្ជីឯកសារលេខ D76606 នៅមជ្ឈមណ្ឌលឯកសារកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

និស្សិតមកពីសហគមន៍ជនជាតិចាមក្នុងក្រុងភ្នំពេញកំពុងអានសៀវភៅ សាក្សីប្រវត្តិសាស្ត្រ ៖ កំណត់ហេតុរបស់សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ នៅបណ្ណាល័យសម្តេចម៉ែ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 283, July 2023 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.